

# អំពើប្រល័យពូជសាសន៍ និង ការសម្លាប់រង្គាល

## នៅក្នុងប្រវត្តិសាស្ត្រពិភពលោក

ទិដ្ឋភាពទូទៅសម្រាប់ការបង្រៀនក្នុងថ្នាក់រៀននៅកម្ពុជា


និពន្ធ និងពិនិត្យផ្ទៀងផ្ទាត់ភាសាអង់គ្លេសដោយ គ្រីស្តូហ្វ័រ ឌៀរីង

បកប្រែ និងពិនិត្យផ្ទៀងផ្ទាត់ភាសាខ្មែរដោយ ផេង ពង្សរ៉ាស៊ី និង សុភ័ក្ត្រ ភាណា



មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០១៩



# អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល នៅក្នុងប្រវត្តិសាស្ត្រពិភពលោក

## ទិដ្ឋភាពទូទៅសម្រាប់ការបង្រៀនក្នុងថ្នាក់រៀននៅកម្ពុជា

និពន្ធ និងពិនិត្យផ្ទៀងផ្ទាត់ភាសាអង់គ្លេសដោយ គ្រីស្តូហ្វ័រ ឌៀរីង
បកប្រែ និងពិនិត្យផ្ទៀងផ្ទាត់ភាសាខ្មែរដោយ ផេង ពង្សរ៉ាស៊ី និង សុភ័ក្ត្រ ភាណា

មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០១៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់,
ខណ្ឌចំការមន, រាជធានីភ្នំពេញ ១២៣០១, ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ៖ +៨៥៥ (០) ២៣ ២១១ ៨៧៥
សារអេឡិចត្រូនិច៖ dccam@online.com.kh
គេហទំព័រ៖ www.dccam.org


**អំពើប្រល័យពូជសាសន៍ និង ការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក - ទិដ្ឋភាពទូទៅសម្រាប់ការបង្រៀនក្នុងថ្នាក់រៀននៅកម្ពុជា**

គ្រីស្តូហ្វ័រ ឌៀរីង
ជា ផល្លា
ស៊ូ ហ្សារីណា
លី សុខឃាង

១) ប្រទេសកម្ពុជា - ច្បាប់ - សិទ្ធិមនុស្ស
២) ប្រទេសកម្ពុជា - នយោបាយ និង រដ្ឋាភិបាល
៣) ប្រទេសកម្ពុជា - ប្រវត្តិសាស្ត្រ


គម្រោងនេះទទួលបានជំនួយថវិកាដ៏សប្បុរសពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ។



ទស្សនៈនៅក្នុងសៀវភៅនេះ គឺជារបស់អ្នកនិពន្ធផ្ទាល់តែប៉ុណ្ណោះ។
រក្សាសិទ្ធិ ឆ្នាំ២០១៩ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

មិនមានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានបោះពុម្ពឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬ ក្នុងមធ្យោបាយបែបណាឡើយដែលរួមមាន ការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ។



គំនិតរចនាសៀវភៅ និងការជ្រើសរើសរូបភាព
ដោយ ឆាំង យុ និង ទ្រី សុជាតា

ការកុំព្យូទ័រ និងការរចនាសៀវភៅដោយ លី សេនសូនីឡា

ក្របសៀវភៅ៖ រូបបដិមាអ្នកតាព្រះភក្ត្រ៨ នៅលើជម្រាលភ្នំដងរែកពយតាម៉ុក មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
ដោយ គ្រីស្តូហ្វ័រ ឌៀរីង

បោះពុម្ពនៅប្រទេសកម្ពុជា

9 789924 907879 >


ជំនួយពីពលរដ្ឋអាមេរិក

**ចំណងជើងរូបភាព៖** នេះគឺជាបដិមាអ្នកតាព្រះភក្ត្រ៨ ស្ថិតនៅលើជម្រាលភ្នំដងរែកត្រង់ចំណុចពយតាម៉ុក ជាប់នឹងទីតាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ថតដោយ គ្រីស្តូហ្វ័រ ឌៀរីង។ យោងតាមការរៀបរាប់របស់លោក ប៉ុក លក្សរាសី នេះគឺជាបដិមាមួយក្នុងចំណោមបដិមាអ្នកតាព្រះភក្ត្រ ៨ ជាច្រើនអង្គ ដែលលោក លី ស៊ុយ បានកសាងឡើងចាប់តាំងពីឆ្នាំ២០០៨ មកម្ល៉េះ។ ជាពលរដ្ឋខ្មែរម្នាក់ដែលមានជំនឿលើបារមីសក្តិសិទ្ធិនៃបុព្វបុរសខ្មែរ លោក លី ស៊ុយ បានកសាងបដិមាទាំងនេះ ដើម្បីតំណាងឲ្យមេទ័ព៨ទិស នៃសម័យអង្គរហើយយកមកតម្កល់តាមព្រំដែនសីមានៃប្រទេសកម្ពុជា ក្នុងជំនឿថាមហិទ្ធិឫទ្ធិនៃបុព្វបុរសខ្មែរ នឹងមកជួយការពារទឹកដីខ្មែរឲ្យមានសន្តិភាព រួចផុតពីការឈ្លានពាន របស់ប្រទេសជិតខាង។ លោក ប៉ុក លក្សរាសី បានរៀបរាប់ទៀតថាមុខទាំង៨ដែលមានពណ៌ខុសៗគ្នា គឺតំណាងឲ្យកងទ័ពទាំង៨ទិសដែលមានពណ៌ទង់សំគាល់ខុសៗគ្នា ហើយក៏បង្ហាញពីការឯកភាពនៃកម្លាំងពលរដ្ឋ ទោះបីជាមានជំនឿ ឬពណ៌សម្បុរខុសគ្នា ក៏អាចរស់នៅជាមួយគ្នាបានដែរឲ្យតែចេះគោរពអត់ឱនឲ្យគ្នាទៅវិញទៅមកនិងតម្កល់ផលប្រយោជន៍ជាតិជាធំ។ ក្នុងន័យម្យ៉ាងទៀត ព្រះភក្ត្រដែលមានពណ៌ខុសៗគ្នាទាំងនេះ អាចសបញ្ជាក់អំពីអត្តចរិកល្អនិងអាក្រក់របស់មនុស្ស និងអាចបង្ហាញពីភាពខ្លាំងដែលអាចទប់ស្កាត់នូវរាល់អំពើអយុត្តិធម៌នៅក្នុងសង្គម។ សន្តិភាព ការសណ្ដោស ប្រណីនិងក្ដីសង្ឃឹម អាចបញ្ឈប់នូវរាល់ទម្រង់នៃភាពស្អប់ខ្ពើម អំពើហិង្សា និងភាពភ័យខ្លាច។ បដិមានេះក៏តំណាងឲ្យអ្នកដែលមានអំណាចខ្លាំងក្លា តែប្រកាន់បាននូវសុចរិតយុត្តិធម៌ មិនបំពានឬដើរធ្វើបាបអ្នកដទៃ។ សរុបមកបដិមានេះបង្ហាញថា«ការគោរពនិងអត់ឱនឲ្យគ្នា នាំមកនូវសាមគ្គីជាតិ ឯកភាពជាតិនាំមកនូវអំណាចរឹងមាំ អំណាចសុចរិតនាំមកនូវសន្តិភាព ហើយភាពសុខសាន្តនាំមកនូវវិឌ្ឍនភាព»។ ជាក់ស្តែងការយកមនុស្សពីទិសទាំង៨ មកដាក់ក្នុងរាងកាយតែមួយបានធ្វើឲ្យបុព្វបុរសខ្មែរកសាងបាននូវអារ្យធម៌អង្គរដ៏ល្អអស្ចារ្យសម្រាប់មនុស្សជាតិ ហើយការបំបែកមនុស្សចេញពីរាងកាយតាមរយៈពណ៌សម្បុរបានធ្វើឲ្យសង្គមខ្មែរធ្លាក់ក្នុងភាពខ្មៅងងឹតបំផុតនៃប្រវត្តិសាស្ត្រមនុស្សជាតិ គឺរបបប្រល័យពូជសាសន៍ឯងខ្មែរក្រហម។

ប្រវត្តិសាស្ត្របានបញ្ជាក់ថា គ្មានសង្គមណាមួយអាចគេចផុតពីអំពើអមនុស្សធម៌ដ៏លហួសហេតុបានឡើយ។ អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ហួសប្រមាណអាចកើតមានឡើងវិញ។ ជួនកាលអំពើទាំងនេះអាចកើតមានឡើងជាបន្តបន្ទាប់នៅក្នុងសង្គមដែលប្រកបដោយសមិទ្ធផលខ្ពស់ក្នុងវិស័យសិល្បៈ វិទ្យាសាស្ត្រ និងការសិក្សា។ ក្នុងន័យនេះ យើងអាចនិយាយបានថាកម្រិតនៃការយល់ដឹងអំពីវប្បធម៌ ការអប់រំ ឬការពលីជីវិត ដើម្បីសម្រេចបានគោលដៅខ្ពស់ណាមួយ ពុំអាចការពារមនុស្សជាតិពីទំនោរនៃការបំផ្លាញទាំងអស់នេះបានឡើយ។ ទីបំផុត មនុស្សជាតិត្រូវប្រឈមនឹងភាពស្មុគស្មាញនៃស្ថានភាពរបស់ខ្លួន។ សាសនា វិទ្យាសាស្ត្រ និងទស្សនវិជ្ជា ផ្តល់នូវគោលគំនិតសម្រាប់បំណោះដឹង។ ប៉ុន្តែដូចគ្នាទៅនឹងរូបអ្នកតាព្រះភក្ត្រ៨ទិសដែរ សមាសធាតុទាំងនេះគឺជាធាតុផ្សំសម្រាប់បំពេញបន្ថែមចំពោះការយល់ឃើញអំពីប្រទេសនិងពិភពលោករបស់យើង ទោះបីជាធាតុផ្សំទាំងនេះមិនគ្រប់ជ្រុងជ្រោយយ៉ាងណាក៏ដោយ។ ការតស៊ូដើម្បីបញ្ឈប់ស្ថានភាពខាងលើ ត្រូវតែជាឆន្ទៈដ៏មុះមុតរបស់មនុស្សជាតិនៅក្នុងសតវត្សរ៍ទី២១នេះ។ ដូចគ្នានេះដែរ អ្នកកសាងរូបតំណាង យល់ឃើញថានៅពេលដែលមនុស្សមានជំនឿថាខ្លួនអាចទប់ស្កាត់អំពើអមនុស្សធម៌នានាបាន នោះទំនុកចិត្តនឹងកើតមានឡើងកាន់តែខ្លាំង ហើយភាពក្លាហានក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើទាំងនោះ ក៏ត្រូវបានផុសឡើងកាន់តែខ្ពស់ក្នុងការការពារអនាគតប្រទេសជាតិដោយគ្មានអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល។

អត្ថបទ៖ ផេង ពង្សរ៉ាស៊ី

# មាតិកា

**សេចក្តីថ្លែងអំណរគុណ**
មេធាវី គ្រិស្តហ្វ័រ ឡៀរីង ........ ៤

**បុព្វកថា**
លោក ឆាំង យុ, នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ........ ៥

**សេចក្តីផ្តើម**
មេធាវី គ្រិស្តហ្វ័រ ឡៀរីង ........ ៧

**ប្រធានបទសិក្សាអំពីការស្អប់ខ្ពើម ការមិនអត់ឱន និងការសម្លាប់រង្គាល នៅក្នុងប្រវត្តិសាស្ត្រពិភពលោក**
បណ្ឌិត ជា ផល្លា និងមេធាវី គ្រិស្តហ្វ័រ ឡៀរីង ........ ៨

**ប្រទេសអាល្លឺម៉ង់**
បេក្ខភាពបណ្ឌិត ស្វ ហ្វារីណា ........ ១៣

**ប្រទេសកម្ពុជា**
បេក្ខភាពបណ្ឌិត ស្វ ហ្វារីណា និងមេធាវី គ្រិស្តហ្វ័រ ឡៀរីង ........ ២៧

**ប្រទេស បូស្ន៊ី-ហឺហ្ស៊ីហ្គោវីន**
បណ្ឌិត លី សុខឃាង ........ ៤៧

**ប្រទេសរវ៉ាន់ដា**
បណ្ឌិត លី សុខឃាង ........ ៥៩

**សំណួរដែលមានចម្លើយខ្លីសម្រាប់មេរៀនលម្អិត** ........ ៧៣

**បញ្ជីឯកសារពិគ្រោះ** ........ ៧៩

# សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះពុំអាចចេញជារូបរាងបានឡើយ ប្រសិនបើគ្មានការគាំទ្រ ជំនួយ និងការលើកទឹកចិត្តដ៏ស្មោះស្ម័គ្រពីសំណាក់បុគ្គល និងស្ថាប័ន ដែលប្តេជ្ញាចិត្តដើម្បីបុព្វហេតុនៃការអប់រំពីអំពើប្រល័យពូជសាសន៍។ អ្នកនិពន្ធទាំងអស់សូមថ្លែងអំណរគុណចំពោះការគាំទ្រដ៏សប្បុរសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការគ្រប់គ្រង និងគាំទ្រការសិក្សាស្រាវជ្រាវនេះ។ អ្នកនិពន្ធសូមថ្លែងអំណរគុណ ដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ចំពោះការចូលរួមចំណែកយ៉ាងសប្បុរស និងបានផ្តល់ជំនួយដ៏ចម្បងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកនិពន្ធសូមថ្លែងអំណរគុណជាអនេកដល់ បណ្ឌិត អាឡិបសាន់ឌឺ ហ៊ីនតុន, សាស្ត្រាចារ្យ ម៉ាគើស ហ្ស៊ីមម័រ, បណ្ឌិត មីលតុន អូរស្ប៊ូន, ព្រះរាជអាជ្ញា នីកូឡាស កូមជាន, អ្នកស្រាវជ្រាវ នីស្សា ផេថេល និងអ្នកគ្រូ ខែលលី វ៉ាត់សុន ដែលបានរួមចំណែកផ្តល់មតិយោបល់ និងការកែតម្រូវដ៏មានតម្លៃលើកិច្ចការនេះ។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ប្រវត្តិវិទូ ដេវីដ ឆេនល័រ ដែលបានចំណាយពេលវេលាពេញមួយជីវិតរបស់លោកក្នុងកិច្ចការស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា និងជំរុញឲ្យមានការអប់រំពីប្រវត្តិសាស្ត្រនេះដល់មនុស្សជំនាន់ក្រោយ។ សំណៅព្រាងដំបូងនៃសៀវភៅនេះ ត្រូវបានធ្វើបទបង្ហាញនិងពិភាក្សានៅក្នុងវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យឧត្តមសិក្សាចំនួន ៥០រូប ស្តីពី "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំយុវជននិងកីឡា ក្នុងឆ្នាំ២០១៩។ ទន្ទឹមនឹងនេះដែរ អ្នកនិពន្ធសូមសម្តែងអំណរគុណដល់សាស្ត្រាចារ្យដែលបានអញ្ជើញមកពីបណ្តាសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា ចំពោះមតិយោបល់ដើម្បីស្ថាបនាលើសំណៅព្រាង។ អ្នកនិពន្ធសូមអរគុណចំពោះ ផេង ពង្សរ៉ាស៊ី និង សុភ័ក្ត្រ ភាណា ដែលបានបកប្រែសៀវភៅនេះជាភាសាខ្មែរ។ ទន្ទឹមនឹងនេះដែរ អ្នកនិពន្ធក៏សូមអរគុណដល់លោកស្រី លី សេនសូនីឡា ដែលជាអ្នករចនាសៀវភៅចំពោះភាពអត់ធ្មត់និងជំនួយដ៏ស្វាហាប់របស់លោកស្រី ក្នុងការរចនានិងការរៀបចំរូបភាព និងក្រាហ្វិកសម្រាប់សៀវភៅនេះ។ ជាចុងក្រោយបង្អស់ យើងខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តជំរុញកិច្ចការស្រាវជ្រាវ និងការអប់រំអំពីសោកនាដកម្មដែលបានកើតមានក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

# បុព្វកថា

យើងអាចនិយាយបានថា លទ្ធិប្រជាធិបតេយ្យគឺជាកម្លាំងដែលមិនចេះបុះញ៉មនៅក្នុងប្រវត្តិសាស្ត្រ។ ក្នុងនាមសេរីភាព និងសមភាព លទ្ធិប្រជាធិបតេយ្យលើកកម្ពស់ដល់សម្លេងរបស់មនុស្សប្រុសស្រី និងបំបែកប្រព័ន្ធនយោបាយបែបឋានានុក្រម។ ដូចគ្នាទៅនឹងលទ្ធិប្រជាធិបតេយ្យដែរ ការអប់រំនាំមកនូវសក្តានុពលប្រកបដោយថាមពលក្នុងការកែប្រែសង្គម។ ការអប់រំដែលផ្តោតលើការត្រិះរិះពិចារណា ការឆ្លុះបញ្ចាំងអំពីខ្លួនឯង និងសេចក្តីអាណិតអាសូរ អាចបង្កើតជាផ្នត់គំនិតថ្មីៗជាលក្ខណៈបុគ្គល និងជារួម ដើម្បីបង្ហាញពីការយល់ឃើញ និងផ្តល់ដល់មនុស្សនូវឧបករណ៍ក្នុងការចោទសួរខ្លួនឯង ស្ថាប័ន និងពិភពលោក។ ដូចគ្នាទៅនឹងលទ្ធិប្រជាធិបតេយ្យដែរ ការអប់រំក៏អាចជាអំណាចដ៏វិសេសវិសាលរបស់មនុស្សជាតិក្នុងការសម្រេចបាននូវសន្តិភាព សេរីភាព និង យុត្តិធម៌។

ការសិក្សាអំពីប្រវត្តិសាស្ត្រ គឺជាសមាសធាតុសំខាន់សម្រាប់ចក្ខុវិស័យនៃការអប់រំ។ ប្រវត្តិសាស្ត្រអាចត្រូវបានសិក្សាដើម្បីបណ្តុះការយល់ដឹង និងឆ្លុះបញ្ចាំងប្រកបដោយការត្រិះរិះពិចារណា តាមរយៈគំនិតពីអតីតកាល ពីមនុស្ស និងពីស្ថាប័ន។ ប្រវត្តិសាស្ត្រអាចជាមូលដ្ឋានគ្រឹះនៃក្តីសង្ឃឹម ការលើកទឹកចិត្ត និងការសណ្តោសប្រណី។ ទន្ទឹមនឹងនេះដែរ ប្រវត្តិសាស្ត្រក៏អាចត្រូវបានប្រើប្រាស់ជាសម្ភារសម្រាប់ការអប់រំ ដើម្បីពន្យល់អំពីកំហុស គុណវិបត្តិ និងអំពើខុសឆ្គងនៅក្នុងសង្គម ។ ប្រវត្តិសាស្ត្រ ជំរុញឲ្យសង្គមទទួលស្គាល់ទុក្ខវេទនាដែលបង្កឡើងដោយសាសនា វប្បធម៌ និងប្រទេសជាតិ។ ប្រវត្តិសាស្ត្រ ជំរុញឲ្យបុគ្គលហ៊ានប្រឈមមុខនឹងភាពភ័យខ្លាចដែលកើតមានឡើងនៅក្នុងសង្គម ។

ដោយសារតែអំណាចដ៏មហិមានៃប្រវត្តិសាស្ត្រក្នុងការបង្កើតអត្តសញ្ញាណ វប្បធម៌ និងចក្ខុវិស័យបែបសហសម័យ យើងត្រូវតែធ្វើឲ្យការសិក្សាអំពីប្រវត្តិសាស្ត្រប្រែទៅជាសមាសធាតុដ៏មានសារៈសំខាន់សម្រាប់យុទ្ធសាស្ត្រជាសកលក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។

ទោះបីជាបញ្ហាជាសកលតម្រូវឲ្យមានយុទ្ធសាស្ត្រជាសកលក្នុងការដោះស្រាយយ៉ាងណាក៏ដោយ ក៏យុទ្ធសាស្ត្រទាំងនេះត្រូវពឹងផ្អែកលើការចូលរួមពីថ្នាក់មូលដ្ឋានដែលមិនអាចខ្វះបានទាល់តែសោះ។

យុទ្ធសាស្ត្រជាសកលនានា ដែលត្រូវបានប្រើប្រាស់សម្រាប់បង្ការនិងទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺពិតជាចាំបាច់ក្នុងការកំណត់លក្ខខណ្ឌនិងឱកាសទូទៅសម្រាប់កិច្ចសហប្រតិបត្តិការនិងការធ្វើការរួមគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែពិភពលោកនៅក្នុងយុគសម័យសកលភាវូបនីយកម្មក្តីក៏រាល់បញ្ហានិងដំណោះស្រាយទាំងអស់ត្រូវកើតចេញពីការផ្តួចផ្តើមនៅតាមបណ្តាភូមិឃុំ។ ប្រសិនបើយើងទទួលស្គាល់ថាមនុស្សគ្រប់រូបមានសក្តានុពលដើម្បីផ្លាស់ប្តូរ បុគ្គលនិងសហគមន៍នោះនឹងដើរតួនាទីជាផ្នែកយ៉ាងសំខាន់មួយនៃយុទ្ធសាស្ត្រសកលលោក។ ទោះជាមានធនធានប៉ុន្មានក៏ដោយ ជោគជ័យនៃយុទ្ធសាស្ត្រជាសកលនឹងអាស្រ័យទៅលើការចូលរួម ការដឹកនាំ និងភាពជាម្ចាស់ការរបស់សហគមន៍ក្នុងភូមិឃុំ។ ភាពជាម្ចាស់ការក្នុងភូមិឃុំលើយុទ្ធសាស្ត្រនានា ពុំមែនមានន័យថា សហគមន៍ក្នុងភូមិឃុំអាច ឬគួរតែដោះស្រាយបញ្ហារបស់ខ្លួនដោយខ្លួនឯងនោះទេ។ ការណែនាំផ្លូវការគាំពារ ការអប់រំ និងគោលគំនិត គឺសុទ្ធសឹងតែជាផ្នែកដ៏សំខាន់ដែលសហគមន៍អន្តរជាតិអាចចូលរួមចំណែក ដើម្បីលើក

កម្ពស់និងជួយដល់បុគ្គលក៏ដូចជាស្ថាប័នមូលដ្ឋានឲ្យចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ ប្រវត្តិសាស្ត្រ គឺមិនត្រឹមតែពឹងផ្អែកលើការផ្តល់ពេលវេលា ឬជួយមនុស្សតែប៉ុណ្ណោះទេ។ យើងត្រូវតែចំណាយធនធានលើប្រតិបត្តិការ និងសម្ភារឧបទេស ព្រោះជាគ្រូបង្រៀនល្អគឺត្រូវពឹងផ្អែកលើបរិយាកាសសិក្សាដែលមានប្រភពធនធានល្អៗគ្រប់គ្រាន់។

កម្មវិធីសិក្សាគ្រប់ជ្រុងជ្រោយស្តីពីការសម្លាប់រង្គាលផ្សេងៗនៅក្នុងប្រវត្តិសាស្ត្រ គឺជាការចូលរួមចំណែកតូចមួយចំពោះការតស៊ូកម្រិតមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ ទោះបីជាប្រទេសកម្ពុជាបានបោះជំហានយ៉ាងសំខាន់ក្នុងការបង្រៀនប្រវត្តិសាស្ត្ររបស់ខ្លួននៅតាមបណ្តាសាលារៀននិងសហគមន៍អាទិភាពយ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវសម្រេចឲ្យបាន ក្នុងការអប់រំមនុស្សជំនាន់ក្រោយពីអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ កម្មវិធីសិក្សានេះ មានគោលបំណងបំពេញចន្លោះខ្វះខាតទាំងអស់ តាមរយៈការផ្តល់ជារូបភាព និងឧទាហរណ៍នៃបទពិសោធន៍នៅក្នុងសង្គមដទៃទៀតទាក់ទងនឹងការសម្លាប់រង្គាលនានា។ កម្មវិធីសិក្សានេះ ផ្តល់ដល់អ្នកអប់រំនូវប្រភពធនធានជាច្រើន ដើម្បីបង្កើនការយល់ដឹងរបស់សិស្សអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងជំរុញឲ្យមានការពិភាក្សាដេញដោលពីបទពិសោធន៍របស់ប្រទេសកម្ពុជាជាមួយនឹងការសម្លាប់រង្គាលក្នុងប្រទេសនានា ថាតើការសម្លាប់រង្គាលទាំងអស់មានភាពដូចគ្នានិងខុសគ្នាយ៉ាងដូចម្តេចខ្លះ។

សង្គមទាំងអស់តម្រូវឲ្យមានកម្មវិធីសិក្សាដែលទាក់ទាញចំណាប់អារម្មណ៍ និងជំរុញឲ្យមានការផ្លាស់ប្តូរ ព្រោះថាគោលបំណងចម្បងនៃការអប់រំ គឺមិនត្រឹមតែបង្ហាញឲ្យឃើញពីការសិក្សារបស់សិស្សតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជជែកវែកញែកអំពីការគិតទុកជាមុន និងការស្វែងយល់អំពីព័ត៌មាននិងគំនិតថ្មីៗទៀត។ ប្រជាជនកម្ពុជាអាចអះអាងអំពីសារៈសំខាន់នៃការរិះគិតដែលជំរុញឲ្យមានការផ្លាស់ប្តូរ។ ប៉ុន្តែជាទូទៅ សកម្មភាពនិងគំនិតទាំងនេះរបស់ប្រជាជនកម្ពុជា តែងតែត្រូវបានផ្តុកទៅដោយក្តីប្រាថ្នាយ៉ាងជ្រាលជ្រៅចង់បានសន្តិសុខជាអាទិភាព មានប្រៀបជាងការជំរុញទឹកចិត្ត និងនវានុវត្តភាពទៅវិញ។ ទំនើបភាវូបនីយកម្ម និងភាពច្នៃប្រតិដ្ឋ គឺអាស្រ័យលើអ្នកដឹកនាំ ហើយយើងចាំបាច់ត្រូវតែធ្វើឲ្យប្រសើរឡើងនូវវិធី ដែលអាចលើកកម្ពស់ការពិចារណាដោយអង់អាច និងភាពប៉ិនប្រសព្វ។

កម្មវិធីសិក្សានេះគឺជាកម្មវិធីសិក្សាខ្លីមួយ ព្រោះថាជួនកាលជំហានតូចៗ ក៏អាចមានឥទ្ធិពលជាងជំហានធំៗបានដែរ។ ជាចុងក្រោយ យើងរំពឹងថាកម្មវិធីសិក្សានេះ នឹងក្លាយជាផ្នែកតូចមួយដើម្បីបំពេញបន្ថែមទៅលើសកម្មភាពផ្សេងៗសម្រាប់អភិវឌ្ឍន៍ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រដល់មនុស្សជំនាន់ក្រោយ។ គ្មានអ្វីគួរឲ្យមន្ទិលទៀតទេថា ប្រវត្តិសាស្ត្រដើរតួនាទីជាវេទិកាដ៏សំខាន់មួយសម្រាប់ឈានទៅបង្កើតវប្បធម៌មួយដែលគោរព និងការពារលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការអភិវឌ្ឍ។

**—— ឆាំង យុ ——**

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# សេចក្ដីផ្ដើម

គ្មានវិធីណាដែលសក្តិសមជាងភាពស្ងៀមស្ងាត់ទេសម្រាប់លើកប្រធានបទនៃការសម្លាប់រង្គាលមកធ្វើការពិភាក្សា។ ភាពស្ងៀមស្ងាត់ គឺជាវិធីសមស្របបំផុតតែមួយគត់ ពីព្រោះថាគ្មានពាក្យពេចន៍អ្វីដែលគ្រប់គ្រាន់ដើម្បីពិពណ៌នាពីអំពើអមនុស្សធម៌ ការប៉ះទង្គិចផ្លូវចិត្ត និងការបាត់បង់អាយុជីវិត នោះឡើយ។ គ្មានពាក្យពេចន៍ណាមួយអាចពន្យល់ឲ្យបានក្បោះក្បាយអំពីផលប៉ះពាល់ចំពោះមនុស្សជំនាន់ក្រោយ ដែលបានកើតក្រោយអំពើហិង្សានិងផលប៉ះពាល់ដ៏យូរអង្វែងនៃអំពើឃោរឃៅមកលើក្រុមគ្រួសារ សហគមន៍ និងពិភពលោកបានទេ។ នៅពេលដែលការប្រើប្រាស់ពាក្យពេចន៍ពុំអាចទទួលបានជោគជ័យ ជួនកាលភាពស្ងៀមស្ងាត់គឺជាសកម្មភាពដ៏សមស្របបំផុត។

ជាអកុសល តម្រូវការចំពោះមុខទាំងឡាយនាពេលបច្ចុប្បន្នមិនផ្ដល់ពេលវេលាដល់យើងដើម្បីធ្វើការឆ្លុះបញ្ចាំងនៅក្នុងភាពស្ងៀមស្ងាត់ឡើយ។ សព្វថ្ងៃ អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ នៅតែបន្តកើតមាននៅតាមផ្នែកជាច្រើនក្នុងពិភពលោក។ ខណៈដែលយុទ្ធសាស្ត្រក្នុងការធ្វើអន្តរាគមន៍ ការឆ្លើយតប និងការទប់ស្កាត់ ត្រូវពឹងផ្អែកលើស្ថាប័នជាតិនិងអន្តរជាតិ បុគ្គលនិងសហគមន៍ក៏ត្រូវតែចូលរួមចំណែកនៅក្នុងយុទ្ធនាការជាសកលនេះដែរ។

ទោះបីជាបុគ្គល និងសហគមន៍អាចចូលរួមចំណែកក្នុងយុទ្ធនាការនានាតាមទម្រង់ជាច្រើនយ៉ាងណាក៏ដោយ ក៏វិធីសាស្ត្រប្រកបដោយឥទ្ធិពលបំផុតដើម្បីបញ្ឈប់ការសម្លាប់រង្គាល ត្រូវតែលើកឡើងអំពីឫសគល់នៃអំពើអមនុស្សធម៌។ នៅក្នុងកម្រិតសហគមន៍ អំពើអមនុស្សធម៌កើតចេញពីការលម្អៀង ការរើសអើង និងការគាបសង្កត់។ នៅក្នុងកម្រិតបុគ្គល អំពើអមនុស្សធម៌កើតចេញពីភាពមិនអើពើ អាត្មានិយម និងភាពអវិជ្ជា។ ទោះបីជាយើងមិនអាចលុបបំបាត់កត្តាជំរុញទាំងនេះចេញពីសភាវៈរបស់មនុស្សបានយ៉ាងណាក៏ដោយ ក៏យើងអាចកាត់បន្ថយឥទ្ធិពលនៃកត្តាទាំងនេះពីសង្គម តាមរយៈការអប់រំ ការកែទម្រង់ និងការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន។

ជំពូកនីមួយៗត្រូវបានបែងចែកជាបីផ្នែក។ ផ្នែកទី១ រៀបរាប់ពីទិដ្ឋភាពប្រវត្តិសាស្ត្រជាមូលដ្ឋាន រួមជាមួយនឹងសំណួរដែលមាននៅក្នុងផ្នែក "ពិនិត្យមើលសំណួរមួយចំនួនដែលទាក់ទងនឹងមេរៀន"។ សេចក្ដីសង្ខេបខ្លីៗអាចផ្ដល់ជាវិធីសាស្ត្រដល់គ្រូបង្រៀន ក្នុងការបង្រៀនសិស្សអំពីប្រវត្តិសាស្ត្រដែលពាក់ព័ន្ធ ក្នុងរយៈពេលតិចជាង១ម៉ោង។ ផ្នែកទី២ អធិប្បាយអំពីទិដ្ឋភាពប្រវត្តិសាស្ត្រលម្អិតជាងមុន រួមជាមួយនឹងសំណួរពិភាក្សាទម្រង់បើកចំហរ។ ចំពោះគ្រូបង្រៀនដែលមានពេលវេលាច្រើន គឺអាចចាត់ឲ្យសិស្សឆ្លើយទៅនឹងសំណួរពិភាក្សាទាំងនេះ តាមរយៈការប្រៀបធៀបជំពូកផ្សេងៗគ្នានៅក្នុងប្រវត្តិសាស្ត្រ។ ផ្នែកទី៣ បង្ហាញពីបញ្ជីសំណួរពីមុនៗ រួមជាមួយនឹងចម្លើយដែលសមស្រប។

# ប្រធានបទសិក្សាអំពីការស្អប់ខ្ពើម ការមិនអត់ឱន និងការសម្លាប់រង្គាល នៅក្នុងប្រវត្តិសាស្ត្រពិភពលោក

បណ្ឌិត ជា ផល្លា និង មេធាវី គ្រីស្តូហ្វ័រ ឌៀរីង

"ការអត់ឱន គឺជាការគោរព ការទទួលយក និងការផ្តល់តម្លៃចំពោះវប្បធម៌ផ្សេងៗគ្នាក្នុងពិភពលោក តាមទម្រង់នៃការបញ្ចេញមតិ និងអំពើមនុស្សធម៌។ " - សេចក្តីថ្លែងការណ៍របស់អង្គការយូណេស្កូស្តីពីគោលការណ៍នៃការអត់ឱន។ ⁽¹⁾

ផ្នែកខាងក្រោមគឺជាករណីសិក្សាអំពីប្រទេស អាល្លឺម៉ង់ កម្ពុជា បូស្នី-ហឺហ្សេហ្គោវីន និង រវ៉ាន់ដា នឹងបង្ហាញអំពីឧទាហរណ៍នៃការស្អប់ខ្ពើម និងការមិនអត់ឱនរបស់មនុស្សដែលអាចបង្កទៅជាអំពើអមនុស្សធម៌នឹកស្មានមិនដល់។ មុននឹងចូលដល់ការពិភាក្សាអំពីឧទាហរណ៍ទាំងនេះ យើងចាំបាច់គួរបញ្ជាក់អំពីមូលដ្ឋានគ្រឹះនៃការជ្រើសយកករណីសិក្សាអំពីប្រទេសខាងលើមកដាក់បញ្ចូលទៅក្នុងសៀវភៅសិក្សានេះ។

ឧទាហរណ៍ដែលនឹងលើកយកមកសិក្សា គឺពុំមានចេតនាតំណាងឲ្យឬសង្ខេបអំពីវិសាលគមន៍នៃអំពើអមនុស្សធម៌ដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រទេ ហើយក៏មិនត្រូវបានចាត់ទុកជាជាករណីសិក្សាដ៏សំខាន់បំផុតស្តីពីការស្អប់ខ្ពើម និងការមិនអត់ឱនគ្នាសម្រាប់ថ្នាក់រៀននៅក្នុងប្រទេសកម្ពុជាដែរ។

ក្រៅពីផ្នែកពាក់ព័ន្ធស្តីពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា អ្នកនិពន្ធមិនបានអះអាងថា ករណីសិក្សាទាំងអស់នៅក្នុងសៀវភៅនេះ គឺជាករណីសិក្សាដែលសមស្របបំផុតស្តីពីបទពិសោធន៍របស់កម្ពុជាទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងការរំលោភបំពានសិទ្ធិមនុស្សឡើយ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងយល់និងផ្តល់យុទ្ធសាស្ត្រទប់ស្កាត់និងឆ្លើយតបដ៏ល្អប្រសើរ អ្នកជំនាញមានបំណងចាត់ថ្នាក់និងបែងចែកប្រភេទនៃជម្លោះនិងអំពើអមនុស្សធម៌ តាមរយៈការវិភាគរីកញ្រែកដែលរាប់ចាប់តាំងពីចិត្តវិទ្យារហូតដល់រចនាសម្ព័ន្ធជាក់លាក់។ តាមរយៈគោលគំនិតរួមករណីផ្សេងៗនៃការសម្លាប់រង្គាល កើតឡើងដោយសារតែកត្តាជាតិពន្ធុនិងពូជសាសន៍ ខណៈដែលអំពើឧក្រិដ្ឋកម្មដទៃទៀតអាចត្រូវបានចាត់ទុកថាមានលក្ខណៈនយោបាយ។ ក្រៅពីធ្វើការកំណត់គោលដៅលើក្រុមសាសនានិង

---

⁽¹⁾ សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (យូណេស្កូ) ស្តីពីគោលការណ៍នៃការអត់ឱន SHS-96/WS-5 ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ មាត្រាទី១.១ http://unesdoc.unesco.org/ images/0015/ 001518/151830eo.pdf

ជាតិពន្ធណាមួយដែលមិនប្រតិបត្តិតាម ឬមិនសមស្របជាមួយនឹងចក្ខុវិស័យផ្រិលនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួន បំណុចដែលខុសប្លែកពីករណីសិក្សាដែលបានលើកឡើងនៅក្នុងសៀវភៅនេះ គឺខ្មែរក្រហមកំណត់ក្រុមគោលដៅដោយផ្អែកលើភាពអត្តសញ្ញាណនិងរបៀបវារៈនយោបាយ។

អ្នកនិពន្ធបានជ្រើសរើសជំពូកដាច់ដោយឡែកនីមួយៗក្នុងប្រវត្តិសាស្ត្រ ព្រោះថាជំពូកទាំងនោះមានលក្ខណៈសមស្របទៅនឹងយុវវ័យកម្ពុជា ក៏ដូចជាអ្នកអប់រំជាច្រើនទៀតដែលអ្នកនិពន្ធបានជួបក្នុងរយៈពេលជាង១០ឆ្នាំនៃការអប់រំពីអំពើប្រល័យពូជសាសន៍នៅតាមបណ្តាវិទ្យាល័យ និងសាកលវិទ្យាល័យនានាទូទាំងប្រទេសកម្ពុជា។ ស្របពេលដែលអ្នកនិពន្ធពិនិត្យពិចារណាលើឧទាហរណ៍នៅក្នុងប្រវត្តិសាស្ត្រដទៃទៀត ភាពងាយស្រួល និងការស្គាល់ច្បាស់អំពីស្ថានភាពនៅមូលដ្ឋានចំពោះជំពូកប្រវត្តិសាស្ត្រទាំងនេះ ពិតជាមានសារៈសំខាន់ជាងកត្តាដទៃទៀត។

ជាចុងក្រោយ កម្មវត្ថុចម្បងនៃកម្មវិធីសិក្សានេះគឺដើម្បីផ្តល់នូវសម្ភារឧបទេសសម្រាប់ការអប់រំអំពីការស្អប់ខ្ពើម និងការមិនអត់ឱនគ្នា ដែលជាចំណុចរួមនៃជំពូកនីមួយៗស្តីពីការសម្លាប់រង្គាលនិងអំពើអមនុស្សធម៌។ តាមរយៈប្រវត្តិសាស្ត្រ មនុស្សបានក្លាយទៅជាជនរងគ្រោះ ដោយសារតែការស្អប់ខ្ពើម និងការមិនអត់ឱនគ្នាចំពោះពូជសាសន៍ ជាតិពន្ធ សាសនា ដើមកំណើតនៃជាតិសាសន៍ ពណ៌សម្បុរ ភេទ ឋានៈសង្គម ពិការភាព មនោគមន៍វិជ្ជានយោបាយ និងទំនាក់ទំនងផ្លូវភេទ។

តើយើងអាចប្រឆាំងនឹងការស្អប់ខ្ពើម និងការមិនអត់ឱនគ្នាបានយ៉ាងដូចម្តេច? ជាតិ សហគមន៍ និងបុគ្គល អាចចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងការស្អប់ខ្ពើមនិងការមិនអត់ឱនគ្នា តាមរយៈការចាត់វិធានការនៅក្នុងវិស័យមួយចំនួនដូចជា (១) ច្បាប់, (២) ការអប់រំ, (៣) ការទទួលបានព័ត៌មាន, (៤) ការយល់ដឹងកម្រិតបុគ្គល និង(៥)ដំណោះស្រាយមូលដ្ឋាន។[២]

វិស័យទាំងនេះ ប្រសិនបើស្ថិតនៅដាច់ដោយឡែកពីគ្នា គឺមិនអាចទប់ស្កាត់ការស្អប់ខ្ពើមនិងការមិនអត់ឱនគ្នាបានទេ ព្រោះថាការស្អប់ខ្ពើមនិងការមិនអត់ឱនគ្នា មិនមែនជាកត្តាតែមួយគត់ ដែលបង្កជាការសម្លាប់រង្គាលអំពើប្រល័យពូជសាសន៍ ឬអំពើហិង្សានោះឡើយ។ បរិបទជុំវិញមានតួនាទីយ៉ាងសំខាន់។ ចំណែកកម្រិតដែលសង្គមមួយអាចរារាំងអំពើហិង្សា ឬហានិភ័យដែលសង្គមនោះអាចធ្លាក់ទៅក្នុងអំពើហិង្សា គឺមិនត្រឹមតែជះឥទ្ធិពលលើសកម្មភាពដែលបានធ្វើឡើងនៅក្នុងវិស័យទាំងនេះតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជះឥទ្ធិពលលើកត្តាវប្បធម៌ នយោបាយ និងសង្គមសេដ្ឋកិច្ចនៃរយៈកាលនោះទៀតផង។

ប្រវត្តិសាស្ត្រ បង្ហាញពីឱកាសក្នុងការស្វែងយល់អំពីអ្វីដែលកត្តាទាំងនេះអាចកើតមានឡើង។ ចាប់តាំងពីការវាយប្រហាររបស់កងកម្លាំងយោធាសែ៊បមកលើសហគមន៍មូស្លីមនៅបូស្ន៊ី រហូតដល់ការបង្កើតឲ្យមាន "ដំណោះស្រាយចុងក្រោយ" នៃលទ្ធិណាហ្ស៊ីរបស់អាល្លឺម៉ង់ អ្នកអាននឹងកត់សម្គាល់ថារាល់ការសម្លាប់រង្គាលទាំងអស់ គឺត្រូវបានប្រព្រឹត្តឡើងដោយមានគម្រោងជាក់លាក់ ក្នុងនោះការស្អប់ខ្ពើមនិងការមិនអត់ឱនគ្នា គឺមិនត្រឹមតែបានកើតមានឡើងនៅក្នុងកម្រិតស្ថាប័នតែប៉ុណ្ណោះទេ ប៉ុន្តែទង្វើនេះថែមទាំងបានរីករាលដាលទៅក្នុងគោលនយោបាយ និងប្រព័ន្ធដែលរៀបរៀងឡើងជាពិសេសដើម្បីបំផ្លាញជីវិតមនុស្ស។

ប្រសិនបើមានមេរៀនដាច់ដោយឡែកណាមួយនៅក្នុងសៀវភៅនេះ មានភាពលេចធ្លោជាងគេ នោះអាចជាការអង្កេតរបស់បុគ្គល ដែលបង្ហាញឲ្យឃើញពីការទទួលខុសត្រូវផ្នែកសីលធម៌ចំពោះជនរួមជាតិជាបុរសនិងស្ត្រីរបស់ខ្លួន។ ការទទួលខុសត្រូវផ្នែកសីលធម៌នេះ បានជ្រាបចូលទៅក្នុងទម្លាប់ប្រចាំថ្ងៃ និងទំនាក់ទំនងនៅក្នុងសហគមន៍របស់បុគ្គល។ បុគ្គលគ្រប់រូប អាចចូលរួមក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ តាមរយៈការរកឲ្យឃើញ ការស្វែងយល់ និងការឆ្លើយតបចំពោះការស្អប់ខ្ពើម និងការមិនអត់ឱនគ្នា ទៅតាមសមត្ថភាព ឬកាលៈទេសៈរបស់ខ្លួន។ ការចំណាយពេលវេលាដើម្បីយល់ដឹងថា តើការស្អប់ខ្ពើមនិងការមិនអត់ឱនគ្នា អាចជំរុញឲ្យកើតមានអំពើអមនុស្សធម៌ក្នុងអតីតកាលបានយ៉ាងដូចម្តេច គឺជាជំហានដំបូងបង្អស់ដែលបុគ្គលអាចចូលរួមចំណែកនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើអមនុស្សធម៌នាពេលបច្ចុប្បន្ននិងអនាគត។

---

[២] គោលនយោបាយរបស់អង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (យូណេស្កូ) “រៀនរស់នៅជាមួយគ្នា៖ លើកកម្ពស់ការអត់ឱនឲ្យគ្នា” http://www.unesco.org/new/en/social-and-human-sciences/themes/fight-against-discrimination/promoting-tolerance/



# ការសម្លាប់រង្គាលនៅក្នុង ប្រវត្តិសាស្ត្រពិភពលោក

ប្រទេសអាល្លឺម៉ង់

ប្រទេសកម្ពុជា

ប្រទេសបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន

ប្រទេសរវ៉ាន់ដា



រណ្តៅសាកសពរួមនៅឯជំរំឃុំឃាំងនៅ ប៊ែលហ្គិន-ប៊ែលសិន។ ប៊ែលហ្គិន-ប៊ែលសិនត្រូវបានបង្កើតឡើងនៅក្នុងខែមីនា ឆ្នាំ១៩៤៣ ដែលជាជំរំពិសេស សម្រាប់ជនជាតិជ្វីហ្វនៃរដ្ឋមានជម្លោះនិងរដ្ឋអព្យាក្រឹត្យ។ អ្នកទាំងនោះ ត្រូវបានប្រើប្រាស់ជាថ្នូរជាមួយនឹងជនជាតិអាល្លឺម៉ង់ ដែលហាត់ការនៅបរទេស។ កម្មសិទ្ធិរូបភាពរបស់សារមន្ទីររំឮកពីអំពើហួទ្បូខសសហរដ្ឋអាមេរិក។ រូបភាពនេះជាអំណោយរបស់ អាណុល ប៊ែរ បារ៉ា។

# ប្រទេសអាល្លឺម៉ង់

បេក្ខភាពបណ្ឌិត សូ ហ្វារីណា

មេរៀនសង្ខេប

ជីវិតប្រចាំថ្ងៃនៅក្នុងជំរំឃុំឃាំងមានសភាពពិបាកណាស់។ អ្នកទោសរស់នៅក្នុងជំរំត្រូវធ្វើការធ្ងន់ធ្ងរទាំងខាងក្នុងនិងខាងក្រៅជំរំ។ អ្នកទោសទទួលបានរបបអាហារពេលសម្រាក ឬការការពារខ្លួនពីអាកាសធាតុត្រជាក់បានតិចតួចណាស់។ ជំងឺនិងការឆ្លងជំងឺតែងតែកើតមានឡើង។ មនុស្សជាច្រើនបានបាត់បង់ជីវិតដោយសារតែធ្វើការហួសកម្លាំង ភាពអត់ឃ្លាន និងជំងឺ។

ភាពបរាជ័យរបស់ប្រទេសអាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទី១ គួបផ្សំនឹងសម្ពាធសេដ្ឋកិច្ចផង បានបណ្តាលឲ្យជនជាតិអាល្លឺម៉ង់បោះឆ្នោតជ្រើសរើសគណបក្សនយោបាយជាតិនិយមប្រកាន់ស្តាំមួយ គឺគណបក្សជាតិនិយមនិងសង្គមនិយមពលករអាល្លឺម៉ង់ ដែលត្រូវបានស្គាល់ជាទូទៅថាជាគណបក្សណាហ្ស៊ី ដឹកនាំដោយអាដុលហ្វ៍ ហ៊ីត្លែរ។ មេដឹកនាំណាហ្ស៊ីបានអនុវត្តទ្រឹស្តីពូជសាសន៍ផ្តាច់ការនិងមិនមានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីបង្រួបបង្រួមប្រជាជននៅក្រោមមនោគមន៍វិជ្ជាមួយ ដែលជំរុញឲ្យមានបន្សុទ្ធកម្មពូជសាសន៍ មោទកភាពជាតិ និងការបង្ក្រាបសត្រូវបរទេសនិងផ្ទៃក្នុងរបស់ប្រទេសអាល្លឺម៉ង់។ ស្ថិតក្រោមបដានៃបន្សុទ្ធកម្មពូជសាសន៍, សាមគ្គីភាពជាតិ និងការលើកកម្ពស់កិត្តិយសប្រទេសអាល្លឺម៉ង់ជាថ្មី គណបក្សណាហ្ស៊ីបានបង្កើតកម្មវិធីជាច្រើន ដើម្បីកម្ចាត់ក្រុមមនុស្សគោលដៅដែលបក្សបានកំណត់ថា គឺជាប្រភពនៃបញ្ហាសម្រាប់ប្រទេសអាល្លឺម៉ង់។ ជនជាតិជ្វីហ្វ ជនជាតិជីបស៊ី ក្រុមស្រឡាញ់ភេទដូចគ្នា ជនពិការ និងប្រជាជនអម្បូរស្លាវ ក៏ដូចជាក្រុមជាច្រើនទៀត ត្រូវបានកំណត់ថាជាក្រុមគោលដៅ។ មេដឹកនាំណាហ្ស៊ីក៏បានបង្កើតយុទ្ធនាការជាប្រព័ន្ធ ដោយប្រើប្រាស់ជំរំឃុំឃាំងមនុស្សដែលគ្រប់គ្រងដោយរដ្ឋ ដើម្បីលុបបំបាត់ជនជាតិជ្វីហ្វ។ ជំរំឃុំឃាំងទាំងនេះ ក៏មានឃុំឃាំងក្រុមមនុស្សផ្សេងៗទៀតដែរ រួមមាន ជនជាតិរ៉ូម៉ា(ជីបស៊ី) និងជនជាតិអម្បូរស្លាវ ដែលត្រូវបានឃាត់ខ្លួននិងប្រមូលផ្តុំនៅក្នុងដែនដីស្ថិតក្រោមការគ្រប់គ្រងរបស់ណាហ្ស៊ី។

ដោយសារតែមានការធ្វើទុក្ខបុកម្នេញទាំងនេះ អ្នកទោសបានបះបោរដោយផ្ទាល់និងដោយប្រយោល។ ការបះបោររបស់ជនជាតិជ្វីហ្វ បានធ្វើឡើងតាមរយៈការគោរពប្រណិប័តន៍ជំនឿសាសនារបស់ខ្លួន និងការកត់ត្រាកំណត់ហេតុអំពីជីវិតនៅក្នុងជំរំ។ ដើម្បីរស់រាន អ្នកទោសបានលួចម្ហូបអាហារ។ ជួនកាលអ្នកទោសបានព្យាយាមរត់ចេញពីគុក និងបានតតាំងជាមួយនឹងអ្នកយាមគុក។

របបណាហ្ស៊ី មានចេតនាធ្វើឲ្យជនជាតិជ្វីហ្វលោយសាបសូន្យពីទ្វីបអឺរ៉ុប តាមរយៈការប្រើប្រាស់ឧស្ម័នពុល ការបាញ់សម្លាប់ និងវិធីសាស្ត្រដទៃទៀត។ ចេតនានេះ បានធ្វើឡើងជាលក្ខណៈប្រព័ន្ធ និងត្រូវបានស្គាល់ថាជា "ដំណោះស្រាយចុងក្រោយ"។ ទោះបីជាដើមកំណើតនៃវិធីសាស្ត្រ "ដំណោះស្រាយចុងក្រោយ" មិនមានភាពច្បាស់លាស់យ៉ាងណាក៏ដោយ ក៏វិធីសាស្ត្រនេះគឺជាផែនការដែលមានច្រើនដំណាក់កាល និងមានគោលបំណងកម្ចាត់ចោលជនជាតិជ្វីហ្វទាំងអស់ចេញពីទ្វីបអឺរ៉ុប។ ជាផ្នែកមួយនៃផែនការនេះ អាដុលហ្វ៍ អាយខ្មាន់ មន្ត្រីជាន់ខ្ពស់នៃកងស្វ័តស្តាហ្វែលអាល្លឺម៉ង់ គឺជាអ្នកទទួលបន្ទុកនិរទេសជនជាតិអាល្លឺម៉ង់-ជ្វីហ្វ នៅក្នុងប្រទេសអាល្លឺម៉ង់ និងជនជាតិអឺរ៉ុប-ជ្វីហ្វ នៅក្នុងឧបទ្វីបអាល្លឺម៉ង់ (រួមមានប្រទេសអូទ្រីស ប៉ូឡូញ ឆេកូស្លូវ៉ាគី បារាំង ហូឡង់ ហុងគ្រី និងរុស្ស៊ី) ទៅកាន់ជំរំឃុំឃាំង និងទីតាំងសម្លាប់បែបប្រមូលផ្តុំ (មណ្ឌលសម្លាប់មនុស្ស)។

ជនជាតិជ្វីហ្វជាបុរស ស្ត្រី និងកុមារចំនួន៦លាននាក់ដែលជាប់នៅក្នុងជំរំ ឬ ស្មើនឹង២ភាគ៣ នៃប្រជាជនជ្វីហ្វទាំងអស់ក្នុងទ្វីបអឺរ៉ុបនៅមុនសង្គ្រាមលោកលើកទី២ ត្រូវបានសម្លាប់ដោយសារការអនុវត្តផែនការនេះ។

ណាហ្ស៊ី ក៏បានដាក់គោលដៅលើក្រុមមនុស្សដទៃទៀត ដែលសមស្របនឹងគោលគំនិតនៃពូជសាសន៍គោលរបស់ប្រទេស។ ជាឧទាហរណ៍ ស្ថិតក្រោមការដឹកនាំរបស់ណាហ្ស៊ី ជនពិការផ្នែកស្មារតីនិងរាងកាយ គឺជាប្រភេទមនុស្សដែលត្រូវកាត់ផ្តាច់ចេញពីព្រោះអ្នកទាំងនេះត្រូវបានចាត់ថ្នាក់ថាជាមនុស្សគ្មានប្រយោជន៍ចំពោះជាតិអាល្លឺម៉ង់ ឬជាការគំរាមកំហែងដល់បន្សុទ្ធកម្មពូជសាសន៍ ដែលណាហ្ស៊ីមានបំណងធ្វើឲ្យបានសម្រេច។ ណាហ្ស៊ី បានបញ្ជូនជនពិការទាំងនោះទៅក្នុងបន្ទប់ឧស្ម័នពុល។ ទន្ទឹមនឹងនេះ របបណាហ្ស៊ីក៏បានបង្កើតផែនការសម្លាប់ទារក និងកុមារពិការតូចៗ តាមរយៈការបញ្ចូលថ្នាំ និងការបង្អត់អាហារ។

ជនជាតិរ៉ូម៉ាឬដែលហៅម្យ៉ាងទៀតថាជាជនជាតិជីបស៊ី គឺជាក្រុមមនុស្សដទៃទៀតដែលជាក្រុមគោលដៅនៃរបបណាហ្ស៊ីដែរ។ ជនជាតិរ៉ូម៉ា គឺជាក្រុមកុលសម្ព័ន្ធពនេចរពិសេសមួយ ដែលផ្លាស់ទីពីតំបន់ ផុនចាប មកកាន់ទ្វីបអឺរ៉ុបក្នុងសតវត្សរ៍ទី៨និងទី១០។ របបណាហ្ស៊ីបានបង្ខំជនជាតិរ៉ូម៉ាជាច្រើននាក់ ឲ្យក្លាយទៅជាមនុស្សដែលពុំអាចមានកូនបាន តាមរយៈយន្តការវេជ្ជសាស្ត្រដើម្បីរារាំងការបង្កកំណើតទារក។ ជនជាតិរ៉ូម៉ា ក៏ជាគោលដៅក្នុងការឃាត់ខ្លួន ការផ្លាស់ទីដោយបង្ខំ និងការនិរទេសទៅកាន់ជំរំឃុំឃាំង។ ជារួមប្រជាជនដទៃផ្សេងទៀតចំនួនប្រមាណ៥លាននាក់ ដែលមិនមែនជាជនជាតិជ្វីហ្វ ត្រូវបានសម្លាប់នៅក្នុងអំឡុងរបបណាហ្ស៊ី។

បន្ទាប់ពីរបបណាហ្ស៊ីអាល្លឺម៉ង់បានដួលរលំនៅក្នុងឆ្នាំ១៩៤៥ សម្ព័ន្ធមិត្តដែលមានអំណាចបានបង្កើតឲ្យមានតុលាការយោធាមួយដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២។ តុលាការយោធាអន្តរជាតិនៅទីក្រុង នូរេមប៊ឺក បានសម្រេចដាក់ទោសលើបុគ្គលដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

| | |
|---|---|
| ១) | ចូរពិពណ៌នាអំពីផែនការរបស់របបណាហ្ស៊ីអាល្លឺម៉ង់ ដែលត្រូវបានហៅថាជាវិធីសាស្ត្រ "ដំណោះស្រាយចុងក្រោយ"។ |
| ២) | តើជីវិតប្រចាំថ្ងៃនៅក្នុងជំរំឃុំឃាំង មានសភាពយ៉ាងដូចម្តេច? |
| ៣) | ចូរផ្តល់ឧទាហរណ៍ខ្លះៗ អំពីក្រុមមនុស្សដែលរបបណាហ្ស៊ី កំណត់ថាជាក្រុមគោលដៅ។ |
| ៤) | ប្រសិនបើមានអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តើទង្វើប្រភេទណាខ្លះដែលចាត់ចូលជាអំពើប្រល័យពូជសាសន៍ស្ថិតនៅក្រោមអនុសញ្ញានេះ? |
| ៥) | តើប្រទេសអាល្លឺម៉ង់បានចុះចាញ់សង្គ្រាមលោកលើកទី២នៅពេលណា? |

## មេរៀនលម្អិត

ភាពបរាជ័យរបស់ប្រទេសអាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទី១ គួបផ្សំជាមួយនឹងសម្ពាធសេដ្ឋកិច្ច បានបណ្តាលឲ្យជនជាតិអាល្លឺម៉ង់បោះឆ្នោតជ្រើសរើសគណបក្សនយោបាយជាតិនិយមប្រកាន់ស្តាំមួយ គឺគណបក្សជាតិនិយម និងសង្គមនិយមពលករអាល្លឺម៉ង់ ដែលត្រូវបានស្គាល់ជាទូទៅថាជា គណបក្សណាហ្ស៊ី ដឹកនាំដោយ អាដុលហ្វ៍ ហ៊ីត្លែរ។ មេដឹកនាំណាហ្ស៊ី បានអនុវត្តទ្រឹស្តីពូជសាសន៍ផ្តាច់ការ និងមិនមានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីបង្រួបបង្រួមប្រជាជនឲ្យនៅក្រោមមនោគមន៍វិជ្ជាមួយ ដែលជំរុញឲ្យមានបន្សុទ្ធកម្មពូជសាសន៍ មោទកភាពជាតិ និងការបង្ក្រាបសត្រូវខាងក្រៅនឹងសត្រូវខាងក្នុងប្រទេសអាល្លឺម៉ង់។ ស្ថិតក្រោមបដានៃបន្សុទ្ធកម្មពូជសាសន៍ សាមគ្គីភាពជាតិ និងការស្តារកិត្តិយសរបស់ប្រទេសអាល្លឺម៉ង់ជាថ្មីឡើងវិញ គណបក្សណាហ្ស៊ីបានបង្កើតកម្មវិធីជាច្រើន ដើម្បីកម្ចាត់បោលនូវក្រុមមនុស្សគោលដៅដែលបក្សបានកំណត់ថា គឺជាប្រភពនៃបញ្ហាសម្រាប់ប្រទេសអាល្លឺម៉ង់។ ជនជាតិជ្វីហ្វ ក្រុមកាន់សាសនាហិណ្ឌូ ក្រុមស្រឡាញ់ភេទដូចគ្នា ជនពិការ និងជនជាតិអម្បូរស្លាវក៏ដូចជាក្រុមមនុស្សជាច្រើនដទៃទៀត ត្រូវបានកំណត់ថាជាក្រុមគោលដៅ។ មេដឹកនាំណាហ្ស៊ី បានបង្កើតយុទ្ធនាការជាប្រព័ន្ធដោយការប្រើប្រាស់ជំរំឃុំឃាំងដែលគ្រប់គ្រងដោយរដ្ឋ ដើម្បីបោសសម្អាតជនជាតិជ្វីហ្វ។ ប្រជាជនប្រមាណ១១លាននាក់មកពីប្រទេសជាង ២០ ត្រូវបានសម្លាប់ក្រោមផែនការនេះ។ ក្នុងចំណោមប្រជាជនទាំង ១១លាននាក់ មាន ៦លាននាក់ គឺជាជនជាតិជ្វីហ្វ។ សហគមន៍ជ្វីហ្វរាប់រយនៅក្នុងទ្វីបអឺរ៉ុបដែលមានអាយុកាលជាច្រើនសតវត្សរ៍មកហើយត្រូវបានសាបសូន្យទៅជារឿងរហូត។ បន្ទាប់ពីរបបណាហ្ស៊ីអាល្លឺម៉ង់ដួលរលំ ក្រុមសម្ព័ន្ធមិត្តដែលមានអំណាច បានបង្កើតតុលាការយោធាដើម្បីកាត់ទោសឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២។ តុលាការយោធាអន្តរជាតិប្រចាំនៅទីក្រុង នូរេមប៊ឺក បានសម្រេចដាក់ទោសលើបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ភាពបរាជ័យរបស់ប្រទេសអាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទី១ ត្រូវបានកំណត់ថាជាចំណុចចាប់ផ្តើមនៃយុគសម័យបង្កបង្កើតឲ្យមានរបបណាហ្ស៊ី និងសង្គ្រាមលោកលើកទី២។ សង្គ្រាមលោកលើកទី១បានបញ្ចប់ទៅនៅក្នុងឆ្នាំ១៩១៩ រួមជាមួយនឹងការចុះហត្ថលេខាលើអនុសញ្ញាវ៉ែរសៃ ដែលតម្រូវឲ្យប្រទេសអាល្លឺម៉ង់ចំណាយប្រាក់យ៉ាងច្រើនលើសលុបលើការចាញ់សង្គ្រាម។ ប្រទេសអាល្លឺម៉ង់បានបាត់បង់ទឹកដីគួរឲ្យកត់សម្គាល់ ព្រមទាំងត្រូវទូទាត់សំណងចំពោះការបំផ្លាញដែលបង្កឡើងដោយសង្គ្រាម។ ប្រទេសអាល្លឺម៉ង់ទទួលរងភាពអាម៉ាស់ពីការបរាជ័យរបស់ខ្លួន និងត្រូវទទួលយកលទ្ធផលវិបាកដែលមានចែងនៅក្នុងអនុសញ្ញាសន្តិភាព។

ក្រៅពីទទួលរងការប៉ះទង្គិចពីការធ្វើសំណងក្រោយសង្គ្រាមលោកលើកទី១ គឺចាប់ពីឆ្នាំ១៩២៩ ពិភពលោកបានធ្លាក់ទៅក្នុងវិបត្តិសេដ្ឋកិច្ចដ៏ធំមួយ។ វិបត្តិសេដ្ឋកិច្ចពិភពលោក ដែលជាវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ បានធ្វើឲ្យប៉ះពាល់ដល់ប្រទេសអាល្លឺម៉ង់យ៉ាងខ្លាំង ព្រមទាំងបណ្តាលឲ្យប្រជាជនអាល្លឺម៉ង់ជាច្រើនឥតមានការងារធ្វើ។ វិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរនេះ រួមផ្សំជាមួយនឹងភាពអាម៉ាស់របស់អាល្លឺម៉ង់បន្ទាប់ពីចាញ់សង្គ្រាមលោកលើកទី១ផង បានធ្វើឲ្យជនជាតិអាល្លឺម៉ង់ជាច្រើននាក់មានមន្ទិលសង្ស័យចំពោះចក្ខុវិស័យរបស់រដ្ឋាភិបាលអាល្លឺម៉ង់ ក្នុងការដឹកនាំប្រទេស។ បន្ទាប់ពីសង្គ្រាមលោកលើកទី១ ប្រទេសអាល្លឺម៉ង់បានអនុវត្តប្រព័ន្ធរដ្ឋាភិបាលនីតិប្រតិបត្តិ ដែលព្យាយាមបំពេញទៅតាមលក្ខខណ្ឌនៃអនុសញ្ញាសន្តិភាពនៃសង្គ្រាមលោកលើកទី១។ វិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរនេះបានបង្កជាផលវិបាកយ៉ាងសម្បើមដល់ប្រជាជនអាល្លឺម៉ង់។ ស្ថានភាពរួមផ្សំនឹងការព្យាយាមទាំងអស់របស់រដ្ឋាភិបាល ក្នុងការបំពេញទៅតាមលក្ខខណ្ឌរបស់អនុសញ្ញាសន្តិភាពនៃសង្គ្រាមលោកលើកទី១ បានធ្វើឲ្យប្រជាជនអាល្លឺម៉ង់យល់ឃើញថា រដ្ឋាភិបាលនីតិប្រតិបត្តិនេះមានភាពទន់ខ្សោយនិងគ្មានសមត្ថភាព។



រូបភាពជាក្រុមនៃកងស្ហ៊ុតស្តាហ្វែលអាល្លឺម៉ង់ នៅឯជំរំឃុំឃាំង ប៊ូហេនវ៉ល។ អង្គភាពស្ហ៊ុតស្តាហ្វែលអាល្លឺម៉ង់ គឺជាភ្នាក់ងារដ៏លេចធ្លោ ទទួលបន្ទុកលើសន្តិសុខ និងភាពភ័យខ្លាចនានាបង្កឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ និងផ្នែកនៃទ្វីបអឺរ៉ុបដែលគ្រប់គ្រងដោយអាល្លឺម៉ង់។ កម្មសិទ្ធិរូបភាពរបស់ សារមន្ទីរហូឡូខសសហរដ្ឋអាមេរិក។ រូបភាពនេះជាអំណោយរបស់ រ៉ូបឺត អេ. ឆ្មឺល។

អាដុលហ្វ៍ ហ៊ីត្លែរ ដែលជាអ្នកវោហាស័ព្ទដ៏មានឥទ្ធិពល បានបង្កើនអំណាចជាបណ្តើរៗតាមរយៈស្ថានការណ៍អំណោយផលអស់ទាំងនេះ។ ស្របពេលដែលសេដ្ឋកិច្ចជាតិមានវិបត្តិ និងរដ្ឋាភិបាលអសមត្ថភាពក្នុងការដឹកនាំប្រទេស ហ៊ីត្លែរ ទាក់ទាញបានអ្នកបោះឆ្នោតគាំទ្រយ៉ាងច្រើនលើសលុប តាមរយៈចក្ខុវិស័យក្នុងការបង្កើតប្រទេសអាល្លឺម៉ង់ថ្មីមួយ ដែលជំរុញឲ្យមានបន្សុទ្ធកម្មពូជសាសន៍ មោទកភាពជាតិ និងការបង្ក្រាបសត្រូវបរទេសនិងសត្រូវផ្ទៃក្នុងរបស់ប្រទេសអាល្លឺម៉ង់។ ហ៊ីត្លែរ បានសន្យាថានឹងធ្វើឲ្យប្រទេសចៀសផុតពីវិបត្តិនានា និងស្តារប្រទេសអាល្លឺម៉ង់ឲ្យ ឆ្ពោះទៅរក "ជំហរដ៏ត្រឹមត្រូវ" ក្នុងនាមជាមហាអំណាចពិភពលោកមួយ។

នាថ្ងៃទី៣០ខែមករាឆ្នាំ១៩៣៣ អាដុលហ្វ៍ ហ៊ីត្លែរ ត្រូវបានតែងតាំងជាអធិការបតីប្រទេសអាល្លឺម៉ង់។ ហ៊ីត្លែរ បានប្រកាសបញ្ឈប់លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសអាល្លឺម៉ង់ និងដឹកនាំប្រទេសតាមប្រព័ន្ធឯកបក្ស។ នៅថ្ងៃទី២៧និងទី២៨ ខែកុម្ភៈ ឆ្នាំ១៩៣៣ ហ៊ីត្លែរ បានដាក់រដ្ឋអធិបតេយ្យអាល្លឺម៉ង់ក្នុងភាពអាសន្ន។ អនុក្រឹត្យថ្មី ត្រូវបានអនុម័ត ដោយលុបចោលកថាខណ្ឌដែលចែងអំពីការការពារដល់សិទ្ធិបុគ្គលជាមូលដ្ឋាន ដែលរួមមាន សេរីភាពសារព័ត៌មាន សេរីភាពបញ្ចេញមតិ និងសេរីភាពក្នុងការប្រមូលផ្តុំ ចេញពីរដ្ឋធម្មនុញ្ញរបស់អាល្លឺម៉ង់។ អនុក្រឹត្យនេះ បានបើកទូលាយឲ្យមានអន្តរាគមន៍ផ្សេងៗពីសំណាក់រដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធទៅលើជីវិតឯកជន ដោយអនុញ្ញាតឲ្យកងកម្លាំងប្រដាប់អាវុធធ្វើការត្រួតពិនិត្យសំបុត្រចេញចូល ស្តាប់ការសន្ទនាតាមបណ្តាញទូរស័ព្ទ និងឆែកឆេរផ្ទះសម្បែងប្រជាជនដោយមិនចាំបាច់មានដីកា ឬមូលហេតុច្បាស់លាស់។ របបណាហ្ស៊ី អាចឃាត់ខ្លួននិងឃុំឃាំងមនុស្សដោយមិនចាំបាច់មានហេតុផល និងគ្មានកាលកំណត់ចំពោះការដាក់ឃុំឃាំងមនុស្សក្នុងពន្ធនាគារ។ កងកម្លាំងសន្តិសុខពិសេសរបស់របបណាហ្ស៊ី ដែលជាកងកម្លាំងប្រដាប់អាវុធសម្ងាត់ កងបំបែកខ្យល់ព្យុះ និងកងការពារបង្កើតឡើងក្នុង





ទាហានអាល្លឺម៉ង់នៃអង្គភាពវ៉ាហ្វិន-ស៊្វីតស្តាហ្វែលអាល្លឺម៉ង់ និងអង្គភាពពលកម្មរ៉េឆ មើលទៅហាក់ដូចជាសមាជិករបស់អេនហ្សាស្រ្តីបភិន បម្រុងនឹងបាញ់ជនជាតិអ៊ុយក្រែន-ជ្វីហ្វ ដែលកំពុងលុតជង្គង់នៅមាត់រណ្តៅសាកសពផ្ទុកពេញទៅដោយសាកសព។ អេនហ្សាស្រ្តីបភិន គឺជាកងពិឃាដរបស់ស៊្វីតស្តាហ្វែលអាល្លឺម៉ង់ ទទួលបន្ទុកលើការសម្លាប់រង្គាលនៅក្នុងផ្នែកនៃទ្វីបអឺរ៉ុបដែលគ្រប់គ្រងដោយអាល្លឺម៉ង់។ កម្មសិទ្ធិរូបភាពរបស់ សារមន្ទីរហូឡូខស សហរដ្ឋអាមេរិក។ រូបភាពនេះជាអំណោយរបស់ ស៊ែរ៉ុន ផាខេត។

ទសវត្សរ៍ឆ្នាំ១៩២០ ដឹកនាំដោយ ហៃនរិច ហ៊ីមល្លឺ ប្រធានកងស៊្វិតស្តាហ្វែលអាល្លឺម៉ង់ និង រេនហាដ ហាយរិច អនុប្រធានកងស៊្វិតស្តាហ្វែលអាល្លឺម៉ង់ ត្រូវបានប្រើប្រាស់ដើម្បីគំរាមកំហែងដល់ក្រុមនយោបាយប្រឆាំង (កុម្មុយនីស្ត សង្គមនិយម និងសេរីនិយម) និងដើម្បីការពារមេដឹកនាំណាហ្ស៊ី។ កងស៊្វិតស្តាហ្វែលអាល្លឺម៉ង់ គឺជាឧបករណ៍បង្កភាពភ័យខ្លាចដ៏សំខាន់បំផុតរបស់របបណាហ្ស៊ី។ មន្ត្រីនៃកងស៊្វិតស្តាហ្វែលអាល្លឺម៉ង់ បានយាមល្បាតនៅតាមជំរំឃុំឃាំង ជាទីតាំងដែលសត្រូវនៃរបបណាហ្ស៊ីត្រូវបានឃុំឃាំង។

ជំរំឃុំឃាំង គឺជាកន្លែងដ៏សំខាន់របស់របបណាហ្ស៊ីអាល្លឺម៉ង់ចាប់ពីឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៤៥។ ជំរំឃុំឃាំង សំដៅលើកន្លែងឃុំខ្លួនមនុស្សយ៉ាងតឹងរ៉ឹងបំផុត។ ជាទូទៅ អ្នកទោសស្ថិតនៅក្នុងស្ថានភាពលំបាក និងផ្ទុយពីក្រឹត្យក្រមច្បាប់ក្នុងការឃាត់ខ្លួន និងឃុំឃាំងនៃលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ។ រាល់ជំរំឃុំឃាំងទាំងអស់នៅក្នុងប្រទេសអាល្លឺម៉ង់ ឬក្រោយមកប្រែទៅជា "ប្រទេសអាល្លឺម៉ង់ដ៏មហាអស្ចារ្យ" ត្រូវបានប្រមូលផ្តុំនិងគ្រប់គ្រងដោយឧត្តមសេនីយ៍ ថេអូដ័រ អៃកឃ៍ នៃកងស៊្វិតស្តាហ្វែលអាល្លឺម៉ង់។ របបណាហ្ស៊ីបានប្រើប្រាស់អគារទាំងចាស់ទាំងថ្មី ដូចជាឃ្លាំងចាស់ៗ រោងចក្រដែលត្រូវបានបោះបង់ចោល និងអគារដទៃទៀត ធ្វើជាជំរំឃុំឃាំង។

ចក្ខុវិស័យនៃរបបណាហ្ស៊ី គឺអនុវត្តគោលនយោបាយពូជសាសន៍ផ្តាច់ការ និងគ្មានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីបង្រ្កាបបង្រ្កមមនុស្ស។ ចាប់ផ្តើមនៅក្នុងឆ្នាំ១៩៣៥ ជនជាតិជ្វីហ្វ ក៏ដូចជា ក្រុមមនុស្សដទៃទៀត ដែលមិនស្របទៅនឹងគោលគំនិតពូជសាសន៍អារីយ៉ានរបស់របបណាហ្ស៊ី ត្រូវបានទទួលរងការរើសអើងជាបន្តបន្ទាប់ពីសំណាក់រដ្ឋាភិបាលនិងសង្គម ហើយហេតុការណ៍នេះបានវិវឌ្ឍទៅកាន់ជម្លោះជាសាធារណៈ និងបានរឹបអូសយកទ្រព្យសម្បត្តិ ព្រមទាំងបានឃាត់ខ្លួន និងជម្លៀសមនុស្សទៅកាន់ជំរំឃុំឃាំង។ ហ៊ីត្លែរ និងអ្នកឯទៀតក្នុងរបបណាហ្ស៊ី បានឃោសនាបំផុសឲ្យប្រជាជនមានកំហឹង និងការភិតភ័យចំពោះក្រុមជនជាតិភាគតិច។

គោលនយោបាយនេះ គឺជាគោលនយោបាយប្រឆាំងនឹងគូបដិបក្ខ ក៏ដូចជា អ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថា "មានពូជសាសន៍អន់ថយ"។ គោលនយោបាយពូជសាសន៍បានបន្តរហូតដល់ប្រទេសអាល្លឺម៉ង់ចាញ់សង្គ្រាមនៅក្នុងឆ្នាំ១៩៤៥។ របបណាហ្ស៊ីជឿជាក់ថា ប្រជាជនអាល្លឺម៉ង់ "មានភាពឧត្ដុង្គឧត្ដមផ្នែកពូជសាសន៍" និងពិបាកក្នុងការរស់នៅជាមួយនឹងពូជសាសន៍អន់ថយជាងពូជសាសន៍របស់ខ្លួន។ ប្រជាជនអាល្លឺម៉ង់បានចាត់ទុកជនជាតិជ្វីហ្វ ជនជាតិរ៉ូម៉ា(ជីបស៊ី) និងជនពិការ ថាជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ដំណើរការបន្សុទ្ធកម្មរបស់ "ពូជសាសន៍អាល្លឺម៉ង់ (អារីយ៉ាន)" ឬហៅម្យ៉ាងទៀតថាជា "ពូជសាសន៍មេ"។ គោលនយោបាយរបស់របបណាហ្ស៊ីប្រឆាំងជនជាតិជ្វីហ្វ និងជនបរទេសដទៃទៀត បានបង្កទៅជាអំពើហូឡូខស (ឬ ការសម្លាប់រង្គាលនៅអឺរ៉ុប ដែលបកប្រែជាភាសាខ្មែរថា បូជាភ្លើង)។

ជនជាតិរ៉ូម៉ា ឬហៅម្យ៉ាងទៀតថា ជីបស៊ី គឺជាក្រុមកុលសម្ព័ន្ធពនេចរពិសេសមួយ ដែលផ្លាស់ទីពីតំបន់ផុនចាប មកកាន់ទ្វីបអឺរ៉ុបក្នុងសតវត្សរ៍ទី៨និងទី១០។ មកទល់ឆ្នាំ១៩៣៩ ជនជាតិរ៉ូម៉ា ប្រមាណជាង១លាននាក់ បានរស់នៅក្នុងទ្វីបអឺរ៉ុប ជាពិសេសអឺរ៉ុបខាងកើត។ ទោះបីជាជនជាតិរ៉ូម៉ា ធ្លាប់ទទួលរងការធ្វើទុក្ខបុកម្នេញក្នុងទ្វីបអឺរ៉ុបអស់រយៈពេលជាច្រើនសតវត្សរ៍រួចមកហើយក្ដី ការកាន់អំណាចនៃរបបណាហ្ស៊ីក្នុងប្រទេសអាល្លឺម៉ង់ បានបើកទំព័រថ្មីនៃការធ្វើទុក្ខបុកម្នេញលើជនជាតិរ៉ូម៉ាជាថ្មីម្ដងទៀត។ របបណាហ្ស៊ីបានអនុវត្តច្បាប់នូរេមប៊ឺកស្ដីពីពូជសាសន៍ ដែលជាច្បាប់ចែងអំពីការបង្ការជំងឺតំណពូជ និងជាច្បាប់ប្រឆាំងចំពោះឧក្រិដ្ឋជនប្រកបដោយគ្រោះថ្នាក់។ ជនជាតិរ៉ូម៉ាជាច្រើន ត្រូវបានបង្ខំឲ្យក្លាយទៅជាមនុស្សដែលពុំអាចបង្កកំណើតទារកបាន (យន្តការវេជ្ជសាស្ត្រដើម្បីរារាំងការបង្កកំណើត)។ ទន្ទឹមនឹងនេះ ជនជាតិរ៉ូម៉ាក៏ជាគោលដៅនៃការឃាត់ខ្លួន ការផ្លាស់ទីដោយបង្ខំ និងការបញ្ជូនទៅកាន់ជំរំឃុំឃាំង។

របបណាហ្ស៊ី បានកំណត់គោលដៅលើក្រុមមនុស្សដទៃទៀតដែលមិនស្របនឹងគោលគំនិតនៃពូជសាសន៍គោលរបស់ប្រទេស។ ជាឧទាហរណ៍ ស្ថិតក្រោមការដឹកនាំរបស់ណាហ្ស៊ី ជនពិការផ្នែកស្មារតីនិងរូបរាងកាយ គឺជាប្រភេទមនុស្សដែលត្រូវកាត់ផ្ដាច់ចេញ ព្រោះថាអ្នកទាំងនេះត្រូវបានចាត់ថ្នាក់ជាក្រុមមនុស្សដែលគ្មានប្រយោជន៍ចំពោះជាតិអាល្លឺម៉ង់ ឬជាការគំរាមកំហែងដល់ការធ្វើបន្សុទ្ធកម្មពូជសាសន៍ ដែលណាហ្ស៊ីមានបំណងធ្វើឲ្យបានសម្រេច។ ណាហ្ស៊ី បានបញ្ជូនជនពិការទាំងនោះទៅក្នុងបន្ទប់ឧស្ម័នពុល និងបានបង្កើតផែនការសម្លាប់ទារក និងកុមារពិការតូចៗតាមរយៈការបញ្ចាក់ថ្នាំ និងការបង្អត់អាហារ។

"ហូឡូខស" សំដៅលើការធ្វើទុក្ខបុកម្នេញនិងការសម្លាប់ជាលក្ខណៈប្រព័ន្ធលើជនជាតិជ្វីហ្វចំនួន៦លាននាក់ ដោយមានទម្រង់ការិយាធិបតេយ្យ និងត្រូវបានគាំទ្រពីរដ្ឋ របបណាហ្ស៊ី និងភាគីពាក់ព័ន្ធទាំងអស់។ ហូឡូខស ("ស្សូហ្វា" នៅក្នុងភាសាហេប្រ៊ូ) គឺជាពាក្យក្រិក ដែលមានន័យជាភាសាខ្មែរថា "បូជាភ្លើង"។

ប្រវត្តិសាស្ត្រនៃភាពស្អប់ខ្ពើមប្រឆាំងនឹងជនជាតិជ្វីហ្វ បានកើតមានតាំងពីយូរលង់ណាស់មកហើយ (នោះគឺការប្រឆាំងនឹងអម្បូរជនជាតិជ្វីហ្វ)។ អស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមក ជនជាតិជ្វីហ្វដែលគោរពសាសនាជ្វីហ្វជាគោល បានពង្រីកសហគមន៍ខ្លួននៅពាសពេញប្រទេសអាល្លឺម៉ង់ និងទីតាំងដទៃទៀតក្នុងទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក និងផ្នែកខ្លះនៃទ្វីបអាស៊ី។ ទន្ទឹមនឹងនេះ ជនជាតិជ្វីហ្វមួយចំនួនបានបន្តរស់នៅក្នុងតំបន់ដែលត្រូវបានស្គាល់ថាជាព្រះរាជាណាចក្រអ៊ីស្រាអែល។ រឿងព្រេងនិទាននិងការដំណាលតៗគ្នាអំពីជនជាតិជ្វីហ្វ បានបង្កជាការយល់ឃើញបែបអវិជ្ជមាន ជំនឿខុស និងការចាត់ថ្នាក់រួមទៅលើជនជាតិជ្វីហ្វ ដោយសារតែឋានៈជនជាតិភាគតិចនៃក្រុមជនជាតិនេះ។ រឿងព្រេងនិទាន និងការដំណាលតៗគ្នាទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយថ្នាក់ជាតិ។ នៅក្នុងប្រទេសអាល្លឺម៉ង់ ជនជាតិជ្វីហ្វមានចំនួនត្រឹម១ភាគរយនៃចំនួនប្រជាជនសរុបតែប៉ុណ្ណោះ ក៏ប៉ុន្ដែអ្នកទាំងនេះត្រូវបានចោទប្រកាន់ថាជាមូលហេតុបណ្ដាលឲ្យប្រទេសអាល្លឺម៉ង់ចាញ់សង្គ្រាមលោកលើកទី១។ ដូចគ្នានេះដែរ ជនជាតិជ្វីហ្វក៏ត្រូវបានស្ដីបន្ទោសចំពោះបដិវត្តន៍បុលសេវិច នៅក្នុងប្រទេសរុស្ស៊ី និងការជំរុញឲ្យសម្រេចបាននូវគោលដៅបដិវត្តន៍ពិភពលោក។ ជនជាតិជ្វីហ្វ ត្រូវបានចោទប្រកាន់ដោយគ្មានភស្ដុតាងអំពីភាពកំសាក និងមិនស្មោះត្រង់ចំពោះប្រទេសជាតិ។ ជនជាតិជ្វីហ្វ ក៏ត្រូវបានគេផ្សារភ្ជាប់ទៅនឹងភាពលោភលន់ និងពាក្យចចាមអារាមថាជនជាតិនេះគ្រប់គ្រងលើប្រព័ន្ធសំណាងដែល




បដាផ្សព្វផ្សាយបំផុសភាពស្អប់ខ្ពើមចំពោះជនជាតិជ្វីហ្វ ដែលមានចំណងជើងថា "នៅពីក្រោយអំណាចរបស់សត្រូវ៖ ជនជាតិជ្វីហ្វ។" ប្រភពរូបភាព៖ សារមន្ទីរហូឡូខសសហរដ្ឋអាមេរិក។ កែសម្រួលរូបភាពដោយ៖ ម៉ាក្ស រ៉េដ។

ដាក់មកលើប្រទេសអាល្លឺម៉ង់នៅក្រោយសង្គ្រាមលោកលើកទី១ ដើម្បីតែផលប្រយោជន៍របស់ខ្លួន។ នៅទ្វីបអឺរ៉ុបខាងលិច ជនជាតិជ្វីហ្វ តែងតែប្រឈមទៅនឹងការរឹតត្បិតលើកម្មសិទ្ធិដីធ្លី។ អ្នកទាំងនេះត្រូវបង្ខំឲ្យរស់នៅក្នុងសហគមន៍ដាច់ស្រយាល ឬ តំបន់អាណាធិបតេយ្យ។ ការបះបោរ (កម្ទេច) ប្រឆាំងនឹងជនជាតិជ្វីហ្វ បានកើតមាននៅក្នុងប្រវត្តិសាស្ត្រអឺរ៉ុប។

ប្រវត្តិសាស្ត្រនៃការវាយប្រហារនៃរបបណាហ្ស៊ី មកលើសហគមន៍ជ្វីហ្វ ត្រូវបានលេចឮចាប់តាំងពីឆ្នាំ១៩៣៣ គឺនៅពេលដែលច្បាប់ទូរេមបឺកត្រូវបានអនុម័ត។ ច្បាប់នេះបានបណ្តេញជនជាតិជ្វីហ្វ ចេញពីមុខតំណែងក្នុងសង្គមសាកលវិទ្យាល័យ និងតំណែងផ្នែកច្បាប់ ព្រមទាំងផ្នែកដទៃទៀតនៃការងារសាធារណៈ។ ច្បាប់នេះបានធ្វើឲ្យជនជាតិជ្វីហ្វ វិវត្តទៅជាប្រជាជនដែលស្ថិតក្នុងឋានៈទីពីរ។ ជនជាតិជ្វីហ្វ ត្រូវបានចាត់ថ្នាក់តាមរយៈទំនាក់ទំនងផ្នែកសាសនានៃជីដូនជីតារបស់ខ្លួន។ ជនជាតិជ្វីហ្វ ពុំអាចសិក្សានៅសាលារដ្ឋ ធ្វើដំណើរទៅកាន់រោងល្ខោន រោងភាពយន្ត រមណីយដ្ឋាន លំហែកំសាន្ត ឬសូម្បីតែរស់នៅ ឬ ដើរនៅក្បែរកន្លែងសំខាន់ៗណាមួយនៅក្នុងទីក្រុងរបស់អាល្លឺម៉ង់បានឡើយ។

នៅចន្លោះឆ្នាំ១៩៣៧ ដល់ឆ្នាំ១៩៣៩ ជនជាតិជ្វីហ្វ ត្រូវបានបណ្តេញចេញពីមុខតំណែងសេដ្ឋកិច្ចក្នុងប្រទេសអាល្លឺម៉ង់។ របបណាហ្ស៊ី បានរឹបអូសយកអាជីវកម្ម និងទ្រព្យសម្បត្តិរបស់ជនជាតិជ្វីហ្វ ឬ បានបង្ខំឲ្យជនជាតិនេះលក់ចេញអាជីវកម្មខ្លួនក្នុងតម្លៃដែលត្រូវបានផ្តល់ឲ្យដោយរដ្ឋ។ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៣៨ របបណាហ្ស៊ី បានធ្វើការបះបោរ (ការកម្ទេច) ដែលមានឈ្មោះថា គ្រីស្ទលណាចថ៍ (រាត្រីនៃកញ្ចក់បែក)។ ការវាយប្រហារប្រឆាំងនឹងជនជាតិអាល្លឺម៉ង់-ជ្វីហ្វ និងជនជាតិអូទ្រីស-ជ្វីហ្វ រួមមាន ការបំផ្លាញព្រះវិហារសាសនា និងហាងដែលជាកម្មសិទ្ធិរបស់ជនជាតិជ្វីហ្វ ការឃាត់ខ្លួនបុរសជនជាតិជ្វីហ្វ ការកម្ទេចផ្ទះសម្បែង និងការសម្លាប់។

ស្ទើរតែពាក់កណ្តាលនៃចំនួនប្រជាជនអាល្លឺម៉ង់-ជ្វីហ្វ និងច្រើនជាង២ភាគ៣នៃជនជាតិអូទ្រីស-អាល្លឺម៉ង់ បានចៀសផុតពីការធ្វើទុក្ខបុកម្នេញរបស់ណាហ្ស៊ី នៅចន្លោះឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៣៩។ អ្នកទាំងនេះបានធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិក, ប៉ាឡេស្ទីន និងទីតាំងដទៃទៀតក្នុងទ្វីបអឺរ៉ុប (ដែលក្រោយមកភាគច្រើននៃអ្នកទាំងនេះត្រូវបានឃាត់ខ្លួន តាមរយៈការគ្រប់គ្រងរបស់អាល្លឺម៉ង់នៅក្នុងអំឡុងពេលសង្គ្រាម)។ ជនជាតិជ្វីហ្វភាគច្រើនបានធ្វើអន្តោប្រវេសន៍ទៅកាន់តំបន់អាមេរិកឡាទីន និងទីក្រុងសៀងហៃ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ជប៉ុន (ដោយមិនតម្រូវឲ្យមានទិដ្ឋាការដើម្បីធ្វើអន្តោប្រវេសន៍ចូលឡើយ)។ ជនជាតិជ្វីហ្វដែលបន្តរស់នៅក្រោមការគ្រប់គ្រងរបស់របបណាហ្ស៊ី គឺជាអ្នកមិនព្រមបោះបង់ដើមកំណើតរបស់ខ្លួន ឬមិនអាចទទួលបានទិដ្ឋាការ ជំនួយឧបត្ថម្ភ ឬមូលនិធិដើម្បីធ្វើអន្តោប្រវេសន៍។ ប្រទេសភាគច្រើន រួមមានសហរដ្ឋអាមេរិក កាណាដា អង់គ្លេស និងបារាំង មិនព្រមអនុញ្ញាតឲ្យជនភៀសខ្លួនចូលទៅក្នុងប្រទេសរបស់ខ្លួនក្នុងចំនួនច្រើនទេ។



អតីតអ្នកយាមគុកបានគាស់និងកប់ម្តងទៀតនូវសាកសពដែលត្រូវបានដុតកម្ទេច នៅជំរំឃុំឃាំងឃ្លូហ្កា បន្ទាប់ពីជំរំនេះត្រូវបានរំដោះដោយសហភាពសូវៀត។ កម្មសិទ្ធិរូបភាពរបស់ សារមន្ទីរហូឡូខសសហរដ្ឋអាមេរិក។ រូបភាពនេះជាអំណោយរបស់ ហេឡេន ស៊ុំម័រ។

ការប្រឆាំងរបស់ ណាហ្ស៊ី ចំពោះជនជាតិជ្វីហ្វ បានឈានដល់ចំណុចកំពូលនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) គឺនៅពេលដែលជនជាតិអាល្លឺម៉ង់-ជ្វីហ្វ ត្រូវទទួលរងទណ្ឌកម្មខ្លាំងជាងមុន។ គោលនយោបាយពូជសាសន៍ផ្តាច់ការនិងគ្មានលក្ខណៈវិទ្យាសាស្ត្រ ត្រូវបានបង្កើតឡើងដោយមានការរួមបញ្ចូលទាំងការកាត់បន្ថយរបបអាហារ ការដាក់កំហិតលើការទិញទំនិញប្រើប្រាស់ និងការរឹតបន្តឹងការធ្វើដំណើរទៅកាន់ហាងទំនិញ ឬការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ។ ជនជាតិជ្វីហ្វ ត្រូវបានបង្ខំឲ្យប្រគល់ទ្រព្យសម្បត្តិ "ដែលចាំបាច់ដល់ការតស៊ូក្នុងពេលមានសង្គ្រាម" ឲ្យពាក់ស្លាកសញ្ញាសម្គាល់ផ្កាយពណ៌លឿងចំពោះអ្នកដែលមានអាយុលើសពី៦ឆ្នាំ និងឲ្យរស់នៅក្នុងតំបន់នៃទីក្រុងរបស់អាល្លឺម៉ង់ដែលបានកំណត់ជាទីតាំងដែលអ្នកទាំងនេះទទួលរងនូវពលកម្មដោយបង្ខំ។

នៅដើមឆ្នាំ១៩៤១ របបណាហ្ស៊ី បានចាប់ផ្តើមលុបបំបាត់សហគមន៍ជ្វីហ្វ និងបញ្ជូនជនជាតិជ្វីហ្វទៅកាន់ជំរំឃុំឃាំង។ ការវាយបំផ្លាញចោលសំណង់អាណាធិបតេយ្យរបស់ជនជាតិជ្វីហ្វ បានកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងឆ្នាំ១៩៤២ និងនៅក្នុងរយៈពេលត្រឹម២ឆ្នាំតែប៉ុណ្ណោះ (គឺមកទល់រដូវក្តៅឆ្នាំ១៩៤៤) មានសហគមន៍ជនជាតិជ្វីហ្វមួយចំនួនតូចតែប៉ុណ្ណោះដែលនៅសេសសល់ក្នុងទ្វីបអឺរ៉ុប។

របបណាហ្ស៊ីបានប្រើប្រាស់ប្រព័ន្ធផ្លូវដែកទាំងអស់ដើម្បីដឹកជញ្ជូន ឬ និរទេសជនជាតិជ្វីហ្វ ចេញពីផ្ទះសម្បែងទៅកាន់ជំរំឃុំឃាំងនៅប៉ែកខាងកើតទ្វីបអឺរ៉ុប។ នៅពេលដែលគ្មានរថភ្លើងសម្រាប់ដឹកជញ្ជូន ឬ ស្ថិតក្នុងរយៈចម្ងាយជិតៗ ជនជាតិជ្វីហ្វត្រូវបានដឹកជញ្ជូនតាមរថយន្ត ឬតម្រូវឲ្យធ្វើដំណើរដោយថ្មើរជើង។

របបណាហ្ស៊ី មានបំណងធ្វើឱ្យជនជាតិជ្វីហ្វរលាយសាបសូន្យពីទ្វីបអឺរ៉ុប តាមរយៈការប្រើប្រាស់ឧស្ម័នពុល ការបាញ់សម្លាប់ និងវិធីសាស្ត្រដទៃទៀត។ ផែនការដែលបានធ្វើឡើងជាប្រព័ន្ធនេះ ត្រូវបានស្គាល់ថាជា "ដំណោះស្រាយចុងក្រោយ"។ ទោះបីជាការបង្កើតផែនការ "ដំណោះស្រាយចុងក្រោយ" មិនមានភាពច្បាស់លាស់ក្តី ក៏កិច្ចការនេះបានធ្វើឡើងជាច្រើនដំណាក់កាលដើម្បីកម្ចាត់ជនជាតិជ្វីហ្វទាំងអស់ចេញពីទ្វីបអឺរ៉ុប។ ជាផ្នែកមួយនៃផែនការនេះ អាដុលហ្វ៍ អាយខ្មាន់ មន្ត្រីជាន់ខ្ពស់នៃកងទ័ពស្ទួតស្តាហ្វែលអាល្លឺម៉ង់ គឺជាអ្នកទទួលខុសត្រូវលើការនិរទេសជនជាតិអាល្លឺម៉ង់-ជ្វីហ្វ នៅក្នុងប្រទេសអាល្លឺម៉ង់ និងជនជាតិអឺរ៉ុប-ជ្វីហ្វ នៅក្នុងឧបទ្វីបអាល្លឺម៉ង់ (រួមមាន ប្រទេសអូទ្រីស, ប៉ូឡូញ, ឆេកូស្លូវ៉ាគី, បារាំង, ហូឡង់, ហុងគ្រី និងរុស្ស៊ី) ទៅកាន់ជំរំឃុំឃាំង និងទីតាំងសម្លាប់។

សរុបទាំងអស់ ជនជាតិជ្វីហ្វជាបុរស ស្ត្រី និងកុមារចំនួន៦លាននាក់ ឬស្មើនឹង២ភាគ៣នៃប្រជាជនជ្វីហ្វរស់នៅក្នុងទ្វីបអឺរ៉ុប មុនសង្គ្រាមលោកលើកទី២ ត្រូវបានសម្លាប់នៅក្នុងជំរំឃុំឃាំង ក្រោមផែនការរបស់ណាហ្ស៊ី។ ទន្ទឹមនឹងនេះ ប្រជាជនដែលមិនមែនជនជាតិជ្វីហ្វចំនួន៥លាននាក់ទៀត ក៏ត្រូវបានសម្លាប់ដែរ។

តាមរយៈរឿងរ៉ាវរបស់អ្នករស់រានមានជីវិត ការនិរទេសនិងការដឹកជញ្ជូនមនុស្សទៅកាន់ជំរំឃុំឃាំងគឺ ត្រូវចំណាយរយៈពេលអស់ជាច្រើនថ្ងៃ។ បុគ្គល គ្រួសារ និងសហគមន៍ទាំងមូល ក៏ដូចជា របស់របរប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវបានវេចខ្ចប់និងបញ្ចូលទៅក្នុងឡានដឹកសត្វធំៗជាច្រើនគ្រឿង។ អ្នកទាំងនោះពុំបានដឹងថាខ្លួននឹងត្រូវធ្វើដំណើរទៅទីណា? អស់រយៈពេលប៉ុន្មានថ្ងៃ? ឬនឹងមានអ្វីកើតឡើងខ្លះនៅពេលដែលបានទៅដល់គោលដៅ? សម្ភារប្រើប្រាស់របស់អ្នកទាំងនេះត្រូវបានរឹបអូស។

នៅពេលទៅដល់ជំរំឃុំឃាំង បុរសនិងស្ត្រីត្រូវបានបំបែក ហើយកុមារតូចៗ ត្រូវនៅជាមួយនឹងម្តាយ។ បន្ទាប់ពីការចុះឈ្មោះ អ្នកទោសត្រូវដោះសម្លៀកបំពាក់ កោរសក់ និងងូតទឹក។ បន្ទាប់មក សម្លៀកបំពាក់របស់អ្នកទោសត្រូវបានដកហូត ហើយអ្នកទោសត្រូវស្លៀកពាក់ឯកសណ្ឋានឆ្នូតៗជំនួសវិញ។

ជីវិតប្រចាំថ្ងៃនៅក្នុងជំរំឃុំឃាំង មានការពិបាកណាស់ គឺត្រូវធ្វើការធ្ងន់ធ្ងរទាំងនៅខាងក្នុងនិងខាងក្រៅជំរំឃុំឃាំង។ អ្នកទោសបានទទួលរបបអាហារ ពេលសម្រាក និងការការពារខ្លួនពីអាកាសធាតុត្រជាក់បានតិចតួចបំផុត។ ជំងឺនិងការឆ្លងជំងឺ តែងតែកើតមានឡើង។ មនុស្សជាច្រើនបានបាត់បង់ជីវិតដោយសារធ្វើការហួសកម្លាំង ភាពអត់ឃ្លាន និងជំងឺ។

អ្នកទោសក្នុងជំរំឃុំឃាំង បានធ្វើការបះបោរប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញទាំងនេះ តាមរយៈការប្រណិប័តន៍ជំនឿរបស់ខ្លួន ការសរសេរកំណត់ហេតុនិងការកត់ត្រាពីជីវិតប្រចាំថ្ងៃនៅក្នុងជំរំ។ អ្នកទោសក៏បានលួចម្ហូបអាហារដើម្បីចម្អែតក្រពះ។ ទន្ទឹមនឹងនេះ អ្នកទោសជួនកាលក៏បានព្យាយាមរត់ចេញពីជំរំ និងប្រយុទ្ធតតាំងគ្នាជាមួយនឹងអ្នកយាមជំរំ។

ខណៈពេលដែលកងទ័ពសម្ព័ន្ធមិត្តបានធ្វើដំណើរចូលទូទាំងទ្វីបអឺរ៉ុប ក្នុងឆ្នាំ១៩៤៤ កងទ័ពទាំងនោះចាប់ផ្តើមរំដោះជំរំ។ លើសពីនេះទៅទៀត កងទ័ពសម្ព័ន្ធមិត្តក៏បានជួបប្រទះជាមួយនឹងស្ថានភាពដែលអ្នកទោសជាច្រើននាក់ ត្រូវបានជម្លៀសចេញពីជំរំដើម្បីយកទៅសម្លាប់។ កងកម្លាំងសូវៀត គឺជាកងទ័ពសម្ព័ន្ធមិត្តដែលបានមកដល់ជំរំឃុំឃាំងក្នុងឆ្នាំ១៩៤៤។ មន្ត្រីណាហ្ស៊ី តែងតែព្យាយាមលាក់បាំងភស្តុតាងនៅតាមជំរំឃុំឃាំងមួយចំនួន តាមរយៈ ការកម្ទេចអគារនិងបំផ្លាញភស្តុតាងដទៃៗទៀត។ ជំរំឃុំឃាំងខ្លះមិនមានអ្នកទោសឡើយខណៈពេលដែលកងកម្លាំងសម្ព័ន្ធមិត្តបានមកដល់ ព្រោះថា អ្នកទោសទាំងអស់ត្រូវបានបង្ខំឱ្យចាកចេញទៅកាន់ទីតាំងដទៃទៀតឬជួនកាល ត្រូវបានសម្លាប់ចោលគ្មានសល់តែម្តង។

# តុលាការយោធាអន្តរជាតិ

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៤៥ ប្រទេសអាល្លឺម៉ង់បានប្រកាសចុះចាញ់ចំពោះកងកម្លាំងសម្ព័ន្ធមិត្ត។ ប្រហែល៦ខែក្រោយមក តុលាការយោធាអន្តរជាតិមួយបានចាប់ផ្តើមដំណើរការនៅក្នុងទីក្រុងនូរេមប៊ឺក ដើម្បីបើកសវនាការជាផ្លូវការលើមន្ត្រីនៃរបបណាហ្ស៊ី។ នេះគឺជាលើកដំបូងហើយដែលមេដឹកនាំប្រទេស មេដឹកនាំនយោបាយ និងយោធាសំខាន់ៗចំនួន២៤រូប ត្រូវបាននាំខ្លួនមកកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងសាលាក្តីយោធាអន្តរជាតិមួយនេះ។ ក្រោយមក មនុស្សជាង១០០នាក់ផ្សេងទៀតត្រូវបានកាត់ទោសជាបន្តបន្ទាប់ ដោយតុលាការយោធា នូរេមប៊ឺក របស់សហរដ្ឋអាមេរិក ទៅលើឧក្រិដ្ឋជនសង្គ្រាមដែលមានឋានៈជាមេដឹកនាំបន្ទាប់ពីមេដឹកនាំកំពូល។ តុលាការនេះបានសម្រេចឲ្យបុគ្គលទាំងនោះជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

បុគ្គលមួយចំនួនដែលត្រូវបានកាត់ទោសដោយតុលាការនេះ រួមមាន ហឺម៉ាន់ ហ្គោរីង ជាអ្នកទទួលខុសត្រូវលើការបង្កើតកងកម្លាំងប្រដាប់អាវុធសម្ងាត់ឈ្មោះ ហ្គេសស្តាប៉ូ ដែលជាកងកម្លាំងនគរបាលរបស់រដ្ឋ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនៃសង្គ្រាម ហ្គោរីង គឺជាអគ្គមេបញ្ជាការកងទ័ពជើងអាកាស និងជាមន្ត្រីជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធអាល្លឺម៉ង់ ត្រូវបានកាត់ទោសពីបទរៀបចំគម្រោងការដោយសម្ងាត់ ប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហ្គោរីង ត្រូវបានកាត់ទោសប្រហារជីវិតដោយព្យួរក ប៉ុន្តែបុគ្គលរូបនេះបានធ្វើអត្តឃាតនៅមុនពេលដែលទោសត្រូវបានអនុវត្ត។

ជនជាប់ចោទដទៃទៀតរួមមាន ចូគីម វ៉ុន រីបេនត្រុប, ហាន ហ្វ្រែង, អាល់ហ្វ្រែត រ៉ូសេនប៊ឺក និង ជូលៀស ស្រ្ទេចធឺរ។ រីបេនត្រុប គឺជារដ្ឋមន្ត្រីការបរទេសអាល្លឺម៉ង់ និងជាកម្លាំងស្នូលក្នុងការជំរុញឲ្យអាល្លឺម៉ង់ អនុវត្តកិច្ចការនិរទេសជនជាតិជ្វីហ្វពីប្រទេសជាសមាជិកនៃក្រុមមហាអំណាចអ័ក្សស មកកាន់ទីតាំងសម្លាប់ក្នុងប្រទេសអាល្លឺម៉ង់។ ហ្វ្រែង គឺជាមន្ត្រីជាន់ខ្ពស់គ្រប់គ្រងប្រទេសប៉ូឡូញ និងជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់ប្រជាជនស៊ីវិលប៉ូឡូញ និងជនជាតិប៉ូឡូញ-ជ្វីហ្វរាប់ម៉ឺននាក់។ រ៉ូសេនប៊ឺក ទទួលខុសត្រូវលើការនិរទេស និងការបំផ្លាញជនជាតិជ្វីហ្វ នៅក្នុងដែនដីនៃសហភាពសូវៀត ហើយ រ៉ូសេនប៊ឺក ក៏ជាអ្នកត្រួតត្រាលើការបង្កើតអង្គភាព អាញាសាប៉្យស្ទេប រ៉ូសែនប៊ឺក ក្នុងគោលបំណងរឹបអូសយកទ្រព្យសម្បត្តិវប្បធម៌ពីទូទាំងទ្វីបអឺរ៉ុប។ ស្រ្ទេចធឺរ គឺជាកម្លាំងស្នូលនៃការឃោសនារបស់ណាហ្ស៊ី ហើយស្រ្ទេចធឺរក៏គ្រប់គ្រងលើការបង្កើត និងចែកចាយសារព័ត៌មានស្តីពីការប្រឆាំងនឹងជនជាតិជ្វីហ្វ និងការរើសអើងពូជសាសន៍ដែរ។ រីបេនត្រុប, ហ្វ្រែង, រ៉ូសេនប៊ឺក និងស្រ្ទេចធឺរ គឺត្រូវបានកាត់ទោសប្រហារជីវិត។

សរុបមក ជនជាប់ចោទទាំង១២នាក់ត្រូវបានកាត់ទោសប្រហារជីវិតដោយព្យួរក។ ចំណែកសាកសពរបស់អ្នកទាំងនោះត្រូវបានដុតនៅក្នុងអតីតជំរំឃុំឃាំងដាខៅ។ ជនជាប់ចោទចំនួន៣នាក់ ត្រូវកាត់ទោសឲ្យជាប់ក្នុងពន្ធនាគារមួយជីវិត។ ចំណែកឯជនជាប់ចោទ៤នាក់ផ្សេងទៀត ត្រូវកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់រយៈពេល២០ឆ្នាំ។ តុលាការបានដោះលែងជនជាប់ចោទចំនួន៣នាក់។ ជនជាប់ចោទខ្លះពុំត្រូវបានកាត់ទោសដើម្បីយុត្តិធម៌ទេ នេះដោយសារតែអ្នកខ្លះត្រូវរួចផុតពីសវនការដោយសារបញ្ហាសុខភាព ឬអ្នកខ្លះបានរត់គេចពីការចាប់ខ្លួន។

អ៊ូតូ អាដុលហ្វ៍ អាយខ្មាន់ គឺជាមេដឹកនាំដ៏សំខាន់ម្នាក់ពាក់ព័ន្ធនឹងការនិរទេសទ្រង់ទ្រាយធំលើជនជាតិជ្វីហ្វ ទៅកាន់ទីតាំងសម្លាប់នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២។ ក៏ប៉ុន្តែ អាយខ្មាន់ បានរត់គេចពីការចាប់ខ្លួនរហូតដល់ឆ្នាំ១៩៦០។ អាយខ្មាន់ ត្រូវបានឃាត់ខ្លួននៅក្នុងប្រទេសអាហ្សង់ទីន និងនាំចេញពីប្រទេសនេះដើម្បីទទួលការកាត់ទោសនៅតុលាកាក្នុងប្រទេសអ៊ីស្រាអែល។

អាយឌ្មាន់ត្រូវបានសម្រេចទោស នៅក្នុងប្រទេសអ៊ីស្រាអែល ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងត្រូវបានកាត់ទោសដោយព្យួរក ក្នុងឆ្នាំ១៩៦២។

មេដឹកនាំជាន់ខ្ពស់ភាគច្រើន ដូចជា អាដុលហ្វ ហ៊ីត្លែរ, ហែនរិច ហ៊ីមល្លឺ និងចូសេភ ហ្គូបែល គឺមិនត្រូវបានកាត់ទោសឡើយ ព្រោះថាអ្នកទាំងនោះបានធ្វើអត្តឃាត ឬត្រូវបានសម្លាប់នៅមុនពេលសង្គ្រាមត្រូវបានបញ្ចប់ទៅ។

ក្នុងរយៈពេលជាច្រើនឆ្នាំបន្ទាប់មកទៀត មន្ត្រីណាហ្ស៊ីជាច្រើននាក់ត្រូវបានកាត់ទោសនៅក្នុងតុលាការដទៃទៀតជុំវិញពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានមន្ត្រីណាហ្ស៊ីជាច្រើននាក់ទៀតពុំត្រូវបានរកឃើញទេ។ តុលាការយោធាអន្តរជាតិនៅទីក្រុងនូរេមប៊ឺក និងតុលាការយោធាអន្តរជាតិដទៃទៀត ដូចជាតុលាការយោធាអន្តរជាតិនៅអាស៊ីបូព៌ា ឬត្រូវបានស្គាល់ថា ជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅតូក្យូ (ដែលកាត់ទោសមេដឹកនាំនៃចក្រភពជប៉ុន) បានបង្កើតច្បាប់គ្រឹះសម្រាប់ច្បាប់អន្តរជាតិ។ ការងាររបស់តុលាការបានវិវឌ្ឍទៅជាបទដ្ឋានសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនាពេលអនាគត ក៏ដូចជាសម្រាប់អនុសញ្ញា ទំនៀមទម្លាប់ និងការអនុវត្តច្បាប់ស្តីពីសិទ្ធមនុស្ស និងអំពើមនុស្សធម៌។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) តើអំពើប្រល័យពូជសាសន៍អាចកើតមានដាច់ដោយឡែកពីកំហឹង ឬព្រឹត្តិការណ៍សង្គ្រាមដែរឬទេ?

២) តើកត្តាអ្វីខ្លះដែលគាំទ្រឲ្យមានការសម្លាប់រង្គាល នៅក្នុងកម្រិតជាតិ?

៣) តើសង្គ្រាមបានលើកទឹកចិត្តឲ្យរដ្ឋាភិបាលប្រព្រឹត្តការសម្លាប់រង្គាលលើប្រជាជនរបស់ខ្លួនយ៉ាងដូចម្តេច?

### សំណួរដែលមានចម្លើយខ្លី

៤) នៅឆ្នាំ១៩៣៣ មានសកម្មភាពចម្បងមួយរបស់រដ្ឋាភិបាល បានកើតមានឡើងដែលបង្កជាការវាយប្រហារទៅលើជនជាតិជ្វីហ្វ។ តើព្រឹត្តិការណ៍នោះគឺជាព្រឹត្តិការណ៍អ្វី?

៥) ចូរពិពណ៌នាអំពីគម្រោងផែនការរបស់ណាហ្ស៊ីអាល្លឺម៉ង់ដែលត្រូវបានស្គាល់ថាជា“ដំណោះស្រាយចុងក្រោយ”។

៦) តើជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងជំរុំឃុំឃាំង មានសភាពយ៉ាងដូចម្តេច?

៧) តើក្រុមគោលដៅនៃរបបណាហ្ស៊ី មានក្រុមណាខ្លះ?

៨) តើប្រទេសអាល្លឺម៉ង់បានចុះចាញ់សង្គ្រាមលោកលើកទី២នៅពេលណា?

៩) តើឧក្រិដ្ឋជនណាហ្ស៊ីត្រូវបានគេនាំយកមកកាត់ទោសយ៉ាងដូចម្តេចខ្លះ?


N
North Sea
Baltic Se
Neuengamme
Ravensbrueck
Bergen-Belsen
Sachsen
Orani
Dora-
Mittelbau
Flossenbuerg
Buchenwald
Natzweiler-
Struthof
PROTECTORATE O
BOHEMIA AND
MORAVIA
SWITZERLAND
Dachau
Mauthaus




ផែនទីបង្ហាញអំពីជំរំឃុំឃាំងនៅក្នុងដែនដីនៃទ្វីបអឺរ៉ុបដែលស្ថិតក្រោមការគ្រប់គ្រងរបស់ណាហ្ស៊ី។
កម្មសិទ្ធផែនទីរបស់ សារមន្ទីរហូឡូខសសហរដ្ឋអាមេរិក។



**ផ្ទាំងគំនូរអំពីជនរងគ្រោះនិងជនដៃដល់**

ផ្ទាំងគំនូរនេះត្រូវបានគូរដោយវិចិត្រករកម្ពុជាមួយរូប។ លោកចង់បង្ហាញថា នៅក្នុងរបបខ្មែរក្រហម បុគ្គលមួយរូបអាចជាជនរងគ្រោះនិងជនដៃដល់។ ផ្ទាំងគំនូរនេះគឺជាអំណោយដែល លោក ចេមស៍ មីហ្សីស្គី ផ្តល់ជូនលោក ឆាំង យុ។ នៅក្នុងភាសាខ្មែរ មានសុភាសិតមួយពោលថា «ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី»។ សុភាសិតនេះបកស្រាយអំពីធម្មជាតិនៃវដ្តជីវិតនៅក្នុងរដូវប្រាំងនិងរដូវវស្សា។ ទោះបីជាយ៉ាងណាក្តី នៅក្នុងន័យធៀប សុភាសិតនេះបង្ហាញថាតើការផ្លាស់ប្តូរនៅក្នុងមជ្ឈដ្ឋានមួយអាចបង្កឥទ្ធិពលលើស្ថានភាពនិងការឆ្លើយតបរបស់បុគ្គលយ៉ាងដូចម្តេច។ នៅក្នុងកាលៈទេសៈមួយ ស្រមោចគឺជាចំណីឯនៅក្នុងកាលៈទេសៈដទៃទៀត ស្រមោចគឺជាអ្នកស៊ីចំណី។ មនុស្សជាតិមានសតិសម្បជញ្ញៈបែងចែកត្រូវខុស ក៏ប៉ុន្តែការផ្លាស់ប្តូរមជ្ឈដ្ឋានជុំវិញរបស់បុគ្គលអាចផ្លាស់ប្តូរមុខងារ ការសម្រេចចិត្ត និងអត្តចរិតបានដោយងាយ។ បុគ្គលមួយរូបអាចជាជនរងគ្រោះនៃអំពើឃោរឃៅទ្រង់ទ្រាយធំ ខណៈពេលដែលនៅពេលខ្លះបុគ្គលរូបនោះជាផ្នែកមួយឬជាជនដៃដល់នៃអំពើអមនុស្សធម៌។ នៅក្នុងន័យនេះ បុគ្គលទាំងឡាយដែលទទួលរងអំពើអមនុស្សធម៌ អាចប្រែជាចងកំហឹងនិងស្អប់ខ្ពើមចំពោះអ្នកដែលបានធ្វើទារុណកម្មមកលើខ្លួននិងអ្នកជាទីស្រឡាញ់។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ជនរងគ្រោះមួយចំនួនបានសងសឹកចំពោះអ្នកដែលត្រូវបានសង្ស័យថាបំពានលើខ្លួនឬសមាជិកគ្រួសាររបស់ខ្លួន។ ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

# ប្រទេសកម្ពុជា

បេក្ខភាពបណ្ឌិត សូ ហ្វារីណា និង មេធាវី គ្រីស្តូហ្វ័រ ឌៀរីង

មេរៀនសង្ខេប

ផ្នែកទី១

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងកុម្មុយនីស្ត (ជាទូទៅ យើងហៅថា ខ្មែរក្រហម) បានគ្រប់គ្រងប្រទេសកម្ពុជា និងបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ដែលនៅទីបំផុតរបបនេះបានបណ្តាលឲ្យប្រជាជនក្នុងចន្លោះពី ១លាន៤សែន ទៅ ២លាន២សែននាក់ស្លាប់បាត់បង់ជីវិត។

របបនយោបាយរបស់ខ្មែរក្រហម ត្រូវបានស្គាល់ថាជា បក្សកុម្មុយនីស្តកម្ពុជា។ បក្សកុម្មុយនីស្តកម្ពុជាបានខិតខំពុះពារអនុវត្តគោលនយោបាយបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា តាមលំនាំលទ្ធិម៉ៅ និងលទ្ធិម៉ាក្សលេនីន។ ដើម្បីសម្រេចគោលបំណង ខ្មែរក្រហមបានរៀបចំសង្គមឡើងវិញគ្រប់ផ្នែកទាំងអស់ ដោយចាប់ផ្តើមពីការជម្លៀសប្រជាជនចេញពីទីក្រុង។ ជាលទ្ធផលនៃការសម្រេចបានគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនជាច្រើននាក់បានស្លាប់បាត់បង់ជីវិតដោយការអត់ឃ្លាន ភាពបាក់កម្លាំង និងជំងឺ។ កុមារត្រូវបំបែកចេញពីឪពុកម្តាយ។ ប្តីត្រូវបំបែកចេញពីប្រពន្ធ។ ចំណែកក្រុមគ្រួសារត្រូវបំបែកចេញពីគ្នា។ ទីក្រុងនិងទីប្រជុំជននានាទូទាំងប្រទេស បានប្រែទៅជាកន្លែងដែលគ្មានមនុស្សរស់នៅ ហើយប្រជាជនតែងតែត្រូវបានបង្ខំឲ្យធ្វើដំណើរដោយថ្មើរជើងទៅកាន់ទីតាំងថ្មី។ របបនេះ បានបង្កើតប្រព័ន្ធការងារក្រោមលក្ខខណ្ឌលំបាកលំបិន។ លើសពីនេះទៀត ដើម្បីការពារបក្សរបស់ខ្លួនពី "សត្រូវខាងក្នុងនិងសត្រូវខាងក្រៅ" ដែលកើតចេញពីការស្រមើស្រមៃ និងដោះស្រាយភាពបរាជ័យនៃគោលនយោបាយផ្តាច់ការរបស់ខ្លួន ខ្មែរក្រហមបានបង្កើតកម្មវិធីរឹតបន្តឹងសន្តិសុខ ដោយផ្តោតគោលដៅលើអ្នកដែលត្រូវបានសង្ស័យថាបានក្បត់នឹងបក្សកុម្មុយនីស្តកម្ពុជា រួមមាន អ្នកដែលមានទំនាក់ទំនងជាមួយនឹងរបបមុនៗ អ្នកចេះដឹង អ្នកមានទ្រព្យសម្បត្តិ និងអ្នកគោរពប្រណិប័តន៍សាសនា។ មនុស្សរាប់ម៉ឺននាក់ត្រូវបានឃាត់ខ្លួន ហើយជាច្រើននាក់ផ្សេងទៀតត្រូវបានសម្លាប់ និងចាប់ដាក់ក្នុងគុកឬមន្ទីរអប់រំ ដែលទីបំផុតអ្នកទាំងនោះបានស្លាប់ដោយសារតែការធ្វើទារុណកម្ម។ សូម្បីតែកំហុសតូចតាចបំផុតក៏អាចធ្វើឲ្យមនុស្សប្រឈមនឹងការស្លាប់ដែរ។



ញឹក វេងហួរ



នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានលុបបំបាត់រូបិយប័ណ្ណ ទីផ្សារ និងទ្រព្យសម្បត្តិឯកជន។ ការគោរពបូជាសាសនានិងវប្បធម៌ ត្រូវបានហាមឃាត់។ សាលារៀន វត្តអារាម វិហារឥស្លាម វិហារគ្រិស្ត និងហាងទំនិញនានា ត្រូវបានបិទទ្វារ ឬប្រែក្លាយទៅជាគុក មន្ទីរអប់រំកែប្រែ ឬកន្លែងដែលអាចបម្រើដល់គោលបំណងនានារបស់រដ្ឋាភិបាលខ្មែរក្រហម។ ពុំមានមធ្យោបាយដឹកជញ្ជូនសាធារណៈ ឬឯកជនឡើយ។ ចំណែកឯសកម្មភាពកំសាន្តត្រូវបានរឹតត្បិតយ៉ាងខ្លាំង ហើយការធ្វើកសិកម្ម ឬសកម្មភាពអាជីវកម្មដទៃទៀតជាលក្ខណៈឯកជន ក៏មិនត្រូវបានអនុញ្ញាតដែរ។ ផ្ទុយទៅវិញ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើពលកម្មនៅក្នុងសហករណ៍ ឬនៅតាមការដ្ឋានការងារប្រព័ន្ធធារាសាស្ត្រ និងការដ្ឋានការងារដទៃៗទៀត។ ប្រជាជនត្រូវទទួលរងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ ការដើរហើរនានាត្រូវបានរឹតបន្តឹង។ ប្រជាជនត្រូវបានបង្ខំឲ្យបរិភោគអាហាររួម។ ទំនាក់ទំនងគ្រួសារក៏ត្រូវបានរឹតត្បិត ឬកាត់ផ្តាច់។ ចំណែកឯការប្រណិប័តន៍សាសនា គឺត្រូវបានហាមឃាត់។ សេរីភាពនៃការបញ្ចេញមតិត្រូវបានរឹតបន្តឹងតាមរយៈការធ្វើទារុណកម្មធ្ងន់ធ្ងរ និងការសម្លាប់។ អ្នកដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសឆ្គងនឹងត្រូវទទួលទណ្ឌកម្មដោយគ្មានការសួរនាំ។



**ជនរងគ្រោះនៃរបបខ្មែរក្រហម** - ញឹក វេងហួរ គឺជាសមាជិកមួយរូបក្នុងចំណោមក្រុមប្រជាជនកម្ពុជា១១៤រូប រស់នៅសហរដ្ឋអាមេរិក ដែលមានបំណងវិលត្រឡប់មកកាន់ប្រទេសកំណើតរបស់ខ្លួន។ ដោយរំពឹងថាអាចការពារក្រុមគ្រួសាររបស់ខ្លួន ប្រជាជនក្រុមនេះបានត្រឡប់មកកាន់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៦ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ភ្លាមៗបន្ទាប់ពីការមកដល់ប្រទេសកម្ពុជា អ្នកទាំងនេះត្រូវបានចាប់ខ្លួនដាក់គុក ធ្វើទារុណកម្ម និងសម្លាប់។ ញឹក វេងហួរ គឺជាម្នាក់ក្នុងចំណោមប្រជាជនកម្ពុជាចំនួនជាង២លាននាក់ដែលបានបាត់បង់ជីវិតយ៉ាងសង្វេគនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ការប៉ាន់ស្មានបង្ហាញថា មានប្រជាជនកម្ពុជាប្រមាណ៥លាននាក់ នៅរស់រានមានជីវិតពីរបបនេះ។
ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ដើម្បីសម្រេចបានគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យការពារជាតិនៅបន្លោះចុងឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ របបនេះបានព្យាយាមបង្កើនចំនួនប្រជាជនដោយបង្ខំឱ្យស្ត្រីនិងបុរសរៀបការជាមួយគ្នាក្រោមការរៀបចំគូស្រករដោយអង្គការ។ បុរសស្ត្រីជាគូស្រករ ជាទូទៅតែងតែត្រូវបង្ខំឱ្យរៀបការរួមគ្នាជាមួយគូស្រករដទៃទៀត ដែលខុសទៅនឹងប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនកម្ពុជា។ បន្ទាប់មក គូស្រករដែលរៀបការថ្មីថ្មោង ត្រូវបង្ខំឱ្យសេពសន្ថវៈជាមួយគ្នាជាប្តីប្រពន្ធ។ គូស្រករណាដែលត្រូវបានរកឃើញថាពុំបានរួមរស់ជាមួយគ្នាទេ គូស្រករនោះនឹងត្រូវនាំយកទៅអប់រំ ឬទទួលរងនូវការគំរាមកំហែងដាក់ទោសនិងសម្លាប់។

ភាពភ័យខ្លាចនៃរបបនេះ ពុំបានបញ្ចប់ទៅភ្លាមៗបន្ទាប់ពីកងកម្លាំងកម្ពុជា និងកងកម្លាំងវៀតណាមវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩នោះឡើយ។ ចាប់តាំងពីខែមករា ឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៨ ខ្មែរក្រហមនៅតែបន្តធ្វើសកម្មភាពទ័ពព្រៃរបស់ខ្លួន ដែលបានយាយីនិងវាយប្រហារមកលើប្រជាជន និងរដ្ឋាភិបាលកម្ពុជា។



**របបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)**

សេនាប្រមុខ លន់ នល់ (ខាងឆ្វេងទីពីរ) គឺជាប្រធានាធិបតីនៃរបបសាធារណរដ្ឋខ្មែរ និងព្រះអង្គម្ចាស់សិរិមតៈ (ខាងស្តាំបង្អស់) គឺនាយករដ្ឋមន្ត្រីស្តីទីនៃរបបសាធារណរដ្ឋខ្មែរ នៅឯបន្ទាយយោធាមួយកន្លែង ក្នុងឆ្នាំ១៩៧៣។ ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។



សាកសពយោធាខ្មែរក្រហមនិងកងទ័ពវៀតកុង ដែលត្រូវបានសម្លាប់ដោយកងកម្លាំងទាហានសាធារណរដ្ឋខ្មែរ ដាក់បង្ហាញនៅខាងមុខស្ថានទូតបារាំងប្រចាំនៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧០។ ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

អង្គការសហប្រជាជាតិ បានចាត់តាំងក្រុមការងារឲ្យធ្វើការស្រាវជ្រាវទាក់ទងនឹងអំពើដែលខ្មែរក្រហមបានប្រព្រឹត្ត។ តាមរយៈការស្រាវជ្រាវនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានឯកភាពគ្នារៀបចំបង្កើតតុលាការចម្រុះមួយរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ដើម្បីស៊ើបអង្កេតនិងកាត់ទោស បទឧក្រិដ្ឋទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ នៅឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតួនាទីវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) តើមនោគមន៍វិជ្ជានយោបាយរបស់ "របបខ្មែរក្រហម" គឺជាអ្វី?

២) តើខ្មែរក្រហមបង្កើតគោលនយោបាយអ្វីខ្លះ?

៣) ស្ថិតនៅក្រោមរបបខ្មែរក្រហម តើប្រជាជនកម្ពុជាទទួលរងអ្វីខ្លះ?

## មេរៀនលម្អិត

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងកុម្មុយនីស្ត ដែលត្រូវបានស្គាល់ជាទូទៅថា ខ្មែរក្រហម បានកាន់កាប់ប្រទេសកម្ពុជា និងបានបង្កើតរដ្ឋាភិបាលមួយដែលមានឈ្មោះថា "កម្ពុជាប្រជាធិបតេយ្យ"។ នៅក្នុងរយៈពេលជិត៤ឆ្នាំនៃការគ្រប់គ្រងប្រទេស ប្រជាជនកម្ពុជាចំនួនប្រមាណពី ១លាន៤សែន ទៅ២លាន២សែននាក់ បានស្លាប់បាត់បង់ជីវិត តាមរយៈការសម្លាប់ ការស្លាប់ដោយការអត់អាហារ ការធ្វើការហួសកម្លាំង និងជំងឺដែលបណ្តាលមកពីកង្វះការថែទាំសុខភាព។ សកម្មភាពដ៏គួរឲ្យភ័យខ្លាច ការធ្វើទារុណកម្ម ការធ្វើការហួសកម្លាំង និងការសម្លាប់បង្កឡើងដោយខ្មែរក្រហម បានបន្តរហូតដល់មានកងកម្លាំងរបស់វៀតណាមចូលមកដល់ប្រទេសកម្ពុជា និងបានកាន់កាប់ទីក្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ពាក្យ "ខ្មែរក្រហម" គឺជាឈ្មោះដែលសម្តេចព្រះនរោត្តម សីហនុ ដាក់ឲ្យគូបដិបក្ខកុម្មុយនីស្តរបស់ព្រះអង្គនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ឈ្មោះផ្លូវការនៃក្រុមនេះគឺ បក្សកុម្មុយនីស្តកម្ពុជា។

ដើមកំណើតរបស់ខ្មែរក្រហម គឺផ្តើមចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំង។ នៅចុងសតវត្សរ៍ទី១៩និងរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៥០ បារាំងបានគ្រប់គ្រងប្រទេសកម្ពុជា ឡាវ និងវៀតណាម។ ប្រទេសទាំង៣ ដែលស្ថិតនៅក្រោមអាណានិគមបារាំង ត្រូវបានស្គាល់ជាទូទៅថា ជាប្រទេសដែលស្ថិតក្នុងឧបទ្វីបឥណ្ឌូចិនកំណត់ដោយបារាំង។ ទោះបីជាទស្សនៈប្រឆាំងនឹងអាណានិគមបារាំងតែងតែបានកើតមានឡើង ជួនកាលបានបង្កទៅជាចលនាបះបោរនៅក្នុងទម្រង់ជាក់លាក់ណាមួយយ៉ាងណាក៏ដោយ ក៏ចលនាប្រឆាំងនឹងអាណានិគមបារាំងមិនបានប្រមូលផ្តុំគ្នាជាទ្រង់ទ្រាយធំនៅមុនទសវត្សរ៍ឆ្នាំ១៩៤០នោះទេ។ ខ្មែរឥស្សរៈ គឺជាចលនាជាតិនិយមខ្មែរប្រឆាំងនឹងអាណានិគមបារាំង ដែលបានកកើតឡើងតាមរយៈការគាំទ្រពីប្រទេសថៃនៅក្នុងឆ្នាំ១៩៤៥។ ទោះបីជាក្រុមខ្មែរឥស្សរៈ ត្រូវបានពិពណ៌នាថាជាចលនាមួយក៏ដោយ តាមភាពជាក់ស្តែងចលនានេះពុំមានថ្នាក់ដឹកនាំជាក់លាក់ឡើយ។ យ៉ាងណាមិញ ខ្មែរឥស្សរៈត្រូវបានបង្កើតឡើងជាច្រើនក្រុមផ្សេងៗគ្នា ដែលមានគោលបំណង និងបរន្តនយោបាយខុសៗពីគ្នា។ ក្រុមឥស្សរៈប៉ែកខាងលិចប្រទេសបានស្វះស្វែងរកជំនួយពីប្រទេសថៃ ខណៈដែលក្រុមឥស្សរៈប៉ែកខាងកើតប្រទេសបានធ្វើការជាមួយ និងទទួលឥទ្ធិពលយ៉ាងខ្លាំងពីក្រុមកុម្មុយនីស្តវៀតណាម ដែលក្រុមនេះត្រូវស្គាល់នាពេលបន្ទាប់មកថាជាក្រុម "វៀតមិញ"។ ក្រុមកុម្មុយនីស្តវៀតណាម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការកកើតចលនាកុម្មុយនីស្តកម្ពុជានៅគ្រាដំបូង។

វៀតមិញ គឺជាក្រុមកុម្មុយនីស្តចម្រុះមួយ ដែលប្រឆាំងនឹងការកាន់កាប់របស់បារាំងលើប្រទេសវៀតណាម។ ក្នុងឆ្នាំ១៩៤៩ វៀតមិញទទួលបានការគាំទ្រពីបក្សកុម្មុយនីស្តចិន ដែលអាចឲ្យខ្លួនបង្កើតជាការតស៊ូប្រឆាំងនឹងបារាំង ដោយប្រែក្លាយពីជម្លោះទ័ពព្រៃទៅជាសង្គ្រាមប្រដាប់អាវុធ។ មកទល់នឹងឆ្នាំ១៩៥០ តំបន់ឥណ្ឌូចិនកំណត់ដោយបារាំង បានធ្លាក់ចូលក្នុងស្ថានភាពបះបោរផ្ទៃក្នុង ដែលបច្ចុប្បន្នត្រូវបានហៅថាសង្គ្រាមឥណ្ឌូចិនលើកទី១។ ភាគច្រើននៃការប្រយុទ្ធនៅក្នុងអំឡុងពេលកើតមានសង្គ្រាមឥណ្ឌូចិនលើកទី១ ប្រព្រឹត្តទៅនៅក្នុងប្រទេសវៀតណាម។ ទោះបីជាយ៉ាងណាក្តី ក្រុមជាតិនិយមខ្មែរបានតស៊ូប្រឆាំងនឹងបារាំងនៅក្នុងពេលតែមួយដូចគ្នា។ នៅឆ្នាំ១៩៥១ បក្សកុម្មុយនីស្តវៀតណាម បានណែនាំឲ្យបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលដើរតួនាទីជាអង្គភាពនាំមុខរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាទូទៅត្រូវបានស្គាល់ថា "ខ្មែរក្រហម" ។ ដូចគ្នាទៅនឹងខ្មែរឥស្សរៈដែរ មុនដំបូងខ្មែរក្រហមបានអនុវត្តតាមទិសដៅរបស់ក្រុមកុម្មុយនីស្តវៀតណាម។



មកទល់ឆ្នាំ១៩៥៣ បារាំងផ្តល់ឯករាជ្យដល់ប្រទេសកម្ពុជា និងនៅក្នុងសន្និសីទសន្តិភាពទីក្រុងហ្សឺណែវ (ដែលបានបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី១ជាផ្លូវការនៅក្នុងឆ្នាំ១៩៥៤) ប្រទេសវៀតណាមបានបែងចែកជាវៀតណាមកុម្មុយនីស្តខាងជើង និងវៀតណាមខាងត្បូងដែលទទួលបានការគាំទ្រពីលោកខាងលិច។

ប៉ុន្មានឆ្នាំបន្ទាប់ពីសន្និសីទសន្តិភាពទីក្រុងហ្សឺណែវ (១៩៥៥-១៩៥៩) ឥទ្ធិពលរបស់ចលនាកុម្មុយនីស្តកម្ពុជាបានថមថយ។ រដ្ឋបាលអាណានិគមបារាំងបានដកចេញពីប្រទេសកម្ពុជា។ សម្តេចព្រះ នរោត្តម សីហនុ បានដាក់រាជ្យបល្ល័ង្ក និងប្តូរទៅជាសម្តេចព្រះ នរោត្តម សីហនុ ដែលព្រះអង្គគឺជាអ្នកនយោបាយ និងជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា។ ស្ថិតក្រោមការគ្រប់គ្រងរបស់សម្តេចព្រះ នរោត្តម សីហនុ បក្សប្រឆាំងត្រូវបានគាបសង្កត់។ ចំណែកបក្សកុម្មុយនីស្តកម្ពុជា ដែលរំពឹងថាអាចរក្សាជំហររបស់ខ្លួនបាននៅក្នុងរដ្ឋកម្ពុជាឯករាជ្យបង្កើតថ្មីនេះ ត្រូវបែកខ្ញែកទៅកាន់ទីជនបទដាច់ស្រយាល និងរស់នៅក្នុងព្រៃនានា ជាកន្លែងដែលក្រុមនេះបានប្រឹងប្រែងតស៊ូដើម្បីរស់។

ក្នុងខែកញ្ញា ឆ្នាំ១៩៦០ បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតគោលនយោបាយថ្មី និងបានប្តូរឈ្មោះទៅជាបក្សពលករកម្ពុជា។ ទូ សាមុត គឺជាលេខាបក្ស ចំណែកឯ នួន ជា គឺជាអនុលេខាបក្ស។ ប៉ុល ពត មានឋានៈទីបីនៅក្នុងបក្សនាពេលនោះ។ ប៉ុល ពត បានប្តូរទៅជាអនុលេខាបក្សទីពីរនៅឆ្នាំ១៩៦១។ បន្ទាប់ពី ទូ សាមុត បាត់ខ្លួននៅក្នុងឆ្នាំ១៩៦២ បក្សនេះបានបើកសម័យប្រជុំជាបន្ទាន់នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ និងបានជ្រើសរើស ប៉ុល ពត ធ្វើជាលេខាបក្ស ហើយ នួន ជា នៅតែជាអនុលេខាបក្សដដែល។ ក្នុងឆ្នាំ១៩៦៥ ប៉ុល ពត បានចូលរួមនៅក្នុងកិច្ចប្រជុំជាច្រើនជាមួយវៀតណាមខាងជើង ចិន និងកូរ៉េខាងជើង។ នៅក្នុងឆ្នាំ១៩៦៦ បន្ទាប់ពីបានត្រឡប់មកកាន់ប្រទេសកំណើតវិញ ប៉ុល ពត បានផ្លាស់ប្តូរឈ្មោះបក្សទៅជា បក្សកុម្មុយនីស្តកម្ពុជា ក្រោមការដឹកនាំរបស់គណៈកម្មាធិការមជ្ឈិមបក្ស ដែលរួមមាន ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី និង តាម៉ុក ជាសមាជិកពេញសិទ្ធិ ព្រមទាំង វន វេត និង សុន សេន ជាសមាជិកត្រៀម។ ដោយមិនស្ថិតនៅក្នុងតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ចលនាបក្សកុម្មុយនីស្តកម្ពុជាបានប្រមូលផ្តុំកម្លាំង និងបានរៀបចំបក្សសាជាថ្មីក្រោមបរិយាកាសអំណោយផលជាងមុន ដែលជាហេតុធ្វើឱ្យបក្សនេះអាចដណ្តើមយកអំណាចបាន។ កាលៈទេសៈអំណោយផលទាំងនេះ បានលេចឡើងនៅក្នុងឆ្នាំ១៩៧០ គឺនៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ ត្រូវបានទម្លាក់ចេញពីតំណែង និងការបង្កើតរបប លន់ នល់ (របបសាធារណរដ្ឋខ្មែរ)។

ក្នុងខែមីនា ឆ្នាំ១៩៧០ រដ្ឋសភាជាតិបានបោះឆ្នោតទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតួនាទីជាប្រមុខរដ្ឋ។ ការទម្លាក់ព្រះអង្គចេញពីតំណែង និងការបង្កើតរបប លន់ នល់ បានផ្តល់ឱកាសជាច្រើនដល់បក្សកុម្មុយនីស្តកម្ពុជា។ ក្រោយពីទម្លាក់ចេញពីតំណែង ព្រះអង្គបានស្វះស្វែងរកជំនួយពីអតីតសត្រូវរបស់ព្រះអង្គ គឺបក្សកុម្មុយនីស្តកម្ពុជា ឬខ្មែរក្រហម។ ព្រះអង្គនៅតែទទួលបានការគោរពស្រឡាញ់ពីប្រជារាស្ត្ររបស់ព្រះអង្គនៅតាមទីជនបទដដែល។ ហេតុនេះ ការចងសម្ព័ន្ធភាពជាមួយព្រះអង្គបានធ្វើឱ្យខ្មែរក្រហមបង្កើនការជ្រើសរើសប្រជាជនដើម្បីបម្រើបុព្វហេតុរបស់ខ្លួន។

លើសពីនេះទៅទៀត ការបង្កើតរបប លន់ នល់ ដែលមានលោកខាងលិចជាខ្នងបង្អែក បានបង្កើតឱ្យមានការរីករាលដាលយ៉ាងគំហុកនូវសង្គ្រាមឥណ្ឌូចិនលើកទី២ (ឬសង្គ្រាមវៀតណាម)។ ប្រទេសកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលក្តៅគគុកចាប់តាំងពីថ្ងៃដំបូងនៃសង្គ្រាមឥណ្ឌូចិនលើកទី២។ សង្គ្រាមនេះ ដែលមានសហរដ្ឋអាមេរិកពួតដៃគ្នាជាមួយវៀតណាមខាងត្បូងធ្វើការប្រយុទ្ធប្រឆាំងនឹងក្រុមកុម្មុយនីស្តវៀតណាម និងវៀតណាមខាងជើង បានហៀរឆ្លងព្រំដែនចូលមកក្នុងទឹកដីរបស់កម្ពុជា។ ស្ថិតក្រោមការគ្រប់គ្រងរបស់សម្តេចព្រះ នរោត្តម សីហនុ នាពេលនោះ ក្រុមកុម្មុយនីស្តវៀតណាមទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ដែនដីរបស់កម្ពុជា ដើម្បីជួយដល់ការតស៊ូរបស់ខ្លួនប្រឆាំងនឹងកងកម្លាំងសហរដ្ឋអាមេរិក និងវៀតណាម (ខាងត្បូង)។ ជាការតបស្នងក្រុម

កុម្មុយនីស្តវៀតណាមបានគាំទ្រព្រះអង្គ ទោះបីជាត្រូវប៉ះពាល់ដល់ក្រុមកុម្មុយនីស្តកម្ពុជាដែលជាយុទ្ធមិត្តប្រកៀកស្មារបស់ខ្លួនក៏ដោយ។ ក្រោយមកទៀត ទោះបីជាប្រទេសកម្ពុជាស្ថិតនៅក្នុងការគ្រប់គ្រងប្រទេសរបស់រដ្ឋាភិបាលដែលមានខ្នងបង្អែកពីសហរដ្ឋអាមេរិក ហើយយ៉ាងណាក្តី ក៏កងកម្លាំងកុម្មុយនីស្តវៀតណាម នៅតែបន្តចូលទៅក្នុងប្រទេសកម្ពុជាកាន់តែជ្រៅ និងបានប្រយុទ្ធជាមួយកងកម្លាំង លន់ នល់ និងជួយដល់ការជ្រើសរើសនិងការបណ្តុះបណ្តាលយោធាខ្មែរក្រហមទៀតផង។ ជាលទ្ធផលនៃហេតុការណ៍ទាំងនេះ ខ្មែរក្រហមបានបង្កើនចំនួនកម្លាំងយោធារបស់ខ្លួនរហូតដល់៣ពាន់នាក់នៅក្នុងឆ្នាំ១៩៧០ និងលើសពី៤ម៉ឺននាក់នៅក្នុងឆ្នាំ១៩៧៣។ ក្រោមការទំនុកបម្រុងរបស់វៀតណាមខាងជើង ខ្មែរក្រហមបានចាប់ផ្តើមយកឈ្នះលើកងកម្លាំង លន់ នល់ នៅក្នុងសមរភូមិ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏សម្ព័ន្ធមិត្តវៀតណាម-ខ្មែរក្រហម ស្ថិតនៅបានរយៈពេលមួយគ្រាតែប៉ុណ្ណោះ។ នៅពេលដែលខ្មែរក្រហមបានបង្កើនកម្លាំង និងភាពអង់អាចរបស់ខ្លួន ខ្មែរក្រហមបានចាប់ផ្តើមទាមទារឲ្យកងកម្លាំងវៀតណាមចាកចេញពីប្រទេសកម្ពុជា។ ក្នុងខែមករា ឆ្នាំ១៩៧៣ រដ្ឋាភិបាលកុម្មុយនីស្តវៀតណាម ដែលមានមូលដ្ឋាននៅទីក្រុងហាណូយ រដ្ឋាភិបាល ធីវគី ដែលមានមូលដ្ឋាននៅទីក្រុងសៃហ្គន (ហូជីមិញ) និងសហរដ្ឋអាមេរិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក្នុងគោលបំណងបញ្ចប់ជម្លោះរ៉ាំរ៉ៃនៅក្នុងប្រទេសវៀតណាម។ ខណៈពេលដែលកិច្ចព្រមព្រៀងនេះពុំបានរួមបញ្ចូលសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា កិច្ចព្រមព្រៀងនេះតម្រូវឲ្យភាគីបរទេសទាំងអស់ដកកម្លាំងរបស់ខ្លួនចេញពីប្រទេសកម្ពុជា។ មកដល់ចុងឆ្នាំ១៩៧៣ កងកម្លាំងវៀតណាមភាគច្រើនបានចាកចេញពីប្រទេសកម្ពុជា ហើយខ្មែរក្រហមត្រូវទទួលបន្ទុកទាំងស្រុងចំពោះសង្គ្រាមប្រឆាំងជាមួយនឹងរបប លន់ នល់។

នៅដើមឆ្នាំ១៩៧៣ ទឹកដីប្រទេសកម្ពុជាប្រមាណ ៨៥ ភាគរយ បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ចំណែកកងកម្លាំងប្រដាប់អាវុធរបស់ លន់ នល់ ស្ទើរតែបោះបង់បោលការប្រយុទ្ធទាំងស្រុងនៅសមរភូមិ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងទីក្រុងភ្នំពេញ ហើយបន្តិចក្រោយមក ខ្មែរក្រហមបានប្រកាសបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។

ក្រោយពីយកឈ្នះលើរបប លន់ នល់ បក្សកុម្មុយនីស្តកម្ពុជា បានពុះពារអនុវត្តរបបបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា តាមរយៈកម្មវិធីនយោបាយផ្លាស់ប្តូរស្ថិតក្រោមលំនាំលទ្ធិមហាលោតផ្លោះម៉ៅ និងលទ្ធិម៉ាក្សលេនីន។ ដើម្បីសម្រេចបានការផ្លាស់ប្តូរនេះ ខ្មែរក្រហមបានរៀបចំសង្គមគ្រប់ផ្នែកសាជាថ្មី ដោយចាប់ផ្តើមពីការជម្លៀសប្រជាជនចេញពីទីក្រុង។

ស្ថិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនជាច្រើនត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួន និងជាទូទៅត្រូវធ្វើដំណើរទៅកាន់ទីជនបទដាច់ស្រយាល។ គោលនយោបាយនៃការផ្លាស់ទីលំនៅរបស់ប្រជាជនពីកន្លែងមួយទៅកន្លែងដទៃទៀត (ការជម្លៀសដោយបង្ខំ) បានបង្កជាទុក្ខវេទនានិងផលវិបាកជាច្រើនដល់ ប្រជាជននិងសហគមន៍។ នៅក្នុងរយៈពេល៤៥ខែ របបខ្មែរក្រហមបានបង្កើតឲ្យមានការជម្លៀសដោយបង្ខំជាច្រើនដងនៅតាមតំបន់នានា។

ខ្មែរក្រហមបានប្រើប្រាស់សហករណ៍ និងការដ្ឋានការងារ ជាមធ្យោបាយក្នុងការគ្រប់គ្រងយ៉ាងតឹងរ៉ឹង មកលើប្រជាជនកម្ពុជា និងបានអនុវត្តយុទ្ធសាស្ត្រប្រឆាំងនឹងឋានៈសង្គម។ ការដ្ឋានត្រូវបានបង្កើតឡើងនៅតាមទីជនបទនានា។ ឧទាហរណ៍នៃការដ្ឋានការងារទាំងនោះរួមមាន សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់អាកាសយានដ្ឋានកំពង់ឆ្នាំង។

សហករណ៍ត្រាំកក់ ស្ថិតនៅក្នុងតំបន់១៣នៃភូមិភាគនិរតី ដែលបច្ចុប្បន្នស្ថិតនៅក្នុងខេត្តតាកែវ។ នៅក្នុងសហករណ៍ត្រាំកក់ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងស្ថានភាពមួយដែលទទួលបានរបបអាហារតិចតួច និងស្ថិតក្នុងការគ្រប់គ្រងប្រកបដោយការភ័យខ្លាច។ ប្រជាជនបានបាត់បង់ជីវិតដោយសារកង្វះអាហារមានជីវជាតិ ការធ្វើការហួសកម្លាំង និងជំងឺ។





**ក្បួននៃក្រុមអ្នករបាំ ឆ្នាំ១៩៧៣**
នៅក្នុងអំឡុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) សិល្បករ សិល្បការិនី និងអ្នកជំនាញផ្នែកវប្បធម៌របស់កម្ពុជា គឺជាក្រុមគោលដៅ ដោយសារតែអ្នកទាំងនេះមានទំនាក់ទំនង និងជាអ្នកមានឥទ្ធិពលលើ ទម្រង់សិល្បៈបែបបុរាណ និងប្រព័ន្ធផ្សព្វផ្សាយមហាជន។ សិល្បការិនីមួយរូប (សោម សាខុន) ក្នុងរូបថតនេះ ត្រូវបានខ្មែរក្រហមសម្លាប់។
ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅការដ្ឋានទំនប់ត្រពាំងថ្ម ដែលបច្ចុប្បន្នស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ ប្រជាជនត្រូវបានបង្ខំឲ្យកសាងទំនប់១និងភ្លឺស្រែ ២ ។ ម៉ោងការងារមានរយៈពេលវែង ដោយមិនខ្វាយខ្វល់ពីអាកាសធាតុ និងគ្មានថ្ងៃឈប់សម្រាក។ ប្រជាជនត្រូវបានគម្រាមកំហែងដោយការសម្លាប់ឬការកាត់បន្ថយរបបអាហារ។ ប្រជាជននៅការដ្ឋាននេះ បានបាត់បង់ជីវិតដោយសារតែស្ថានភាពរស់នៅ ហើយសាក្សីបានពិពណ៌នាថា ការសម្លាប់ក៏បានកើតមានឡើងដែរ។

ការដ្ឋានទំនប់១មករា ស្ថិតនៅក្នុងតំបន់៤២ និង ៤៣ ក្នុងភូមិភាគកណ្តាល (ឬអតីតភូមិភាគឧត្តរ) ឬ បច្ចុប្បន្នខេត្តកំពង់ធំ។ នៅក្នុងអំឡុងពេលសាងសង់ទំនប់នេះ ប្រជាជនរាប់ពាន់នាក់ត្រូវបានបង្ខំឲ្យធ្វើការនៅក្រោមស្ថានភាពលំបាកលំបិន។

នៅការដ្ឋានសាងសង់អាកាសយានដ្ឋានកំពង់ឆ្នាំង ដែលបច្ចុប្បន្នស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ប្រជាជនត្រូវបានចាត់ទុកដូចជាទាសករ និងត្រូវធ្វើការស្ថិតក្រោមការគំរាមកំហែងសម្លាប់។

នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រូបិយប័ណ្ណ ទីផ្សារ និងទ្រព្យសម្បត្តិឯកជន ត្រូវបានលុបបំបាត់។ ការគោរពបូជាសាសនានិងវប្បធម៌ត្រូវបានហាមឃាត់។ សាលារៀន វត្តអារាម វិហារឥស្លាម វិហារគ្រិស្ត និងហាងទំនិញនានាត្រូវបានបិទ ឬប្រែក្លាយទៅជាគុក មន្ទីរអប់រំកែប្រែ ឬកន្លែងដែលអាចបម្រើដល់គោលបំណងនានារបស់រដ្ឋាភិបាលខ្មែរក្រហម។ ពុំមានមធ្យោបាយដឹកជញ្ជូនសាធារណៈ ឬឯកជនទេនៅក្នុងរបបខ្មែរក្រហម។ បំណែកឯសកម្មភាពកំសាន្តផ្សេងៗត្រូវបានរឹតត្បិតយ៉ាងខ្លាំង។ ការធ្វើកសិកម្ម ឬសកម្មភាពអាជីវកម្មឯកជនដទៃទៀតមិនត្រូវបានអនុញ្ញាតឡើយ។ ផ្ទុយទៅវិញ ប្រជាជនត្រូវបានបង្ខំ




**ខ្មែរក្រហម និងភាគីចិន។** (កណ្ដាលខាងស្ដាំ) ប៉ុល ពត នាយករដ្ឋមន្ត្រីនិងលេខាបក្សកុម្មុយនីស្ដកម្ពុជា ជាមួយនឹង វ៉ាង តុងស៊ីង អនុប្រធានគណៈកម្មាធិការកណ្ដាលនៃបក្សកុម្មុយនីស្ដចិន។ (នៅខាងក្រោយ ប៉ុល ពត) ខៀវ សំផន ប្រមុខរដ្ឋនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ។ (ខាងស្ដាំបង្អស់ទីពីរ) នួន ជា ប្រធានរដ្ឋសភាតំណាងប្រជាជន និងជាអនុលេខាបក្សកុម្មុយនីស្ដកម្ពុជា។ កំណត់ចំណាំ៖ ហ៊ូ យ៉ាវប៉ាង លេខាជាន់ខ្ពស់គណៈកម្មាធិការកណ្ដាលនៃបក្សកុម្មុយនីស្ដចិន, អៀង សារី រដ្ឋមន្ត្រីការបរទេសនៃរបបខ្មែរក្រហម និងភរិយារបស់ខ្លួនគឺ អៀង ធីរិទ្ធ រដ្ឋមន្ត្រីសុខាភិបាល សង្គមកិច្ចនិងអប់រំ ក៏បានចូលរួមព្រឹត្តិការណ៍នេះដែរ។

នាថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ សាលាក្ដីខ្មែរក្រហម បានកាត់ទោស នួន ជា និង ខៀវ សំផន ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ឧក្រិដ្ឋកម្មខាងលើ ត្រូវបានប្រព្រឹត្តឡើងនៅតាមបណ្ដាទីតាំងផ្សេងៗគ្នានៃប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ថិតក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះបានកាត់ទោស នួន ជា និង ខៀវ សំផន ឲ្យជាប់ពន្ធនាគារមួយជីវិត។ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានស្លាប់នៅក្នុងអំឡុងពេលនៃការប្ដឹងឧទ្ធរណ៍ តបទៅនឹងការវិនិច្ឆ័យនិងការផ្ដន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណុំរឿង០០២/០២។ ប៉ុល ពត គឺជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៦ និងបានលាលែងពីតំណែងនៅក្នុងឆ្នាំ១៩៧៩ ក៏ប៉ុន្តែនៅតែជាអ្នកដឹកនាំសកម្មមួយរូបនៃរបបខ្មែរក្រហម។ ប៉ុល ពត បានរស់នៅដោយនិរទេស ភាគច្រើននៅក្នុងប្រទេសថៃ រហូតដល់បាត់បង់ជីវិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨។ សពរបស់ ប៉ុល ពត ត្រូវបានបូជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨។ ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ឲ្យធ្វើពលកម្មក្នុងសហករណ៍កម្រិតខ្ពស់របស់រដ្ឋ និងនៅតាមការដ្ឋានលើកទំនប់ជីកប្រឡាយ និងការងារពលកម្មដទៃទៀត។ ប្រជាជនត្រូវទទួលរងការរំលោភបំពានសិទ្ធិផ្ទាល់ខ្លួនយ៉ាងធ្ងន់ធ្ងរ។ ការដើរហើរនានាត្រូវបានរឹតបន្តឹង។ ប្រជាជនត្រូវបានបង្ខំឲ្យហូបបាយរួម។ ទំនាក់ទំនងគ្រួសារ ត្រូវបានរឹតត្បិតឬបំបែកបំបាក់។ ចំណែកឯការគោរពបូជាសាសនាត្រូវបានហាមឃាត់។ សេរីភាពនៃការបញ្ចេញមតិត្រូវបានរឹតបន្តឹងតាមរយៈទារុណកម្មធ្ងន់ធ្ងរនិងការគំរាមសម្លាប់។ អ្នកដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសឆ្គងនឹងត្រូវទទួលទណ្ឌកម្មដោយគ្មានការសួរនាំតាមផ្លូវច្បាប់ទេ។

ដើម្បីសម្រេចបានគោលដៅរបស់បក្សកុម្មុយនីស្ដកម្ពុជាក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យការពារជាតិនៅចន្លោះចុងឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានព្យាយាមបង្កើនចំនួនប្រជាជន តាមរយៈការបង្ខិតបង្ខំឲ្យស្ត្រីនិងបុរសរៀបការតាមការចាប់គូ និងរៀបចំដោយអង្គការ។ ជាទូទៅ គូស្រករដែលតម្រូវឲ្យរៀបការ តែងតែរៀបការទាំងហ្វូងនៅក្នុងពេលតែមួយ ដែលខុសទៅនឹងប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនកម្ពុជា។ បន្ទាប់ពីរៀបការរួច ប្ដីប្រពន្ធថ្មីថ្មោងត្រូវបានបង្ខំឲ្យសេពសន្ថវៈជា

មួយគ្នា។ ជាធម្មតា មានការរៀបចំនៅទីតាំងកំណត់ណាមួយ ដើម្បីឲ្យប្តីប្រពន្ធធ្វើការផ្សំដំណេក ហើយអង្គការជាអ្នកឃ្លាំមើលប្តីប្រពន្ធនោះ។ ប្រសិនបើប្តីប្រពន្ធណាត្រូវបានរកឃើញថាពុំបានសេពសន្ថវៈជាមួយគ្នាតាមបញ្ជារបស់អង្គការទេ ប្តីប្រពន្ធនោះនឹងត្រូវនាំយកទៅអប់រំកែប្រែ ឬរងការគំរាមកំហែងដាក់ទោស ឬត្រូវសម្លាប់។

នៅទីបំផុត ខ្មែរក្រហមជឿជាក់ថាខ្លួនអាចកំណត់ទិន្នផលកសិកម្ម និងដឹងពីសមត្ថភាពក្នុងការសម្រេចបាននូវប្រសិទ្ធភាព និងការអភិវឌ្ឍ តាមរយៈគោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្លួន។

ជាលទ្ធផលនៃការចង់សម្រេចបានគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនជាច្រើនបានបាត់បង់ជីវិតដោយសារភាពអត់ឃ្លាន ការធ្វើការហួសកម្លាំង និងជំងឺ។ លើសពីនេះទៀត ដើម្បីការពារបក្សពីការប្រឆាំងរបស់ "សត្រូវខាងក្នុងនិងសត្រូវខាងក្រៅ" ដែលកើតចេញពីការស្រមើស្រមៃ និងដោះស្រាយបរាជ័យនៃគោលនយោបាយ មហាលោតផ្លោះមហាអស្ចារ្យរបស់ខ្លួន ខ្មែរក្រហមបានបង្កើនការរឹតបន្តឹងសន្តិសុខជាតិ តាមរយៈការកំណត់គោលដៅលើអ្នកដែលត្រូវបានសង្ស័យថាបានក្បត់បក្សកុម្មុយនីស្តកម្ពុជា ដូចជា អ្នកទាំងឡាយណាដែលមានទំនាក់ទំនងជាមួយនឹងរបបមុនៗ អ្នកចេះដឹង អ្នកមានទ្រព្យសម្បត្តិ និងមេដឹកនាំសាសនា។ មនុស្សរាប់ម៉ឺននាក់ត្រូវបានឃាត់ខ្លួន ហើយជាច្រើននាក់ទៀតត្រូវបានសម្លាប់ និងទទួលរងទារុណកម្មរហូតដល់ស្លាប់នៅក្នុងគុកឬមន្ទីរអប់រំ។ ខ្មែរក្រហមមិនញញើតចំពោះការប្រើប្រាស់ទារុណកម្មយ៉ាងឃោរឃៅ ដើម្បីញុះញង់ បំបែកបំបាក់ រំលោភបំពាន និងបំផ្លិចបំផ្លាញសត្រូវដែលខ្លួនសង្ស័យឡើយ។ ខ្មែរក្រហម ក៏មិនស្ទាក់ស្ទើរចំពោះការអនុវត្តយុទ្ធនាការដ៏គួរឲ្យភ័យខ្លាចមកលើជនរងគ្រោះគ្រប់ប្រភេទដែរ។ ស្ត្រី កុមារ និងសូម្បីតែកម្មាភិបាលដ៏ប្តូរផ្តាច់របស់ខ្លួន ក៏ខ្មែរក្រហមចាប់ខ្លួនធ្វើទារុណកម្ម និងសម្លាប់ដែរ។ ក្រុមសាសនានិងជនជាតិភាគតិចក៏ត្រូវទទួលរងទុក្ខវេទនា។ ខ្មែរក្រហមបានផ្តោតគោលដៅលើពុទ្ធសាសនិក ជនជាតិចាម និងអ្នកទាំងឡាយណាដែលជាប់សែស្រឡាយវៀតណាម។ បន្ទាប់ពីជនជាតិចាមរស់នៅក្នុងភូមិចំនួន ២ បានធ្វើការបះបោរប្រឆាំងនឹងការរឹតបន្តឹងលើការប្រណិប័តន៍សាសនារួចមក ខ្មែរក្រហមបានព្យាយាមបំបែកសហគមន៍ទាំងនេះ។ ជនជាតិចាម ត្រូវបានហាមឃាត់មិនឲ្យប្រណិប័តន៍សាសនា និយាយភាសាចាម ឬស្លៀកសម្លៀកបំពាក់និងរក្សារបៀបរបបសក់តាមប្រពៃណីរបស់ខ្លួនឡើយ។ ជនជាតិចាមជាច្រើនត្រូវបានសម្លាប់នៅក្នុងតំបន់នានា ដែលជាទីតាំងប្រមូលផ្តុំនៃអ្នកទាំងនេះតាមបែបប្រពៃណីនៅតាមបណ្តោយដងទន្លេមេគង្គ។

ជារួម ប្រជាជនចំនួនប្រមាណពី ១លាន៤សែននាក់ ទៅ ២លាន ២សែននាក់ បានស្លាប់បាត់បង់ជីវិតនៅក្នុងអំឡុងពេលនៃរបបកម្ពុជាធិបតេយ្យ។

មន្ទីរសន្តិសុខចំនួនប្រមាណ ២០០ កន្លែង ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជាដើម្បីឃុំឃាំងអ្នកទោស។ ទារុណកម្មនិងការសម្លាប់គឺជាសកម្មភាពដែលតែងតែកើតមាននៅក្នុងមន្ទីរសន្តិសុខទាំងនេះ។ អ្នកទោសទទួលរងការអត់ឃ្លាន និងស្ថិតក្រោមស្ថានភាពរស់នៅដ៏លំបាក។ មន្ទីរ ស-២១ ដែលមានឈ្មោះអសោចបំផុត ស្ថិតនៅក្នុងទីក្រុងភ្នំពេញ ត្រូវបានជឿជាក់ថាបានឃុំឃាំងអ្នកទោសប្រមាណ១ម៉ឺន៨ពាន់នាក់ ក្នុងនោះអ្នកទោសភាគច្រើនត្រូវបានស្លាប់។



**កម្មាភិបាលខ្មែរក្រហម។** ប្រធានភូមិខ្មែរក្រហម និងអង្គរក្សការពាររបស់ខ្លួន (ដែលត្រូវបានស្គាល់ថា ឈ្លប)។ ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។



**ផ្ទាំងគំនូរគូរដោយវិចិត្រករស្ត្រី (គថ្លង់) មួយរូប ឈ្មោះ កែវ កុលធីតា ឯកស័ក្ក (ត្រូវបានស្គាល់ថា កុល)។** ផ្ទាំងគំនូរ បង្ហាញអំពីអ្នកដឹកនាំក្រុមខ្មែរក្រហមដែលជាស្ត្រីមួយរូប (មេកង) បានបញ្ជាឲ្យស្ត្រីជនជាតិចាមមូស្លីម ធ្វើការងារពលកម្មធ្ងន់ធ្ងរ។ (សូមមើល កុលៈ ភាពគថ្លង់ និងអំពើប្រល័យពូជសាសន៍ ចុះផ្សាយនៅលើកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤)។ ប្រភពរូបភាពៈ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ក្រៅពីមន្ទីរស-២១ ដែលជាគុកមានឈ្មោះអសោចបំផុត នៅមានមន្ទីរសន្តិសុខដទៃជាច្រើនទៀតនៅ ពាសពេញផ្ទៃប្រទេស ដូចជាមន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

មន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្នុងឃុំត្រាំកក់ គឺនៅភាគបស្ចិមនៃក្រុងតាកែវ។ អ្នកទោសដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនេះ ទទួលរងទុក្ខយ៉ាងខ្លោចផ្សា។ អ្នកទោសត្រូវបានបង្ខំឲ្យអង្គុយជាជួរៗ ជាប់ខ្នោះ និងច្រវាក់រួមគ្នាជាជួរៗនៅក្នុងបរិវេណមន្ទីរឃុំឃាំង។ អ្នកទោស តែងតែទទួលរងទារុណកម្ម សួរចម្លើយ វាយដំ វាត់នឹងរំពាត់ និងខ្ទប់ដង្ហើម។ អ្នកទោសភាគច្រើនត្រូវបានសម្លាប់។

មន្ទីរសន្តិសុខអូរកន្សែង ស្ថិតនៅក្នុងតំបន់១០២ នៃភូមិភាគឦសានឬខេត្តរតនគិរីនាពេលបច្ចុប្បន្ន។ មន្ទីរសន្តិសុខនេះដើរតួនាទីជាមន្ទីរជំនួយដល់មន្ទីរស-២១ ក្នុងគោលបំណងឃុំខ្លួនអ្នកមានទោសពុំសូវធ្ងន់ធ្ងរនៅក្នុងភូមិភាគឦសាន។ នៅក្នុងគុកនេះ វិធីសាស្ត្រនៃការធ្វើទារុណកម្មបានប្រព្រឹត្តទៅជាច្រើនសណ្ឋាន រួមទាំង ការវាយដំ, វាត់នឹងរំពាត់ និងឆក់ខ្សែភ្លើង។

មន្ទីរសន្តិសុខភ្នំក្រោល ស្ថិតនៅក្នុងតំបន់១០៥ ឬខេត្តមណ្ឌលគិរីនាពេលបច្ចុប្បន្ន។ មន្ទីរសន្តិសុខនេះរួមមានការិយាល័យ គ-១៧ និង គ-១១, គុកភ្នំក្រោល និងទីតាំងកប់សាកសពត្រពាំងព្រីង។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះ ត្រូវបានឃាត់ខ្លួនដោយពុំទទួលបានការការពារសិទ្ធិរបស់ខ្លួន និងការវិនិច្ឆ័យទោសឡើយ។ អ្នកទោសទាំងអស់ ត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងមន្ទីរសន្តិសុខ ដែលជាផ្នែកមួយនៃការដាក់ទណ្ឌកម្ម។



**បន្ទាប់ពីវាលពិឃាដ (ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩)។**

រូបភាពរណ្តៅសាកសពចំនួនពីរ ដែលត្រូវបានរុករកឃើញបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩។ រណ្តៅសាកសពប្រមាណ ២ម៉ឺន កន្លែង ស្ថិតនៅតាមបណ្តាទីជនបទ។ បន្ទាប់ពីឆ្នាំ១៩៧៩ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានប្រមែប្រមូលឆ្អឹងរបស់អ្នកជាទីស្រឡាញ់របស់ខ្លួនដែលបានបាត់បង់ជីវិត និងដាក់តម្កល់នៅបូជនីយដ្ឋានមួយស្ថិតនៅក្បែរផ្ទះសម្បែងរបស់ខ្លួន។ ទិវារំឭកអំពីការចងចាំដល់អដ្ឋិធាតុដែលបន្សល់ពីរណ្តៅសាកសពទាំងអស់នេះ តែងតែប្រព្រឹត្តិធ្វើឡើងនៅថ្ងៃទី ២០ ខែ ឧសភា ដែលត្រូវបានស្គាល់ថាជា «ទិវានៃការចងចាំ»។

ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។



ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០មក ជម្លោះម្តងម្កាលបានកើតមានឡើងរវាងក្រុមកុម្មុយនីស្តវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ។ ជម្លោះធ្ងន់ធ្ងរ បានកើតមានឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលដែលកងកម្លាំងខ្មែរក្រហម បានបាញ់ផ្លោងនិងឈ្លានពានខេត្តមួយចំនួនរបស់វៀតណាម។ ប្រឈមទៅនឹងការបំពានជាបន្តបន្ទាប់នេះ វៀតណាមបានសម្រេចចិត្តតបតវិញ។ កងកម្លាំងវៀតណាមបានជ្រៀតចូលទៅក្នុងផ្នែកនានានៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៧។ រហូតមកដល់ខែមករា ឆ្នាំ១៩៧៨ កងកម្លាំងវៀតណាមបានដកថយ។ ចាប់តាំងពីខែឧសភា ឆ្នាំ១៩៧៨ របប ប៉ុល ពត បានបង្កសង្គ្រាមនៅភូមិភាគបូព៌ា រួមជាមួយនឹងការសម្លាប់រង្គាលមកលើយោធាខ្មែរក្រហមភូមិភាគបូព៌ា ដោយសារការបំផុសបំផុលសតិអារម្មណ៍ និងភាពភ័យខ្លាចចំពោះការក្បត់ផ្ទៃក្នុងបក្ស។ សង្គ្រាមនេះ រួមបញ្ចូលទាំងការវាយលុកឥតឈប់ឈរទៅក្នុងប្រទេសវៀតណាម ដែលនាំឲ្យមានការកកើតកម្លាំងប្រឆាំង ក្រោមការគាំទ្រពីវៀតណាម។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមបានចាប់ផ្តើមបាញ់ផ្លោងមកលើកម្ពុជាប្រជាធិបតយ្យវិញ និងនៅក្នុងខែតុលា ឆ្នាំ១៩៧៨ វៀតណាមបានចាប់ផ្តើមរៀបចំការវាយប្រហារទ្រង់ទ្រាយធំ។ នៅចុងបញ្ចប់ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងវៀតណាមបានចាប់ផ្តើមការវាយប្រហារទ្រង់ទ្រាយធំមកលើរបបកម្ពុជាប្រជាធិបតេយ្យ។ កងកម្លាំងវៀតណាម និងកងកម្លាំងប្រឆាំង គឺរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយសន្ធប់មកលើកងកម្លាំងខ្មែរក្រហម តាមរយៈការបាញ់ផ្លោង ការប្រើប្រាស់កាំភ្លើងតូចធំ និងការពង្រាយកងកម្លាំងនៅពាសពេញទីតាំងប្រយុទ្ធជាច្រើន។ ត្រឹមរយៈពេល៣សប្តាហ៍តែប៉ុណ្ណោះ កងកម្លាំងវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលកាន់កាប់ទីក្រុងភ្នំពេញ គឺនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយក្នុងរយៈពេលត្រឹមតែ១០ថ្ងៃ កងកម្លាំងទាំងពីរបានគ្រប់គ្រងប្រទេសកម្ពុជាស្ទើរតែទាំងស្រុង។ វៀតណាម បានរួមចំណែកក្នុងការបង្កើតរបបថ្មីមួយ គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ ដោយមានសមមិត្ត ហេង សំរិន គឺជាប្រធាន, សមមិត្ត ប៉ែន សុវណ្ណ គឺជានាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការពារជាតិ និងសមមិត្ត ហ៊ុន សែន គឺជារដ្ឋមន្ត្រីការបរទេស។




**ការពិត៖ កម្ពុជា និងវៀតណាម៖ សាមគ្គី យើងឈ្នះ។ បើគ្មានសាមគ្គីភាព យើងចាញ់។**

ផ្ទាំងផ្សព្វផ្សាយ បង្កើតឡើងដោយសិល្បករកម្ពុជា បង្ហាញអំពីកងទ័ពកម្ពុជានិងកងទ័ពវៀតណាម បណ្តេញខ្មែរក្រហមចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩។

ផ្ទាំងផ្សព្វផ្សាយនេះត្រូវបានបោះពុម្ពដោយក្រសួងឃោសនាការ ព័ត៌មាន និងវប្បធម៌នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០។

ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។



# តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម (សាលាក្តីខ្មែរក្រហម)

**សាលាក្តីខ្មែរក្រហម។** រូបថតមួយសន្លឹក ថតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ពីឆ្វេងទៅស្តាំ) វីល្លៀម ស្មីត អនុសហព្រះរាជអាជ្ញាអន្តរជាតិ, តារីក អាប់ឌុលហាក់ ជំនួយការព្រះរាជអាជ្ញាអន្តរជាតិ, អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ, សេង ប៊ុនឃាង ជំនួយការសហព្រះរាជអាជ្ញាជាតិ និង ជា លាង សហព្រះរាជអាជ្ញាជាតិ។ អេនឌ្រូ ខេលី បានបំពេញមុខងារជាសហព្រះរាជអាជ្ញាអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ពីខែធ្នូ ឆ្នាំ២០០៩ ដល់ខែកញ្ញា ឆ្នាំ២០១៣។ លោកធ្លាប់បានបំពេញមុខងារជាទីប្រឹក្សាព្រះរាជអាជ្ញានៅក្នុងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ ជា លាង គឺជាសហព្រះរាជអាជ្ញាជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកស្រីបានចាប់ផ្តើមអាជីពផ្នែកច្បាប់របស់ខ្លួននៅឯក្រសួងយុត្តិធម៌របស់កម្ពុជា និងមកទល់ឆ្នាំ ២០១៩ លោកស្រីបានបន្តបំពេញមុខងារជាសហព្រះរាជអាជ្ញាជាតិ។ ប្រភពរូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ក្នុង ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រុមអ្នកជំនាញនៃអង្គការសហប្រជាជាតិបានមកកាន់ប្រទេសកម្ពុជា និងប្រទេសថៃ ដើម្បីកំណត់អំពីប្រភេទនៃឧក្រិដ្ឋកម្មដែលបានកើតមាននៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ អ្នកជំនាញបានរកឃើញថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីហេតុផលលើនិតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម។ ការខ្វែងគំនិតគ្នាលើមធ្យោបាយដ៏ល្អបំផុតដើម្បីបន្តនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជា ជម្លោះដែលកំពុងបន្តកើតមានឡើងរវាងយោធាខ្មែរក្រហម និងរាជរដ្ឋាភិបាលបានធ្វើឲ្យមានការរាំងស្ទះដល់ដំណើរការនៃកិច្ចខិតខំប្រឹងប្រែងនេះ។ ទីបំផុត នៅក្នុងឆ្នាំ២០០៣ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានធ្វើឡើង ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការចម្រុះរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ ស្ថិតក្រោមកិច្ចព្រមព្រៀងនេះ កម្ពុជាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមលំនាំច្បាប់ក្នុងស្រុក។ ប៉ុន្តែតុលាការនេះនឹងប្រព្រឹត្តទៅតាមបទដ្ឋានអន្តរជាតិ និងរួមបញ្ចូលទាំងការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក ដែលកើតមានឡើងក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ចាប់តាំងពី

អង្គជំនុំជម្រះនេះចាប់ផ្តើមប្រតិបត្តិការការងាររបស់ខ្លួនមក មេដឹកនាំខ្មែរក្រហមកំពូលៗចំនួន៣រូប ត្រូវបានកាត់ទោសនិងផ្តន្ទាទោស។ នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន អតីតប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទង្វើអមនុស្សធម៌ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ការសម្រេចផ្តន្ទាទោសដែលបានប្រព្រឹត្តទៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ត្រូវបានប្តឹងឧទ្ធរណ៍តាំងពីថ្ងៃប្រកាសសាលក្រមមកម្ល៉េះ នេះបើគិតនៅត្រឹមថ្ងៃដែលសៀវភៅនេះត្រូវបានរៀបរៀងឡើង។ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានស្លាប់នៅក្នុងអំឡុងពេលនៃការប្តឹងឧទ្ធរណ៍ តបទៅនឹងការវិនិច្ឆ័យនិងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណុំរឿង០០២/០២។ នៅថ្ងៃទី១៣ ខែសីហា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការស្លាប់របស់ នួន ជា បញ្ចប់រាល់បទឧក្រិដ្ឋត្រូវបានដាក់លើ នួន ជា ហើយការស្លាប់នេះក៏បញ្ចប់រាល់ដំណើរការយុត្តាធិការទាំងអស់ចំពោះ នួន ជា នៅមុខអង្គជំនុំជម្រះតុលាការកំពូល។ ខៀវ សំផន នៅតែបន្តបណ្តឹងឧទ្ធរណ៍លើការវិនិច្ឆ័យចំពោះសំណុំរឿង០០២/០២។ កាំង ហ្គេកអ៊ាវ ហៅឌុច ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅមន្ទីរស-២១ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) តើកត្តាអ្វីខ្លះដែលបង្ក ឬបង្កើនហានិភ័យនៃអំពើប្រល័យពូជសាសន៍?

២) តើមានវិធីសាស្ត្រអ្វីខ្លះដែលសង្គមអាចទប់ស្កាត់ការកកើតអំពើប្រល័យពូជសាសន៍?

៣) តើមានវិធីសាស្ត្រអ្វីខ្លះ ដែលបុគ្គលអាចចូលរួមក្នុងការទប់ស្កាត់ការកកើតអំពើប្រល័យពូជសាសន៍?

### សំណួរដែលមានចម្លើយខ្លី

៤) តើនរណាជាអ្នកហៅក្រុមខ្មែរក្រហមថា "ខ្មែរក្រហម"?

៥) នៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ ចូលរួមជាមួយខ្មែរក្រហមក្នុងឆ្នាំ១៩៧០ តើសកម្មភាពរបស់ព្រះអង្គមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះកិច្ចប្រឹងប្រែងជ្រើសរើសសមាជិកថ្មីរបស់ខ្មែរក្រហម?

៦) ចូរពិពណ៌នាអំពីគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា?

៧) ចូររៀបរាប់ពីក្រុមមនុស្សដែលជាក្រុមគោលដៅរបស់កម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ឲ្យបាន៣ប្រភេទ។

៨) រហូតមកដល់ត្រឹមឆ្នាំ២០១៨មេដឹកនាំកំពូលខ្មែរក្រហម៣រូបត្រូវបានចោទប្រកាន់, កាត់ទោស និងផ្តន្ទាទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ តើអ្នកទាំងនោះគឺជានរណា ហើយត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋអ្វីខ្លះ?




## វាលពិឃាដក្នុងប្រទេសកម្ពុជា (១៩៧៥-១៩៧៩)

វាលពិឃាដក្នុងប្រទេសកម្ពុជា (១៩៧៥-១៩៧៩)។ មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់ប្រព័ន្ធផ្កាយរណបកំណត់ទីតាំងជាសកល (GPS) ដើម្បីដៅទីតាំងរណ្តៅសាកសព គួបផ្សំបន្ថែមលើការងារចងក្រងឯកសារនៅតាមមូលដ្ឋានទូទាំងប្រទេស។ សព្វថ្ងៃ មជ្ឈមណ្ឌលឯកសារកម្ពុជាបានដៅទីតាំងនៃអំពើប្រល័យពូជសាសន៍ចំនួន ៣៩០ កន្លែង ក្នុងនោះរួមមាន  រណ្តៅសាកសពប្រមាណជាង២ម៉ឺនកន្លែង ដែលកើតមាននៅក្នុងរបបខ្មែរក្រហម។ (មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់និយមន័យរណ្តៅសាកសពរួម ថាជារណ្តៅទាំងឡាយណាដែលមានសាកសពចំនួនចាប់ពី៤ឡើងទៅ ទោះបីជារណ្តៅខ្លះអាចផ្ទុកសាកសពលើសពី១000 ក៏ដោយ)។ បន្ថែមលើសពីនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានចងក្រងឯកសារទាក់ទងនឹងគុកចំនួន ១៩៧ កន្លែង បន្សល់ពីរបបកម្ពុជាប្រជាធិបតេយ្យ និងបូជនីយដ្ឋានរំឭកពីអំពើប្រល័យពូជសាសន៍ចំនួន ៨១ទីតាំង។ (ទិន្នន័យ៖ ផេង ពង្សរ៉ាស៊ី, ផែនទី៖ លី កុកឆាយ)



វាលពិឃាតនៅកម្ពុជា ឆ្នាំ១៩៧៥-១៩៧៩
CAMBODIA'S KILLING FIELDS 1975 - 1979
បូជនីយដ្ឋាន (Memorial) : 81 ទីតាំង (Site)
គុក (Prison) : 197 ទីតាំង (Site)
រណ្ដៅសាកសពរួម (Mass Grave) : 390 ទីតាំង (Site)
0 - 2100 សាកសព (Bodies)
2101 - 6000 សាកសព (Bodies)
6001 - 13000 សាកសព (Bodies)
13001 - 25000 សាកសព (Bodies)
25001 - 70000 សាកសព (Bodies)
STUENG TRAENG
RATANAK KIRI
MONDOL KIRI
KRATIE
PREAH VIHEAR
TBOUNG KHMUM
KAMPONG CHAM
TAY NINH
BINH PHUOC
BINH DUONG
DONG THAP
Muang Không
Stoeng Trêng
Senmonorom
Krâchéh
Kampong Cham
Tây Ninh
Dôn Luân
Ho Chi Minh City
13
7
1
22



**ដៃចាប់ដៃ**

បុរាណវិទូមួយរូបចាប់ដៃរបស់ជនរងគ្រោះម្នាក់នៅឯរណ្តៅសាកសព ដែលផ្ទុកសាកសពចំនួន ៥០៦ ត្រូវបានរកឃើញនៅតំបន់កាមេនីសា នៅក្បែរតំបន់ស្វ៊រនីក ក្នុងសាធារណរដ្ឋស្រឹបស្កា។ រូបភាពនេះត្រូវបានថតដោយអ្នកថតរូបជនជាតិបូស្ន៊ី ដែលល្បីល្បាញលំដាប់ពិភពលោក គឺលោក ថារីក សាម៉ារ៉ាហ៍ ដែលជាអ្នកចងក្រងឯកសារអំពីសំណល់នៃអំពើប្រល័យពូជសាសន៍ ដែលកើតមានឡើងនៅក្នុងទីក្រុងស្រ៊ីប្រ៊ីនីសា ប្រទេសបូស្ន៊ី-ហឺហ្សីហ្គោវីន។ រូបថតរបស់លោក ត្រូវបានដាក់តាំងពិព័រណ៌នៅវិចិត្រសាល សារមន្ទីរ និងទីតាំងសាធារណៈ ដ៏ល្បីឈ្មោះជាច្រើន នៅទូទាំងពិភពលោក។ រូបភាពនេះត្រូវបានប្រគល់ជាអំណោយដ៏សប្បុរសមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជារូបបង្ហាញនៅក្នុងជំពូកសៀវភៅស្តីពីសង្គ្រាមនៅក្នុងអតីតយូហ្គោស្លាវី និងបូស្ន៊ី-ហឺហ្សីហ្គោវីន។

រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយលោក ថារីក សាម៉ារ៉ាហ៍។

# ប្រទេស បូស្នី-ហឺហ្ស៊ីហ្គោវីន

បណ្ឌិត លី សុខឃាង

ប្រទេសបូស្នី-ហឺហ្ស៊ីហ្គោវីន បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនពីប្រទេសយូហ្គោស្លាវី នៅក្នុងខែតុលា ឆ្នាំ១៩៩១។ ដោយមានការគាំទ្រពីសំណាក់រដ្ឋាភិបាលស៊ែប និងម៉ុងតេណេហ្គ្រោ កងជីវពល បូស្នី-ស៊ែប បានចាប់ផ្តើមតស៊ូប្រដាប់អាវុធក្នុងគោលបំណងបំបែកសាធារណរដ្ឋទៅតាមក្រុមជាតិពន្ធនីមួយៗ។ មេដឹកនាំស៊ែបនៃតំបន់ផ្តាច់ខ្លួនទាំងនេះ បានចាត់ទុកប្រជាជនមូស្លីម-បូស្នី ក្រូអាត-បូស្នី (កាន់សាសនាកាតូលិក) ថាជាឧបសគ្គចំពោះការបង្កើតជារដ្ឋស៊ែប។ កត្តានេះ បង្កើតបានជាគោលនយោបាយលុបបំបាត់ជាអចិន្ត្រៃយ៍ ឬការបោសសម្អាតជាតិពន្ធ ដែលជាជនជាតិ បូស្នី-មូស្លីម និងជនជាតិ បូស្នី-ក្រូអាត។

អស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមក តំបន់យូហ្គោស្លាវី គឺជាជម្រកនៃសាសនា និងវប្បធម៌ចម្រុះ។ សាសនាឥស្លាម សាសនាគ្រិស្តបែបបុរាណ សាសនារ៉ូម៉ាំងកាតូលិក និងសាសនាគ្រិស្តប្រូតេស្តង់ ក៏ដូចជាសាសនាជ្វីហ្វ ព្រមទាំងសាសនាធំៗដទៃទៀត បានរីករាលដាលពាសពេញតំបន់។ នៅពេលខ្លះអ្នកកាន់សាសនាទាំងនោះ បានប្រមូលផ្តុំគ្នាជាសហគមន៍យ៉ាងជិតស្និទ្ធទៀតផង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រទេសយូហ្គោស្លាវី ទើបតែកកើតឡើងជាព្រះរាជាណាចក្រស៊ែប, ក្រូអាត និងស្លូវេនី បន្ទាប់ពីសង្គ្រាមលោកលើកទី១តែប៉ុណ្ណោះ។ បន្ទាប់ពីសង្គ្រាមលោកលើកទី២កន្លងផុតទៅ ប្រទេសនេះបានប្តូរទៅជារដ្ឋកុម្មុយនីស្ត ដែលក្រោយមកត្រូវបានស្គាល់ថាជាសហព័ន្ធសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវី។ សហព័ន្ធសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវីរួមបញ្ចូលប្រទេសសាធារណរដ្ឋចំនួន ៦ គឺ បូស្នី-ហឺហ្ស៊ីហ្គោវីន, ក្រូអាស៊ី, ម៉ាសេដ្វាន, ម៉ុងតេណេហ្គ្រោ, ស៊ែប និងស្លូវេនី និងខេត្តចំនួនពីរទៀតគឺ កូសូវ៉ូ និងវ៉ូយវ៉ូឌីណា។ ចាប់ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៨០ ប្រធានាធិបតី ចូស៊ីប ប្រូហ្ស៊ទីតូ បានគ្រប់គ្រងសហព័ន្ធសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវី តាមបែបផ្តាច់ការ ដែលបានទប់ស្កាត់ការបែងចែកយ៉ាងខ្លាំងក្លា ក្នុងចំណោមក្រុមជាតិពន្ធនៅក្នុងប្រទេស មិនឲ្យឈានដល់ការកើតមានជម្លោះហិង្សា។ បន្ទាប់ពីមរណភាពរបស់ ទីតូ ប្រទេសយូហ្គោស្លាវីបានផ្លាស់ប្តូរទៅជាសហព័ន្ធសាធារណរដ្ឋរហូតដល់ឆ្នាំ១៩៩២ នៅពេលដែលសង្គ្រាមរវាងជាតិពន្ធបានកើតមានឡើង និងនាំទៅរកការបែកបាក់រដ្ឋយូហ្គោស្លាវី។

បន្ទាប់ពី ទីតូ ទទួលមរណភាព វិបត្តិសេដ្ឋកិច្ចនិងភាពចលាចលក្នុងប្រទេសបានបង្កទៅជាចលនាជាតិនិយមក្នុងចំណោមក្រុមជាតិពន្ធធំៗ។ សែប, ក្រូអាត, ស្លូវេនី និងក្រុមជាតិពន្ធធំៗដទៃទៀត បានចាប់ផ្តើមទាមទារឯករាជ្យភាពពីរដ្ឋសហព័ន្ធ។ ការកកើតឡើងនូវចលនាជាតិនិយមនិងការបែកបាក់រដ្ឋយូហ្គោស្លាវី បាននាំឲ្យមានសង្គ្រាមនិងការងើបបះបោរជាបន្តបន្ទាប់ នៅក្នុងអតីតសាធារណរដ្ឋយូហ្គោស្លាវី ដែលឈានទៅដល់ការប្រព្រឹត្តអំពើអមនុស្សធម៌ព្រៃផ្សៃ ការសម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍។

បូស្នី-ហឺហ្សេហ្គោវីន បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនពីយូហ្គោស្លាវី នៅក្នុងខែតុលា ឆ្នាំ១៩៩១។ នៅក្នុងខែឧសភា ឆ្នាំ១៩៩២ ការបោះឆ្នោតមួយត្រូវបានរៀបចំឡើង ដែលនាំឲ្យមានការប្រកាសឯករាជ្យភាព។ ដោយមានការគាំទ្រពីសំណាក់រដ្ឋាភិបាលសែប និងម៉ុងតេណេហ្គ្រោ កងជីវពល បូស្នី-សែប បានចាប់ផ្តើមតស៊ូប្រដាប់អាវុធក្នុងគោលបំណងបំបែកសាធារណរដ្ឋទៅតាមក្រុមជាតិពន្ធនីមួយៗ។ តំបន់បូស្នី-សែប បានវិវឌ្ឍទៅជាផ្នែកមួយនៃការផ្តាច់ខ្លួនក្នុងនាមជាសាធារណរដ្ឋសែប។ មេដឹកនាំសែបនៃតំបន់ផ្តាច់ខ្លួនទាំងនេះ បានចាត់ទុកប្រជាជនមូស្លីម-បូស្នី ក្រូអាត-បូស្នី (កាន់សាសនាកាតូលិក) ថាជាឧបសគ្គចំពោះការបង្កើតជារដ្ឋសែប។ កត្តានេះ បង្កើតបានជាគោលនយោបាយលុបបំបាត់ជាអចិន្ត្រៃយ៍ ឬការបោសសម្អាតជាតិពន្ធ[៣] ដែលជាជនជាតិបូស្នី-មូស្លីម និងជនជាតិ បូស្នី-ក្រូអាត។ ជនជាតិ បូស្នី-មូស្លីម និងជនជាតិបូស្នី-ក្រូអាតរាប់ម៉ឺននាក់ត្រូវបានឃុំខ្លួននៅក្នុងជំរំឃុំឃាំង ជាកន្លែងដែលអ្នកទាំងនោះត្រូវបានរំលោភបំពាន បង្អត់អាហារ និងសម្លាប់។ អំពើរំលោភសេពសន្ថវៈនិងទារុណកម្មបានកើតមានជាទូទៅនៅក្នុងជំរំឃុំឃាំងទាំងនេះ។

ព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងយុទ្ធនាការបោសសម្អាតក្រុមជាតិពន្ធរបស់សែប បានកើតមាននៅជុំវិញទីក្រុងស្រីប្រីនីសា ដែលជាទីតាំងដ៏សំខាន់សម្រាប់ជនជាតិសែប ពីព្រោះទីតាំងយុទ្ធសាស្ត្រនេះស្ថិតនៅក្នុងតំបន់គ្រប់គ្រងរបស់ជនជាតិសែប។ ការសម្លាប់រង្គាលនិងស្ថានភាពនៅក្នុងទីក្រុងស្រីប្រីនីសា បានជំរុញឲ្យអង្គការសហប្រជាជាតិប្រកាសថា ទីក្រុងស្រីប្រីនីសាគឺជាទីតាំងសុវត្ថិភាពក្នុងតំបន់ជម្លោះ បូស្នី-ហឺហ្សេហ្គោវីន នៅខែមេសា ឆ្នាំ១៩៩៣។ បេតនានៃការប្រកាសរបស់អង្គការសហប្រជាជាតិ ត្រូវបានធ្វើឡើងដើម្បីធានាឲ្យបាននូវទីតាំងសុវត្ថិភាពមួយសម្រាប់ជនស៊ីវិលដែលភៀសខ្លួនចេញពីសង្គ្រាម។ យោងតាមសេចក្តីសម្រេចលេខ៨១៩ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានឲ្យដឹងថា ទីក្រុងស្រីប្រីនីសានឹងរួចផុតពីការវាយប្រហារប្រដាប់អាវុធរបស់កងទ័ព ឬអំពើប្រទូស្តរ៉ាយផ្សេងៗ។ យ៉ាងណាក៏ដោយ កងកម្លាំង បូស្នី-សែប នៅតែវាយប្រហារលើតំបន់ជុំវិញទីក្រុងស្រីប្រីនីសាដដែល។ ការសម្លាប់ត្រូវបានប្រព្រឹត្តឡើងដោយកងយោធា បូស្នី ដោយមានការបញ្ជាពីសំណាក់ រ៉ាត់កូ ម្ល៉ាឌិក។ ក្នុងរយៈពេលត្រឹមតែ៥ថ្ងៃ ទាហានសែបបានសម្លាប់ជាប្រព័ន្ធលើបុរសនិងកុមារាចំនួន៧ពាន់នាក់នៅតាមវាលស្រែ សាលារៀន និងឃ្លាំងផ្ទុកទំនិញ។

សង្គ្រាមដែលកើតមានបន្ទាប់ពីការដួលរលំសហព័ន្ធយូហ្គោស្លាវីបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩១ ដោយមានការប្រកាសឯករាជ្យភាពរបស់ស្លូវេនី។ នៅចន្លោះឆ្នាំ១៩៩២និងឆ្នាំ១៩៩៩ ជម្លោះបានកើតមាននៅក្រូអាស៊ី បូស្នី-ហឺហ្សេហ្គោវីន និងកូសូវ៉ូ។ នៅចន្លោះឆ្នាំ២០០០និង២០០១ ម៉ាសេដ្វានជួបប្រទះនូវជម្លោះផ្ទៃក្នុងជាមួយនឹងក្រុមបះបោរជនជាតិអាល់បានី។

---

[៣] ការបោសសម្អាតជាតិពន្ធ មិនត្រូវបានកំណត់ថា ជាឧក្រិដ្ឋកម្មដាច់ដោយឡែកក្រោមច្បាប់អន្តរជាតិទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការបោសសម្អាតជាតិពន្ធនេះរួមបញ្ចូលអំពើទាំងឡាយណាដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលអាចមានន័យស្មើនឹងអំពើសម្លាប់រង្គាលដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម។



បណ្តុំអគារលំនៅដ្ឋានមួយក្នុងចំណោមអគារជាច្រើនទៀត នៅក្នុងទីក្រុងសារ៉ាយ៉េវ៉ូ (រដ្ឋធានីនៃប្រទេសបូស្នី-ហឺហ្សីហ្គោវីន) ដែលត្រូវបានបំផ្លាញនៅក្នុងអំឡុងសង្គ្រាមនៅក្នុងប្រទេសបូស្នី-ហឺហ្សីហ្គោវីន។ រូបភាពត្រូវបានថតដោយ ពលបាល ល្វីស ប្រឺសេស៊ី កងទ័ពជើងអាកាសសហរដ្ឋអាមេរិក។

ជាច្រើនឆ្នាំក្រោយមក តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានរកឃើញថាបុគ្គលជាច្រើនមានពិរុទ្ធភាពលើឧក្រិដ្ឋកម្មសង្គ្រាម[៤] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៥] និងអំពើប្រល័យពូជសាសន៍។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការយុត្តិធម៌អន្តរជាតិ (ដែលបើកសវនាការស្តាប់ក្តីស្តីអំពីជម្លោះរវាងរដ្ឋនិងរដ្ឋ) បានរកឃើញថាការសម្លាប់បុរសនិងកុមារ ជនជាតិបូស្នី-មូស្លីមចំនួនជាង៨ពាន់នាក់ ជាអំពើប្រល័យពូជសាសន៍ បន្ទាប់ពីកងកម្លាំងស៊ែបបានដណ្តើមកាន់កាប់ទីក្រុងស្រ៊ីប្រ៊ីនីសា។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩១ បូស្នី-ហឺហ្សីហ្គោវីន បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនពីប្រទេសយូហ្គោស្លាវី និងបន្ទាប់មកប្រកាសនូវឯករាជ្យភាព។ តើយោធា បូស្នី-ស៊ែប មានប្រតិកម្មចំពោះព្រឹត្តិការណ៍នេះយ៉ាងដូចម្តេចខ្លះ?

២) ចលនាដ៏សំខាន់មួយនៅក្នុងជម្លោះ បូស្នី-ហឺហ្សីហ្គោវីន កើតមាននៅជុំវិញទីក្រុងស្រ៊ីប្រ៊ីនីសា។ តើមានអ្វីកើតឡើងខ្លះនៅទីក្រុងនេះ?

៣) ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដើម្បីជំនុំជម្រះទោសលើបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សជាតិអន្តរជាតិ ដែលប្រព្រឹត្តឡើងនៅក្នុងដែនដីនៃអតីតប្រទេសយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ១៩៩១។ តើមានបទឧក្រិដ្ឋកម្មណាខ្លះ ដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានលើកយកមកជំនុំជម្រះ?

---

[៤] ឧក្រិដ្ឋកម្មសង្គ្រាមសំដៅលើបទឧក្រិដ្ឋកម្មទាំងឡាយណាប្រព្រឹត្តទៅលើជនរងគ្រោះដែលជាយុទ្ធជននិងជនស៊ីវិល។ នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បានការពារដល់ (១) សមាជិកកងកម្លាំងប្រដាប់អាវុធដែលមានជំងឺឬរងរបួសនៅសមរភូមិ។ (២) សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលមានជំងឺ រងរបួស ឬលិចនាវានៅលើសមុទ្រ។ (៣) ឈ្លើយសឹក។ (៤)បុគ្គលដែលទទួលបានការការពារ រួមមានបុគ្គលិកសុខាភិបាល និង (៥)ជនស៊ីវិល។

[៥] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលអំពើទាំងឡាយណាដែលជាផ្នែកមួយនៃការវាយប្រហារ ដែលរីករាលដាល ឬមានទម្រង់ជាប្រព័ន្ធ ផ្តោតជាសំខាន់លើក្រុមប្រជាជនស៊ីវិល។

## មេរៀនលម្អិត

បន្ទាប់ពីសង្គ្រាមលោកលើកទី១បានបញ្ចប់ ប្រទេសយូហ្គោស្លាវីបានកកើតជាព្រះរាជាណាចក្រស៊ែប, ក្រូអាត និងស្លូវេនី។ ប្រទេសនេះបានប្រើប្រាស់ឈ្មោះ យូហ្គោស្លាវី នៅក្នុងឆ្នាំ១៩២៩ ហើយក្រោយមកទៀត ប្រទេសនេះបានផ្លាស់ប្តូរទៅជាសហព័ន្ធមួយដែលរួមបញ្ចូលសាធារណរដ្ឋចំនួន៦គឺ ស៊ែប, ក្រូអាត, បូស្នី-ម៉ូស្លីម, អាល់បានី, ស្លូវេនី និងរដ្ឋដទៃទៀត។ តំបន់នេះគឺជាជម្រកនៃសាសនា និងវប្បធម៌ចម្រុះដ៏សម្បូរបែប។ សាសនិកឥស្លាម, សាសនិកគ្រិស្តបែបបុរាណ, សាសនិករ៉ូម៉ាំងកាតូលិក និងសាសនិកគ្រិស្តប្រូតេស្តង់ ក៏ដូចជាសាសនិកជ្វីហ្វ ព្រមទាំងសាសនិកនៃសាសនាធំៗដទៃទៀត បានរីកសាយភាយពាសពេញតំបន់នេះ ហើយជួនកាលបានប្រមូលផ្តុំគ្នាជាសហគមន៍យ៉ាងជិតស្និទ្ធទៀតផង។

បន្ទាប់ពីសង្គ្រាមលោកលើកទី២ ប្រទេសនេះបានជ្រើសយករបបកុម្មុយនីស្តដើម្បីបម្រើដល់មនោគមន៍វិជ្ជារបស់ខ្លួន។ ក្រោមរបបគ្រប់គ្រងរបស់សេនាប្រមុខ ចូស៊ីប ប្រូហ្សទីតូ ឯករាជ្យភាពនៃសាធារណរដ្ឋដទៃទៀតរបស់ប្រទេសយូហ្គោស្លាវី នឹងអាចបង្រួបបង្រួមបាននៅក្រោមរដ្ឋាភិបាលដ៏រឹងមាំមួយ ដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្ត និងដឹកនាំដោយ ទីតូ។

ក្នុងឆ្នាំ១៩៦៣ យូហ្គោស្លាវីបានផ្លាស់ប្តូរឈ្មោះទៅជា សហព័ន្ធសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវី ដែលមាន ទីតូ ជាប្រធានាធិបតីអស់មួយជីវិត។ ទស្សនៈយល់ឃើញខាងប្រវត្តិសាស្ត្រទាក់ទងនឹងការគ្រប់គ្រងរបស់ ទីតូ លើយូហ្គោស្លាវី គឺមានភាពខុសៗពីគ្នា។ ចាប់តាំងពីពេលដែល ទីតូ ឡើងកាន់អំណាចរហូតដល់ពេលទទួលមរណភាពនៅក្នុងឆ្នាំ១៩៨០ ទីតូត្រូវបានគេចាត់ទុកថាជាមេដឹកនាំផ្តាច់ការ។ យ៉ាងណាមិញ រដ្ឋាភិបាលរបស់ ទីតូ ក៏ត្រូវបានទទួលស្គាល់ថា ជារដ្ឋាភិបាលដែលមានសមត្ថភាពក្នុងការរក្សាបាននូវសន្តិភាពវិជ្ជមានក្នុងចំណោមប្រជាជាតិរបស់សហព័ន្ធយូហ្គោស្លាវី។ ទោះបីជារដ្ឋាភិបាលរបស់ ទីតូ បានអនុវត្តគោលនយោបាយបែបមជ្ឈការយ៉ាងណាក៏ដោយ ក៏ ទីតូ បានដាក់ចេញនូវគោលនយោបាយបែបវិមជ្ឈការ ដែលក្រុមមេដឹកនាំនៅក្នុងតំបន់និងក្នុងប្រទេសទទួលបាននូវស្វ័យភាពយ៉ាងច្រើនក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ការដឹកនាំរបស់ ទីតូ អាចធានាបាននូវ "ការរស់រាននៃក្រុមជាតិពន្ធុនិងភាសាដែលមានលក្ខណៈចម្រុះ"។

ការគ្រប់គ្រងរបស់ ទីតូ អាចនៅឋិតថេរបាន ដោយសារការប្រើប្រាស់វិធីគាបសង្កត់ផ្នែកយោធា និង នគរបាល ដែលកំណត់បទដ្ឋានមួយសម្រាប់ចក្ខុវិស័យរបស់អ្នកដឹកនាំ ក្នុងការគ្រប់គ្រងនាពេលអនាគត។ មនុស្សមួយចំនួនជឿជាក់ថា វិធីសាស្ត្រប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ក៏ដូចជា ប្រឆាំងនឹងទំនើបកម្មក្នុងអំឡុងនៃការគ្រប់គ្រងរបស់ ទីតូ គឺជាកត្តាជំរុញឲ្យមានការបែកខ្ញែកប្រទេសយូហ្គោស្លាវី និងសង្គ្រាមស៊ីវិលបង្ហូរឈាមដែលកើតមានជាបន្តបន្ទាប់។ ទីតូ ពុំបានបណ្តុះអ្នកបន្តតំណែងរបស់ខ្លួនទេ។ ចំណែកឯការដឹកនាំបន្តពី ទីតូ គឺអនុវត្តតាមរបៀបវារៈនយោបាយបែបជាតិនិយមចាស់គំរឹល ដែលផ្តោតលើការប្រកួតប្រជែងក្នុងតំបន់និងរវាងក្រុមជាតិពន្ធុ។ ក្នុងខែមករា ឆ្នាំ១៩៩០ បក្សកុម្មុយនីស្តបានប្រេះស្រាំទៅតាមជាតិសាសន៍នីមួយៗ។ ភាពប្រេះស្រាំនៃបក្សកុម្មុយនីស្តយូហ្គោស្លាវី ជំរុញឲ្យមានការប្រកាសឯករាជ្យភាព ដោយស្លូវេនីចាប់ផ្តើមមុនបង្អស់ ហើយក្រោយមកទៀតគឺក្រូអាស៊ីនៅក្នុងរដូវក្តៅឆ្នាំ១៩៩០។ បន្ទាប់ពីការប្រកាសឯករាជ្យភាពរបស់ស្លូវេនី និងក្រូអាស៊ី ពីយូហ្គោស្លាវី ភាពប្រេះស្រាំបានកើតមានឡើងរវាងសមាជិកស៊ែបនៃសភារបស់ បូស្នី-ហឺហ្ស៊ីហ្គោវីន ជាមួយនឹងសមាជិករដ្ឋាភិបាលក្នុងតំបន់ដទៃទៀត និងជាចុងក្រោយមានការបង្កើតជាសាធារណរដ្ឋស្រឹបស្កា។ បន្តិចក្រោយមក បក្សប្រជាជនក្រូអាស៊ីនៅក្នុងបូស្នី-ហឺហ្ស៊ីហ្គោវីន បានបំបែកខ្លួនចេញពីសាធារណរដ្ឋ បូស្នី-ហឺហ្ស៊ីហ្គោវីន និងប្រកាសបង្កើតសហគមន៍ក្រូអាស៊ី ហឺហ្ស៊ី-បូស្នី វិញ។



រូបថតនៃអតីតប្រធានាធិបតីសូវៀត នីគីតា គ្រូស្ស៊ូហ្វ (១៩៥៨-១៩៦៤) ធ្វើទស្សនកិច្ចនៅសភាកងទ័ពជើងទឹកសូវៀត ជាមួយនឹងអតីតប្រធានាធិបតីយូហ្គោស្លាវី ចូស៊ិប ប្រូហ្សទីតូ (១៩៥៣-១៩៨០)។ រូបភាពនេះត្រូវបានថតដោយ ដានីឡូ ស្កហ្វីក។ ប្រភពរូបភាព វីគីមីឌា ខមមិនស៍ (Wikimedia Commons)។

ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩១ បូស្នី-ហឺហ្ស៊ីហ្គោវីន បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនពីយូហ្គោស្លាវី និងបន្ទាប់មកបានធ្វើប្រជាមតិដើម្បីឯករាជ្យភាព។ ជនជាតិ បូស្នី-ស៊ែប ភាគច្រើនបានធ្វើពហិការមិនចូលរួមក្នុងការធ្វើប្រជាមតិ ក៏ប៉ុន្តែប្រជាជនបូស្នី-ហឺហ្ស៊ីហ្គោវីនភាគច្រើនបានចូលរួមធ្វើប្រជាមតិបានគាំទ្រឯករាជ្យភាព ដែលត្រូវបានប្រកាសនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩២។ ភ្លាមៗបន្ទាប់ពីការប្រកាសឯករាជ្យភាព យោធា បូស្នី-ស៊ែប បានប្រមូលផ្តុំនិងទទួលបានការគាំទ្រពីសមាជិក បូស្នី-ស៊ែប នៃកងកម្លាំងប្រដាប់អាវុធប្រជាជនយូហ្គោស្លាវី។

ដោយមានការគាំទ្រពីកងកម្លាំងប្រដាប់អាវុធប្រជាជនយូហ្គោស្លាវី កងទ័ព ឬកងជីវពល បូស្នី-ស៊ែប, បានកាន់កាប់លើមួយផ្នែកធំនៃ បូស្នី-ហឺហ្ស៊ីហ្គោវីន ក្នុងនាមជាតំបន់ឯករាជ្យស៊ែប នៃ បូស្នី-ហឺហ្ស៊ីហ្គោវីន (សាធារណរដ្ឋស្រឹបស្កា) ដែលមានភាពស្មោះត្រង់ទៅនឹងប្រទេសស៊ែប និងជាផ្នែកមួយនៃប្រទេសនេះ។ នៅផ្នែកនយោបាយជួរមុខ បក្សប្រជាធិបតេយ្យស៊ែបបានបង្កើតជាតំបន់ស្វយ័តក្រាជីណា។ តំបន់ភូមិសាស្ត្រនេះរួមបញ្ចូលតំបន់ស្វយ័តក្រាជីណា គឺជាផ្នែកមួយនៃការប្រកាសរបស់សាធារណរដ្ឋស៊ែប ឬសាធារណរដ្ឋស្រឹបស្កា។ មេដឹកនាំបក្សប្រជាធិបតេយ្យស៊ែប ចាត់ទុកប្រជាជន បូស្នី-មូស្លីម និង បូស្នី-ក្រូអាត ដែលរស់នៅក្នុងតំបន់ទាំងនេះ ហើយដែលត្រូវបានអះអាងថាជាផ្នែកមួយនៃសាធារណរដ្ឋស៊ែបដែរនោះ ថាជាឧបសគ្គចំពោះការបង្កើតរដ្ឋស៊ែបដែលខ្លួនបានប្រកាស។ កត្តានេះបង្កើតឲ្យមានគោលនយោបាយចម្រុះអចិន្ត្រៃយ៍ ឬការបោសសម្អាតជាតិពន្ធុមកលើប្រជាជន បូស្នី-មូស្លីម និង បូស្នី-ក្រូអាត ស្ទើរតែទាំងស្រុង។ ការដឹកនាំរបស់ក្រុមជាតិនិយម បូស្នី-ស៊ែប បានចាត់ទុកក្រុម បូស្នី-មូស្លីម និង បូស្នី-ក្រូអាត ថាជាក្រុមជ្រុលនិយម ដែលមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើប្រជាជនស៊ែបនៃ បូស្នី-ហឺហ្ស៊ីហ្គោវីន។

កងកម្លាំងរដ្ឋាភិបាលបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន មានបំពាក់អាវុធតិចតួច ហើយមិនបានត្រៀមខ្លួនចំពោះជម្លោះជាមួយយោធានៃសាធារណរដ្ឋស្រឹបស្កា ឬកងយោធាស៊ែបឡើយ។ កងជីវពលស៊ែប ដែលមានការគាំទ្រពីកងកម្លាំងប្រដាប់អាវុធស៊ែប បានកាន់កាប់មួយភាគធំនៃបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន ហើយកងកម្លាំងនេះបានចាត់វិធានការ និងអនុវត្តគោលនយោបាយដែលអាចចាត់ទុកថា គឺជាការលុបបំបាត់ក្រុមជាតិពន្ធុប្រឆាំងនឹងប្រជាជនបូស្ន៊ី-មូស្លីម និងបូស្ន៊ី-ក្រូអាត។ ជាទូទៅ ការបោសសម្អាតជាតិពន្ធុសំដៅលើការសម្លាប់ ការផ្លាស់ទីដោយបង្ខំ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងទង្វើដទៃទៀត ឬការគំរាមកំហែងបែបហិង្សា ក្នុងគោលបំណងផ្លាស់ប្តូរសមាសភាពនៃជាតិពន្ធុនៅក្នុងដែនដីមួយ។



ការគាស់រណ្តៅសាកសពរួមនៅទីក្រុងស្រ៊ីប្រ៊ីនីសា ប្រទេសបូស្ន៊ី នៅខែកក្កដា ឆ្នាំ ២០០៧។ រូបភាពថតដោយ៖ កែវ ដាស៊ីល, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃ ដោយផ្អែកលើអត្តសញ្ញាណជាតិពន្ធុ។ ចំណែកប្រជាជនរាប់លាននាក់ទៀត ត្រូវបានផ្លាស់ទីលំនៅ។ ប្រជាជនបូស្ន៊ី-មូស្លីម ត្រូវបានចាត់ទុកថាជា "ជនក្បត់" និង "អ្នកផ្តាច់ខ្លួន" ដោយផ្អែកលើមូលដ្ឋានជាតិពន្ធុ សាសនា និងទំនាក់ទំនងប្រវត្តិសាស្ត្រជាមួយនឹងប្រជាជន បូស្ន៊ី-មូស្លីម នៅក្នុងតំបន់។ តាមរយៈការធ្វើសកម្មភាពយ៉ាងអមនុស្សជាប្រព័ន្ធបែបនេះ ប្រជាជនបូស្ន៊ី-មូស្លីមត្រូវបានវាយប្រហារ និងទទួលរងអំពើសម្លាប់រង្គាលយ៉ាងព្រៃផ្សៃ។ ការសម្លាប់ជាប្រព័ន្ធ ការរំលោភសេពសន្ថវៈ និងអំពើទារុណកម្ម ត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងផ្លាស់ទី ឬលុបបំបាត់ប្រជាជនបូស្ន៊ី-មូស្លីមទាំងស្រុង។

ស្លូបូដាន មីឡូសេវិក គឺជាប្រធានាធិបតីស៊ែបពីឆ្នាំ១៩៨៩ដល់ឆ្នាំ១៩៩៧ និងជាប្រធានាធិបតីនៃសហព័ន្ធសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវី ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០០។ ការឡើងកាន់អំណាចរបស់ មីឡូសេវិកគឺស្របពេលនៃការកើនឡើងនៃចលនាជាតិនិយមស៊ែបក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០ ហើយក្នុងនាមជាប្រធានាធិបតីស៊ែប និងយូហ្គោស្លាវីក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះ មីឡូសេវិក បានដាក់ចេញនូវរបៀបវារៈជាតិនិយមជ្រុល ដែលជំរុញឲ្យមានការរីករាលដាលនៃការបោសសម្អាតជាតិពន្ធុ។ នៅពេលដែលប្រជាជនបូស្ន៊ី (មូស្លីម) និងក្រូអាតនៃបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន បោះឆ្នោតផ្តាច់ខ្លួនពីយូហ្គោស្លាវី មីឡូសេវិក បានគាំទ្រយោធាស៊ែប និងកងយោធាដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅមួយចំនួនប្រឆាំងនឹងជនស៊ីវិល។ តាមរយៈការគាំទ្ររបស់មីឡូសេវិក ក៏ដូចជាការគាំទ្ររបស់រដ្ឋាភិបាលនិងកងកម្លាំងប្រដាប់អាវុធស៊ែប យោធាបូស្ន៊ី-ស៊ែប បានប្រព្រឹត្តអំពើឃោរឃៅនៅពាសពេញប្រទេសបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន។

រ៉ាដូវ៉ាន់ ការ៉ាដហ្ស៊ិក គឺជាអ្នកនយោបាយបូស្ន៊ី-ស៊ែបមួយរូប ដែលកាន់តំណែងជាប្រធានាធិបតីនៃសាធារណរដ្ឋស្រឹបស្កាក្នុងអំឡុងសង្គ្រាមបូស្ន៊ី។ ការ៉ាដហ្ស៊ិក បានចូលរួមបង្កើតបក្សប្រជាធិបតេយ្យស៊ែបនៅក្នុងឆ្នាំ១៩៨៩ ក្នុងគោលបំណងបង្រួបបង្រួមសហគមន៍ស៊ែប។ បក្សប្រជាធិបតេយ្យស៊ែប បានដណ្តើមយក និងប្រកាសដែនអធិបតេយ្យភាពស៊ែប នៅក្នុងបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន។ ការ៉ាដហ្ស៊ិក ត្រូវបានបោះឆ្នោតជ្រើសតាំងជាប្រធានាធិបតីនៃសាធារណរដ្ឋស្រឹបស្កានាពេលបន្តិចក្រោយមក បន្ទាប់ពីការកាត់






រូបភាពនៃបង្គោលផ្នូរ និងបូជនីយដ្ឋាន នៅឯបូជនីយដ្ឋានរំឭក និងទីបញ្ចុះសាកសពស្រ៊ីប្រ៊ីនីសា-ផូថូឆារី សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ប្រព្រឹត្តឡើងក្នុងឆ្នាំ១៩៩៥ ស្ថិតនៅក្នុង ទីក្រុងស្រ៊ីប្រ៊ីនីសា ប្រទេសបូស្នី-ហឺហ្សីហ្គោវីន។ រូបភាពថតដោយ៖ គ្រីស្តូហ្វ័រ ឌៀរីង, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ផ្តាច់ទំនាក់ទំនងជាមួយនឹងសហព័ន្ធសាធារណរដ្ឋសង្គមនិយមយូហ្គោស្លាវីក្នុងឆ្នាំ១៩៩២។ ការ៉ាដហ្ស៊ិក ក៏បានដើរតួនាទីជាមេដឹកនាំនយោបាយយ៉ាងសំខាន់ក្នុងរដ្ឋបាលបូស្នី-ស៊ែប និងគ្រប់គ្រងលើកងកម្លាំងប្រដាប់អាវុធ ដោយទទួលខុសត្រូវចំពោះអំពើឃោរឃៅជាច្រើន ទៅលើជនស៊ីវិលបូស្នី-មូស្លីម។

ខណៈដែល ការ៉ាដហ្ស៊ិក ធ្វើជាប្រមុខនយោបាយនៃបក្សប្រជាធិបតេយ្យស៊ែប ឧត្តមសេនីយ៍ រ៉ាត់កូ ម្ល៉ាឌិក បានកាន់មុខតំណែងជាមន្ត្រីជាន់ខ្ពស់នៅក្នុងកងកម្លាំងប្រដាប់អាវុធប្រជាជនយូហ្គោស្លាវី និងបន្ទាប់មកគឺជានាយសេនាធិការយោធានៃសាធារណរដ្ឋស្រឹបស្កា នៅក្នុងអំឡុងសង្គ្រាមបូស្នៀពីឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៥។ ក្នុងនាមជាមន្ត្រីយោធាជាន់ខ្ពស់មួយរូបក្នុងអំឡុងពេលសង្គ្រាមបូស្នៀ ម្ល៉ាឌិក មានការទទួលខុសត្រូវផ្នែកខ្សែសង្វាក់បញ្ជាទាក់ទងនឹងអំពើព្រៃផ្សៃ ដែលប្រព្រឹត្តឡើងដោយអង្គភាពក្រោមបញ្ជារបស់ខ្លួន ដែលក្នុងនោះក៏រួមបញ្ចូលទាំងការឡោមព័ទ្ធទីក្រុងសារ៉ាយ៉េវ៉ូ និងការសម្លាប់រង្គាលនៅទីក្រុងស្រ៊ីប្រ៊ីនីសា។

ព្រឹត្តិការណ៍សំខាន់មួយនៃយុទ្ធនាការស៊ែបលើការបោសសម្អាតក្រុមជាតិពន្ធុ បានកើតមាននៅជុំវិញទីក្រុងស្រ៊ីប្រ៊ីនីសា។ ទីក្រុងស្រ៊ីប្រ៊ីនីសាស្ថិតក្នុងតំបន់ប៉ូឌ្រីនយ៉េភាគកណ្តាល ដោយមានប្រជាជនបូស្នី-មូស្លីម រស់នៅកកកុញ។ តំបន់នេះមានសារៈសំខាន់សម្រាប់ប្រជាជនស៊ែប ព្រោះទីតាំងយុទ្ធសាស្ត្រនេះស្ថិតក្រោមការគ្រប់គ្រងរបស់ស៊ែប។ កងកម្លាំងបូស្នី-ស៊ែប បានវាយប្រហារ និងឡោមព័ទ្ធជុំវិញទីក្រុងស្រ៊ីប្រ៊ីនីសា។ នៅក្នុងអំឡុងដើមឆ្នាំ១៩៩២ កងកម្លាំងស៊ែបបានគ្រប់គ្រងទីក្រុងស្រ៊ីប្រ៊ីនីសា។ ទោះបីជាយ៉ាងណាក្តី កងកម្លាំងរដ្ឋាភិបាលបូស្នីបានគ្រប់គ្រងទីតាំងជុំវិញទីក្រុងនេះសាជាថ្មី នៅខែឧសភាក្នុងឆ្នាំដដែល។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមកទៀត ចំនួនប្រជាជននៅក្នុងទីក្រុងស្រ៊ីប្រ៊ីនីសា បានកើនឡើងជាបន្តបន្ទាប់ ដោយមូល

ហេតុថាទីក្រុងនេះបានទទួលយកជនស៊ីវិលនៅក្នុងតំបន់ដែលភៀសខ្លួនចេញពីការវាយលុករបស់កងកម្លាំងស៊ែប។ នៅទីបំផុត តំបន់ជុំវិញទីក្រុងស្រ៊ីប្រ៊ីនីសា ត្រូវបានកាត់ផ្ដាច់ពីការគ្រប់គ្រងរបស់រដ្ឋាភិបាលស៊ែប និងត្រូវហ៊ុមព័ទ្ធដោយកងកម្លាំងបូស្ន៊ី-ស៊ែប។ កងកម្លាំងបូស្ន៊ី-ស៊ែប ដែលគ្រប់គ្រងលើផ្លូវចូលទៅក្នុងទីក្រុងស្រ៊ីប្រ៊ីនីសា មិនអនុញ្ញាតឲ្យដឹកជំនួយសប្បុរសធម៌ ជាពិសេសស្បៀងអាហារ និងថ្នាំសង្កូវទៅឲ្យប្រជាជនបានឡើយ។ កងកម្លាំងស៊ែបបានអនុវត្តយុទ្ធសាស្ត្របង្អត់អាហារ ប្រជាជន ដើម្បីបង្ខំអ្នកទាំងនោះឲ្យចុះចាញ់។

ឧក្រិដ្ឋកម្មសង្គ្រាម អំពើឃោរឃៅ និងការសម្លាប់រង្គាល បានកើតមានឡើងនៅទូទាំងតំបន់ដែលគ្រប់គ្រងដោយ កងកម្លាំងយោធាបូស្ន៊ី-ស៊ែប។ ការសម្លាប់រង្គាល និងស្ថានភាពក្នុងទីក្រុងស្រ៊ីប្រ៊ីនីសា បានជំរុញឲ្យអង្គការសហប្រជាជាតិ ប្រកាសនៅខែមេសា ឆ្នាំ១៩៩៣ ថាទីក្រុងស្រ៊ីប្រ៊ីនីសាគឺជាតំបន់សុវត្ថិភាពក្នុងតំបន់ជម្លោះនៃបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន។ ចេតនានៃការ ប្រកាសរបស់អង្គការសហប្រជាជាតិ គឺដើម្បីធានាឲ្យប្រាកដថា មានតំបន់សុវត្ថិភាពសម្រាប់ជនស៊ីវិលដែលភៀសខ្លួនពីសង្គ្រាម។ យោងតាមសេចក្ដីសម្រេចលេខ៨១៩ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ទីក្រុងស្រ៊ីប្រ៊ីនីសាមិនត្រូវមានការវាយ ប្រហារពីកងកម្លាំងប្រដាប់អាវុធ ឬអំពើប្រទូស្តរ៉ាយណាមួយឡើយ។ ទីតាំងនេះត្រូវបានបង្កើតឡើងក្នុងនាមជាទីតាំងដែលគ្មាន កងទ័ព។ ចំណែកក្រុមការងាររបស់អង្គការសហប្រជាជាតិវិញ គឺមានភារកិច្ចសម្របសម្រួលសន្តិភាព និងដកហូតអាវុធពី ភាគីទាំងសងខាង។ យ៉ាងណាមិញ កងកម្លាំងបូស្ន៊ី និងកងកម្លាំងស៊ែប ពុំបានទម្លាក់អាវុធ។ ភាគីបូស្ន៊ី បានតវ៉ាចំពោះការវាយ ប្រហាជាបន្តបន្ទាប់ដែលបង្កឡើងដោយកងកម្លាំងស៊ែប ព្រមទាំងរាំងខ្ទប់ជំនួយមនុស្សធម៌។ ចំណែកឯភាគីស៊ែប បានបន្ទោស កងកម្លាំងបូស្ន៊ីអំពីការប្រើប្រាស់តំបន់នេះជាមូលដ្ឋានយោធា។ បន្ទាប់មក នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៥ ភាគីស៊ែប បានបើក ការវាយប្រហារ ដើម្បីដណ្ដើមយកតំបន់នេះវិញ។ ក្រោយមក ប៉ុស្តិ៍ជួរមុខរបស់អង្គការសហប្រជាជាតិប្រចាំនៅក្នុងតំបន់នេះត្រូវ បានបាត់បង់ដោយសារការវាយលុករបស់ស៊ែប។ ចំណែកឯកងកម្លាំងការពាររបស់បូស្ន៊ីត្រូវបានរុញច្រានចេញពីទីក្រុង។ កងកម្លាំង ស៊ែបបានដុតបំផ្លាញ និងប្លន់ផ្ទះសម្បែងប្រជាជន ក្នុងពេលដែលខ្លួនវាយប្រហារ។ ប្រជាជនស៊ីវិលបូស្ន៊ីដែលព្យាយាមរត់គេច ខ្លួនត្រូវបានចាប់ខ្លួននិងសម្លាប់។ ការសម្លាប់រង្គាល ត្រូវបានប្រព្រឹត្តឡើងតាមរយៈយុទ្ធនាការស៊ែប។

ការសម្លាប់ត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពបូស្ន៊ី ស្ថិតក្រោមបញ្ជារបស់ រ៉ាត់កូ ម្ល៉ាឌិក។ រយៈពេល៥ថ្ងៃក្រោយមក ទាហាន ស៊ែបបានសម្លាប់ជាប្រព័ន្ធលើបុរសនិងកុមារាចំនួន៧ពាន់នាក់ នៅតាមវាលស្រែ សាលារៀន និងឃ្លាំងផ្ទុកទំនិញ។ ការរំលោភ សេពសន្ថវៈក៏បានក្លាយទៅជាអាវុធសង្គ្រាម។ បុរសជនជាតិស៊ែប ត្រូវបានលើកទឹកចិត្តឲ្យរំលោភស្ត្រីជនជាតិបូស្ន៊ី។ សាក្សីផ្ទាល់ បានពិពណ៌នាថា កុមារក៏មិនត្រូវបានលើកលែង។ កុមារត្រូវបានប្រមូលយកមកសម្លាប់ជាមួយនឹងមនុស្សពេញវ័យ។ សញ្ញាដែល បង្ហាញពីចេតនាបានស្ដែងឲ្យឃើញយ៉ាងច្បាស់ថា គ្មានជនជាតិបូស្ន៊ីណាម្នាក់អាចរស់នៅក្នុងទីក្រុងស្រ៊ីប្រ៊ីនីសាតទៅទៀតឡើយ។




# តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី



មួយឆ្នាំបន្ទាប់ពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិបូស្ន៊ី-មូស្លីម តុលាការអន្តរជាតិមួយបានបង្កើតឡើងដើម្បីកាត់ទោសបុគ្គលមួយចំនួន ដែលត្រូវបានជឿជាក់ថាជាអ្នកទទួលខុសត្រូវចំពោះអំពើសម្លាប់រង្គាល ដែលប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៩២និងឆ្នាំ១៩៩៥។ នៅក្នុងខែឧសភា ឆ្នាំ១៩៩៣ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិនេះ មានអំណាចនាំយកបុគ្គលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងដែនដីនៃអតីតប្រទេសយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ១៩៩១។ នៅទីបំផុត តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានកំណត់អត្តសញ្ញាណបុគ្គលចំនួន១៦១នាក់ ដោយរាប់បញ្ចូលទាំង ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី នាយសេនាធិការយោធា រដ្ឋមន្ត្រីមហាផ្ទៃ និងមេដឹកនាំជាន់ខ្ពស់ និងថ្នាក់កណ្តាលផ្នែកនយោបាយ មេដឹកនាំយោធានិងនគរបាល ទាក់ទងនឹងការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តនៅក្នុងដែនដីនៃអតីតប្រទេសយូហ្គោស្លាវី និងនៅក្នុងសាធារណរដ្ឋបូស្ន៊ី-ហឺហ្សេហ្គោវីន។ ទោះបីជាយ៉ាងនេះក៏ដោយ មានបុគ្គលចំនួន៣២នាក់តែប៉ុណ្ណោះ ដែលត្រូវបានកាត់ទោសដោយតុលាការនេះនៅឆ្នាំ២០១៦។

បុគ្គល៩នាក់បានស្លាប់នៅមុនពេលសវនាការរបស់ខ្លួនបានបញ្ចប់ ឬនៅមុនពេលត្រូវបានបញ្ជូនទៅកាន់តុលាការ ដែលក្នុងចំណោមនោះមាន ស្លូបូដាន មីឡូសេវិក ដែលជាបុគ្គលដ៏សំខាន់បំផុត។ នៅក្នុងឆ្នាំ២០០១ ស្លូបូដាន មីឡូសេវិក ត្រូវបានឃាត់ខ្លួននិងបញ្ជូនទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលនៅទីនោះបុគ្គលរូបនេះត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ នៅក្នុងអំឡុងពេលសវនាការ មីឡូសេវិក បានស្លាប់នៅក្នុងគុកមុនពេលដែលតុលាការប្រកាសសាលក្រម។

ជនជាប់ចោទជាច្រើននាក់ទៀត បានលាក់ខ្លួនបន្ទាប់ពីសង្គ្រាមដោយទទួលបានការការពារពីសំណាក់អាជ្ញាធរស៊ែប។ ការ៉ាដហ្ស៊ិក អតីតប្រធានាធិបតីសាធារណរដ្ឋស្រ៊ីបស្កា បានលាក់ខ្លួនអស់រយៈពេលជាងមួយទសវត្សរ៍ ដោយក្លែងខ្លួនជាគ្រូពេទ្យបើកថ្នាំ។ នៅក្នុងខែកក្កដា ឆ្នាំ២០០៨ ការ៉ាដហ្ស៊ិក ត្រូវបានឃាត់ខ្លួននៅក្នុងទីក្រុងប៊ែលហ្គ្រាត សាធារណរដ្ឋស៊ែប។

រ៉ាត់កូ ម្ល៉ាឌិក ដែលជាអ្នកបញ្ជាកងទ័ពប្រមាណ១សែន៨ម៉ឺននាក់ នៅក្នុងអំឡុងសង្គ្រាមប្រឆាំងនឹងបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន បានគេចខ្លួនពីការតាមចាប់ខ្លួនជាច្រើនឆ្នាំ ដោយសារមានការជួយជ្រោមជ្រែងពីសំណាក់អាជ្ញាធរស៊ែប ក្រុមគ្រួសារ និងសមាជិកយោធានៃសាធារណរដ្ឋស្រ៊ីបស្កា។ ម្ល៉ាឌិក ត្រូវបានឃាត់ខ្លួននៅក្នុងខែឧសភា ឆ្នាំ២០១១ នៅភាគខាងជើងស៊ែប និងបានធ្វើបត្យាប័នទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងចុងខែដដែល។ នៅចុងបញ្ចប់ ម្ល៉ាឌិក ត្រូវបានតុលាការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មចំនួន១០ករណី រួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការបំពានលើច្បាប់សង្គ្រាម។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានរកឃើញថា ឧត្តមសេនីយ៍រូបនេះ "បានរួមចំណែកយ៉ាងសំខាន់" នៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងនៅក្នុងទីក្រុងស្រ៊ីប្រ៊ីនីសា និងបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) ចូរពិភាក្សាអំពីព្រឹត្តិការណ៍និងកាលៈទេសៈដែលបង្កឲ្យមានអំពើហិង្សានៅបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន?

២) តើជនដៃដល់បានបង្ហាញពីភាពសមហេតុផលក្នុងការសម្លាប់របស់ខ្លួនទៅលើជនជាតិបូស្ន៊ី-មូស្លីម និងក្រូអាតដោយរបៀបណា?

៣) ស្ត្រី កុមារ និងសូម្បីតែទារកត្រូវបានសម្លាប់។ តើអ្វីជាគោលដៅចេតនានៃការសម្លាប់ស្ត្រី កុមារនិងទារកទាំងនោះ?

### សំណួរដែលមានចម្លើយខ្លី

៤) នៅដើមឆ្នាំ១៩៩០ សមាជិកមួយចំនួនរបស់ស៊ែបនៅក្នុងនៃសភាបូស្ន៊ី-ហឺហ្ស៊ីហ្គោវីនបានប្រានចោលសភាបូស្ន៊ី-ហឺហ្ស៊ីហ្គោវីន និងបានធ្វើអ្វីខ្លះ?

៥) នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩១ បូស្ន៊ី-ហឺហ្ស៊ីហ្គោវីន បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនពីយូហ្គោស្លាវី និងបន្ទាប់មកបានធ្វើប្រជាមតិដើម្បីប្រកាសឯករាជ្យភាព។ តើប្រជាជនភាគច្រើនបោះឆ្នោតគាំទ្រអ្វីដែរ?

៦) តើយោធាបូស្ន៊ី-ស៊ែប មានប្រតិកម្មយ៉ាងណាចំពោះព្រឹត្តិការណ៍នេះ?

៧) ព្រឹត្តិការណ៍សំខាន់មួយនៃយុទ្ធនាការស៊ែប ចំពោះការបោសសម្អាតក្រុមជាតិពន្ធុ បានកើតមាននៅជុំវិញទីប្រជុំជននៃទីក្រុងស្រ៊ីប្រ៊ីនីសា។ តើមានអ្វីកើតឡើងនៅទីនេះ?

៨) ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដើម្បីនាំយកមកជំនុំជម្រះទោសបុគ្គលដែលទទួលខុសត្រូវលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលប្រព្រឹត្តនៅក្នុងដែនដីនៃអតីតប្រទេសយូហ្គោស្លាវីចាប់តាំងពីឆ្នាំ១៩៩១។ តើឧក្រិដ្ឋកម្មប្រភេទណាដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី លើកយកមកជំនុំជម្រះ?




ផែនទីនៃប្រទេសបូស្នី-ហឺហ្ស៊ីហ្គោវីន

ប្រភពរូបភាព៖ https://www.un.org/Depts/Cartographic/map/profile/bosnia.pdf





(រូបភាពខាងលើ) ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍រវ៉ាន់ដា។ គំនរឆ្អឹងជនរងគ្រោះដែលត្រូវបានគាស់យកពីរណ្ដៅសាកសពរួម នៅឆ្នាំ១៩៩៤ នៅសាលារៀនមូរ៉ាំប៊ី។ រូបភាពថតដោយ បុគ្គលិកនៃតំណាងសមាជិកសភាសហរដ្ឋអាមេរិក លោក ហ្វ្រេង វ៉ូល្វ
(រូបភាពខាងក្រោម) លលាដ៍ក្បាលរបស់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ស្ថិតនៅពាសពេញបន្ទប់រៀនមួយក្នុងសាលាបច្ចេកទេស មូរ៉ាំប៊ី ប្រទេសរវ៉ាន់ដា។ រូបភាពថតដោយ បុគ្គលិកនៃតំណាងសមាជិកសភាសហរដ្ឋអាមេរិក លោក ហ្វ្រេង វ៉ូល្វ។

# ប្រទេសរវ៉ាន់ដា

បណ្ឌិត លី សុខឃាង

សេចក្ដីសង្ខេប

ក្រុមជាតិពន្ធុធំបំផុតរបស់ប្រទេសរវ៉ាន់ដា គឺក្រុមហ៊ូទូ និងទុតស៊ី បានកើតឡើងតាមរយៈកត្តាសង្គមសេដ្ឋកិច្ច ជាជាងកើតឡើងដោយសារភាពខុសប្លែកគ្នានៃវប្បធម៌និងជាតិពន្ធុ។ នៅក្នុងឆ្នាំ១៩៩៤ ប្រជាជនក្នុងប្រទេសរវ៉ាន់ដាដែលត្រូវបានប៉ាន់ស្មានថាមានចំនួនប្រហែល៧លាននាក់ ក្នុងនោះរួមមានក្រុមជាតិពន្ធុចំនួន៣គឺ ហ៊ូទូ (ដែលមានចំនួនប្រមាណ៨៥ភាគរយនៃប្រជាជនសរុប), ទុតស៊ី (១៤ភាគរយ) និង ត្វា (១ភាគរយ)។

ផ្អែកលើគោលគំនិតអាណានិគមនៃការបែងចែកពូជសាសន៍និងក្រុមជាតិពន្ធុ ប្រទេសបែលហ្ស៊ិកបានគ្រប់គ្រងលើប្រទេសរវ៉ាន់ដា តាមរយៈរដ្ឋអំណាចដែលកំណត់ថា ទុតស៊ី ជាក្រុមដែលមានពូជសាសន៍ខ្ពង់ខ្ពស់។ ការកំណត់ន័យអំពីក្រុមហ៊ូទូ និងក្រុមទុតស៊ី នៅតែមានភាពចម្រូងចម្រាសទាក់ទងនឹងភាពខុសប្លែកពីគ្នានៃរដ្ឋបាលអាណានិគម និងកត្តាដទៃទៀតទាក់ទងនឹងជាតិពន្ធុឬវណ្ណៈសេដ្ឋកិច្ច។ ដើម្បីធ្វើឲ្យរដ្ឋអំណាចស្របទៅនឹងទ្រឹស្តីអំពីពូជសាសន៍និងក្រុមជាតិពន្ធុ បែលហ្ស៊ិកបានដកហូតអំណាចពីជនជាតិហ៊ូទូ និងរារាំងអ្នកទាំងនេះមិនឲ្យទទួលបាននូវបុព្វសិទ្ធិនានា ដូចជា ការអប់រំកម្រិតឧត្តមជាដើម។ ក្នុងនាមជាអ្នកអាស្រ័យផលពីរដ្ឋអំណាច ទុតស៊ី ប្រកាន់យកគំនិតខុសឆ្គងនៃឧត្តមភាពពូជសាសន៍ឬជាតិពន្ធុ ហើយជនជាតិហ៊ូទូត្រូវបានផាត់ចេញជាបន្តបន្ទាប់ និងទទួលរងនូវការគាបសង្កត់ទៀតផង។

ការសម្លាប់រង្គាលលើក្រុមទុតស៊ី បានកើតមានឡើងរាប់ខែរាប់ឆ្នាំនៅតាមផ្នែកផ្សេងៗគ្នាក្នុងប្រទេសរវ៉ាន់ដា ដែលបណ្ដាលឲ្យកើតមានអំពើប្រល័យពូជសាសន៍។ កងកម្លាំងយោធានិងរដ្ឋាភិបាលបានចូលរួមនៅក្នុងការសម្លាប់រង្គាលនេះ។ របាយការណ៍របស់អ្នកសង្កេតការណ៍បរទេសបានបង្ហាញថា រដ្ឋាភិបាលរវ៉ាន់ដា បានរៀបចំគម្រោងផែនការ ដើម្បីអនុវត្តអំពើប្រល័យពូជសាសន៍ជាប្រព័ន្ធលើជនជាតិទុតស៊ី ។

បន្ទាប់មក នៅល្ងាចថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ យន្តហោះរបស់ ជូវេណាល ហាប៊ីយ៉ារីម៉ាណា ប្រធានាធិបតីប្រទេសរវ៉ាន់ដា (ជនជាតិហ៊ូទូ) និង ស៊ីព្រា ណារីយ៉ាមីរ៉ា ប្រធានាធិបតីនៃប្រទេសប៊ូរុនឌី ត្រូវបានបាញ់ទម្លាក់នៅពេលដែលយន្តហោះនោះបានត្រៀមចុះចតនៅទីក្រុងគីហ្គាលី ប្រទេសរវ៉ាន់ដា។ ភ្លាមៗ

បន្ទាប់ពីការធ្វើឃាតប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា រដ្ឋាភិបាលរវ៉ាន់ដាបណ្ដោះអាសន្នបានគ្រប់គ្រងអំណាចបន្ត និងបង្កើតអំពើហិង្សាដ៏ឃោរឃៅនៅពាសពេញផ្ទៃប្រទេស។

ទាហាន នគរបាល អ្នកនយោបាយ កងជីវពល និងប្រជាជនបានប្រព្រឹត្ត ឬគាំទ្រដោយផ្ទាល់ចំពោះការសម្លាប់រង្គាលលើជនជាតិទុតស៊ី។ នៅក្នុងរយៈពេល១០០ថ្ងៃក្រោយមក ក្រុមទុតស៊ី ត្រូវបានស្វែងរកនិងសម្លាប់រង្គាលជាប្រព័ន្ធដោយកងជីវពលហ៊ូទូ ខណៈដែលសហគមន៍អន្តរជាតិកំពុងរវល់ពិភាក្សាគ្នារកវិធានការសម្រាប់លៃលកលើសភាពការណ៍នេះ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងទម្រង់ដែលពុំធ្លាប់មានពីមុនមក។

រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា ដែលមានខ្នងបង្អែកជាជនជាតិទុតស៊ី ហើយដែលបានវាយប្រយុទ្ធជាមួយនឹងរដ្ឋាភិបាលរវ៉ាន់ដាអស់ជាច្រើនឆ្នាំមកទល់នឹងពេលនេះ បានគ្រប់គ្រងលើប្រទេសយ៉ាងគំហុកចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៩៤។ ទោះបីជាយ៉ាងណាក្ដី អំពើហិង្សាលើក្រុមជាតិពន្ធនៅតែបន្តរហូតដល់ដើមខែកក្កដា។ បន្តិចម្ដងៗ កងកម្លាំងរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា បានផ្ដួលរំលំកងទាហាននិងក្រុមជីវពលរបស់រដ្ឋាភិបាលរវ៉ាន់ដា ដែលជាអ្នកទទួលខុសត្រូវចំពោះការរៀបចំការសម្លាប់។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៤ កងកម្លាំងរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា បានកាន់កាប់រដ្ឋធានីគីហ្គាលីទាំងស្រុង។ តំបន់តស៊ូសំខាន់ៗដទៃទៀតនៃរដ្ឋាភិបាលស្ដីទីរវ៉ាន់ដា ត្រូវបានផ្ដួលរំលំនាពេលបន្ទាប់។ ទន្ទឹមនឹងនេះ បទឈប់បាញ់ជាឯកតោភាគីត្រូវបានប្រកាសនៅថ្ងៃទី១៨ ខែកក្កដា។ មេដឹកនាំរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា បានបង្កើតរដ្ឋាភិបាលរួបរួមជាតិបណ្ដោះអាសន្នមួយនៅថ្ងៃទី១៩ ខែកក្កដា និងបានពង្រីកការគ្រប់គ្រងរបស់ខ្លួននៅទូទាំងប្រទេស។

ទោះបីជាអង្គការសហប្រជាជាតិ និងមេដឹកនាំអន្តរជាតិនានា បានថ្កោលទោសអំពើហិង្សានេះយ៉ាងណាក៏ដោយ ក៏ស្ថាប័នអន្តរជាតិទាំងនេះ មិនបានធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពណាមួយនៅមុនខែកក្កដានោះទេ។ ជំនួសឲ្យការបញ្ជូនកងទ័ពរបស់ខ្លួនទៅពង្រឹងបន្ថែម ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅក្នុងខែមេសា បានបោះឆ្នោតសម្រេចដកកងទ័ពបេសកកម្មអង្គការសហប្រជាជាតិសម្រាប់ជួយប្រទេសរវ៉ាន់ដា ចេញពីប្រទេសនោះ។ កត្តានេះបានបណ្ដាលឲ្យមានការរីករាលដាលអំពើហិង្សានៅពាសពេញផ្ទៃប្រទេស។ ទោះបីជាមានសេចក្ដីរាយការណ៍និងសម្ពាធពីសំណាក់ក្រុមមនុស្សធម៌ អ្នកសារព័ត៌មាន និងប្រជាជាតិដទៃទៀតយ៉ាងណាក៏ដោយ ក៏ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅតែអល់អែកលើសំណួរ ថាតើគួរចាត់វិធានការបែបណា និងថាតើនៅពេលណា។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានធ្វើការថ្កោលទោសចំពោះអំពើហិង្សា និងអ្នកដឹកនាំអំពើប្រល័យពូជសាសន៍ក៏ពិតមែន ប៉ុន្តែសេចក្ដីថ្លែងការថ្កោលទោសនោះនៅមានលក្ខណៈទន់ខ្សោយ ហើយមិនទាំងហ៊ានហៅអំពើហិង្សាដែលបានប្រព្រឹត្តឡើងឲ្យចំតាមធាតុពិតរបស់ទង្វើនេះថាជាអំពើប្រល័យពូជសាសន៍នោះទេ។ ក្រៅពីនេះ អង្គការសហប្រជាជាតិមិនបានចាត់វិធានការមិនមែនតាមបែបយោធាណាមួយទាល់តែសោះ ដូចជា ការបិទស្ថានីយវិទ្យុជាតិរវ៉ាន់ដា ឬធ្វើការថ្កោលទោសជាសាធារណៈលើមេដឹកនាំនៃអំពើប្រល័យពូជសាសន៍។ ប្រសិនបើត្រូវបានដាក់ចេញ វិធានការទាំងអស់នេះ វាអាចនឹងមានប្រសិទ្ធភាពក្នុងការរារាំង ឬពន្យារពេលនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដោយនាំមកនូវហានិភ័យ និងការចំណាយថវិកាតិចតួចបំផុតដល់បណ្ដាសមាជិកអង្គការសហប្រជាជាតិ។ ប៉ុន្តែ ទម្រាំនឹងអង្គការសហប្រជាជាតិសម្រេចដាក់ពង្រាយកងកម្លាំងរបស់ខ្លួនចំនួន៥ពាន់នាក់ទៅក្នុងប្រទេសរវ៉ាន់ដាសាជាថ្មីវិញនោះ អំពើប្រល័យពូជសាសន៍ត្រូវបានបញ្ចប់ ហើយកន្លងផុតទៅអស់ជាច្រើនខែទៅហើយ។

ប្រទេសរវ៉ាន់ដា

ប្រជាជនចន្លោះពី៨សែនទៅ១លាននាក់ ត្រូវបានសម្លាប់នៅក្នុងអំឡុងរយៈពេល១០០ថ្ងៃនេះ គឺចាប់ពីខែមេសាដល់ខែកក្កដា ឆ្នាំ១៩៩៤។ អំពើហិង្សានេះបានបង្ហាញថា ក្រុមហ៊ូទូ បានសម្លាប់ក្រុមទុតស៊ី។ អំពើប្រល័យពូជសាសន៍បានបញ្ចប់នៅពេលដែលរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដាដែលគាំទ្រដោយក្រុមទុតស៊ី បានឡើងគ្រប់គ្រងប្រទេស។ ជាច្រើនឆ្នាំក្រោយមក តុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានរកឃើញថាបុគ្គលមួយចំនួនមានពិរុទ្ធភាពក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) តើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រអ្វីខ្លះ ដែលជំរុញឲ្យមានអំពើហិង្សារវាងក្រុមហ៊ូទូ និងទុតស៊ី?

២) បន្ទាប់ពី ហាប៊ីយ៉ារីម៉ាណា ប្រធានាធិបតីនៃប្រទេសរវ៉ាន់ដា ត្រូវបានធ្វើឃាត តើមានព្រឹត្តិការណ៍អ្វីកើតឡើងខ្លះ?

៣) តើអង្គការសហប្រជាជាតិបានដាក់ចេញវិធានការអ្វីខ្លះ ដើម្បីទប់ស្កាត់ការសម្លាប់រង្គាល?

៤) តើសកម្មភាពអ្វីខ្លះ ដែលនាំឲ្យមានការបញ្ឈប់អំពើហិង្សា?

ប្រទេសរវ៉ាន់ដា

## មេរៀនលម្អិត

នៅលា្ងចថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ យន្តហោះរបស់ ជូវេណាល ហាប៊ីយ៉ារីម៉ាណា ប្រធានាធិបតីប្រទេសរវ៉ាន់ដា (ជនជាតិហ៊ូទូ) និង ស៊ីព្រា ណារីយ៉ាមីរ៉ា ប្រធានាធិបតីនៃប្រទេសប៊ូរុនឌី ត្រូវបានបាញ់ទម្លាក់នៅពេលដែលយន្តហោះនេះបានត្រៀមចុះចត នៅក្នុងទីក្រុងគីហ្គាលី ប្រទេសរវ៉ាន់ដា។ ភ្លាមៗបន្ទាប់ពីការធ្វើឃាត ហាប៊ីរីយ៉ារីម៉ាណា រដ្ឋាភិបាលរវ៉ាន់ដាបណ្តោះអាសន្នបានកាន់អំណាច និងបានបង្កឲ្យមានអំពើហិង្សាដ៏ឃោរឃៅនៅទូទាំងប្រទេស។ ជាលទ្ធផល បុរស ស្ត្រី និងកុមារ ចំនួនប្រមាណពី៨សែនទៅ១លាននាក់ត្រូវបានសម្លាប់[៦] ហើយករណីរំលោភសេពសន្ថវៈព្រមទាំងអំពើហិង្សាផ្លូវភេទប្រមាណពី១សែនទៅ២សែនករណីបានកើតមានឡើង។[៧] ជនរងគ្រោះ គឺជាក្រុមជនជាតិទុតស៊ី ដែលមានចំនួនច្រើនជាងគេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រជាជនដទៃជាច្រើនទៀត រួមបញ្ចូលទាំងក្រុមហ៊ូទូផង ត្រូវបានបោសសម្អាត។ ទាហាន នគរបាល អ្នកនយោបាយ កងជីវពល និងប្រជាជន បានប្រព្រឹត្តឬគាំទ្រដោយផ្ទាល់ដល់ការសម្លាប់រង្គាលលើជនជាតិទុតស៊ី។ ក្នុងរយៈពេល១០០ថ្ងៃ ក្រុមទុតស៊ីត្រូវបានស្វែងរក និងសម្លាប់រង្គាលជាប្រព័ន្ធដោយកងជីវពលហ៊ូទូ ខណៈដែលសហគមន៍អន្តរជាតិនៅរវល់ពិភាក្សារកវិធានការសម្រាប់លៃលកចំពោះស្ថានការណ៍នេះ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងទម្រង់ដែលពុំធ្លាប់មានពីមុនមក។ ជារួម អត្រានៃការស្លាប់ដែលបានកើតមាននៅក្នុងរយៈពេល១០០ថ្ងៃនេះ មានចំនួនស្មើនឹងបួនដង ច្រើនជាងអត្រាស្លាប់ខ្ពស់បំផុតនៃការសម្លាប់រង្គាលក្នុងព្រឹត្តិការណ៍សម្លាប់រង្គាលនៅអឺរ៉ុបនៃរបបណាហ្ស៊ីទៅទៀត។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៤ គឺប្រមាណ២ខែបន្ទាប់ពីការកើតមានជម្លោះ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុញ្ញាតឲ្យកងកម្លាំងប្រដាប់អាវុធបង្កើតជា "តំបន់សុវត្ថិភាព" នៅភាគនិរតីនៃប្រទេសរវ៉ាន់ដា។ នៅដើមខែកក្កដា រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា ដែលប្រឆាំងនឹងរដ្ឋាភិបាលរវ៉ាន់ដា បានបើកការវាយប្រហារយ៉ាងឆាប់រហ័សចំពេលមានភាពចលាចលនិងកាន់កាប់រដ្ឋធានីគីហ្គាលី។ បន្ទាប់មក រណសិរ្សនេះបានពង្រីកការគ្រប់គ្រងរបស់ខ្លួនលើផ្នែកសេសសល់នៃប្រទេស។ បទឈប់បាញ់ត្រូវបានប្រកាសនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤។ រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដាក៏បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលសន្យាថានឹងអនុវត្តគោលនយោបាយរួបរួមជាតិ។ ទោះបីជាប្រទេសរវ៉ាន់ដាទទួលបានសន្តិភាពជាបន្តបន្ទាប់ក្រោយពីអំពើប្រល័យពូជសាសន៍យ៉ាងណាក៏ដោយ ក៏ផលប៉ះពាល់នៃការបំផ្លិចបំផ្លាញនៅតែកើតឡើងនៅគ្រប់ស្រទាប់នៃប្រទេសនេះ អស់រយៈពេលប្រមាណជាង២០ឆ្នាំក្រោយមក។

ក្រុមជាតិពន្ធធំៗនៅក្នុងប្រទេសរវ៉ាន់ដា បានកើតចេញពីកត្តាសេដ្ឋកិច្ចសង្គម ជាជាងកត្តាវប្បធម៌និងជាតិពន្ធ។ នៅក្នុងឆ្នាំ១៩៩៤ ប្រជាជនដែលរស់នៅក្នុងប្រទេសរវ៉ាន់ដា ត្រូវបានប៉ាន់ស្មានថាមានចំនួនប្រមាណ៧លាននាក់ រួមមានក្រុមជាតិពន្ធចំនួន៣គឺ ហ៊ូទូ (ដែលមានចំនួនប្រមាណ៨៥ភាគរយនៃប្រជាជនសរុប), ទុតស៊ី (១៤ភាគរយ) និង ត្វា (១ភាគរយ)។ ពាក្យថា ទុតស៊ី ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាអំពីបុគ្គលម្នាក់ដែលសម្បូរសត្វពាហនៈ។ ពាក្យនេះបង្កប់ន័យបញ្ជាក់ពីឋានៈអភិជន ដែលភាគច្រើនជាអ្នកមានកម្មសិទ្ធិលើសត្វពាហនៈ។ ហ៊ូទូ មានន័យថា អ្នកក្រោមបង្គាប់ ឬអ្នកដើរតាមមេដឹកនាំណាម្នាក់។ ដូច្នេះពាក្យ ហ៊ូទូ ត្រូវបានប្រើប្រាស់សំដៅលើប្រជាជនភាគច្រើនដែលជាអ្នកប្រកបរបរកសិកម្ម។ ទោះបីជាយ៉ាងណាក្តី ការបែងចែកវណ្ណៈទាំងនេះមិនមានភាពច្បាស់លាស់ឡើយ ហើយការផ្លាស់ប្តូរវណ្ណៈសង្គមក៏អាចធ្វើឡើងតាមរយៈអាពាហ៍ពិពាហ៍ ឬនៅពេលដែលហ៊ូទូមានទ្រព្យសម្បត្តិឬអំណាច។ នៅក្នុងកាលៈទេសៈទាំងនេះ ជនជាតិទុតស៊ីដែលក្រីក្រ ក៏អាចត្រូវចាត់ទុកថាជា ជនជាតិហ៊ូទូ។

---

[៦] សូមមើល ម៉ារ៉ៃយឺ វើភូថេន "ចំនួនអ្នកស្លាប់នៅក្នុងអំពើប្រល័យពូជសាសន៍រវ៉ាន់ដា៖ សេចក្តីវិភាគលម្អិតនៅក្នុងខេត្តហ្គីកុងហ្គោរ៉ូ" ចំនួនប្រជាជន ឆ្នាំ២០០៥/៤ (លេខ ៦០) ទំព័រ៣៣១-៣៦៧។ DOI 10.3917/popu.504.0401, https://www.cairn-int.info/article-E_POPU_504_0401--the-death-toll-of-the-rwandan-genocide-a.htm.

[៧] សូមមើល ព័ត៌មានអំពីប្រវត្តិស្តីពីអំពើហិង្សាផ្លូវភេទដែលប្រើប្រាស់ជាឧបករណ៍សង្គ្រាម, អង្គការសហប្រជាជាតិ, កម្មវិធីចុះផ្សាល់ទៅកាន់មូលដ្ឋានស្តីពីអំពើប្រល័យពូជសាសន៍លើជនជាតិរវ៉ាន់ដានិងអង្គការសហប្រជាជាតិ។ https://www.un.org/es/preventgenocide/rwanda/assets/pdf/Backgrounder%20Sexual%20Violence%202014.pdf.

មុនដំបូង ប្រទេសរវ៉ាន់ដាត្រូវបានប្រគល់ឲ្យទៅប្រទេសអាល្លឺម៉ង់នៅក្នុងអំឡុងសន្និសីទទីក្រុងបែរឡាំងឆ្នាំ១៨៨៤ ហើយគឺជាផ្នែកមួយនៃអាល្លឺម៉ង់-អាហ្វ្រិកខាងកើត។ បន្ទាប់ពីសង្គ្រាមលោកលើកទី១ គឺនៅក្នុងឆ្នាំ១៩២៤ ប្រទេសអាល្លឺម៉ង់បានផ្ទេរការគ្រប់គ្រងលើដែនដីរវ៉ាន់ដា ទៅឲ្យប្រទេសបែលហ្ស៊ិក។

នៅពេលដែលខ្លួនចាប់ផ្តើមគ្រប់គ្រងលើប្រទេសរវ៉ាន់ដា ប្រទេសបែលហ្ស៊ិក បានរក្សានូវរចនាសម្ព័ន្ធវណ្ណៈសង្គមបង្កើតដោយជនជាតិអាល្លឺម៉ង់ និងមន្ត្រីអាល្លឺម៉ង់ ដែលបានធ្វើការគ្រប់គ្រងដោយប្រយោលលើប្រទេសនេះតាមរយៈមេដឹកនាំទុតស៊ី។ ផ្អែកលើគោលគំនិតអាណានិគមនៃការបែងចែកពូជសាសន៍ និងក្រុមជាតិពន្ធុ ប្រទេសបែលហ្ស៊ិកបានគ្រប់គ្រងប្រទេសរវ៉ាន់ដាតាមរយៈរដ្ឋអំណាចដែលកំណត់ថា ក្រុមទុតស៊ី ជាពូជសាសន៍ខ្ពង់ខ្ពស់។

ដើម្បីធ្វើឲ្យរដ្ឋអំណាចស្របទៅនឹងទ្រឹស្តីអំពីពូជសាសន៍និងក្រុមជាតិពន្ធុ បែលហ្ស៊ិក បានដកហូតជនជាតិហ៊ូទូពីមុខតំណែងមានអំណាច និងមិនឲ្យជនជាតិនេះទទួលបានបុព្វសិទ្ធិនានា ដូចជា ការអប់រំកម្រិតឧត្តមសិក្សា ជាដើម។ ក្នុងនាមជាអ្នកអាស្រ័យផលពីរដ្ឋអំណាច ក្រុមជនជាតិភាគតិច ទុតស៊ី បានសហការជាមួយមន្ត្រីបែលហ្ស៊ិក ដើម្បីអនុវត្តគោលនយោបាយ។ ការបែងចែកពូជសាសន៍និងកំណត់ក្រុមជាតិពន្ធុ បានកើនឡើងថែមទៀតនៅពេលដែលបែលហ្ស៊ិកតម្រូវឲ្យប្រជាជនរវ៉ាន់ដាគ្រប់រូបកាន់អត្តសញ្ញាណប័ណ្ណ និងកំណត់ក្រុមជាតិពន្ធុនៃអ្នកទាំងនេះ។ លទ្ធផលដែលកើតចេញពីអត្តសញ្ញាណប័ណ្ណគឺបុគ្គលម្នាក់មិនអាចផ្លាស់ប្តូរវណ្ណៈសង្គមតាមរយៈស្ថានភាពសេដ្ឋកិច្ចឬអាពាហ៍ពិពាហ៍បានទៀតទេ។ ដោយមិនខ្វល់ពីមូលហេតុខុសឆ្គងនៃទ្រឹស្តីរើសអើងពូជសាសន៍និងជាតិពន្ធុ អត្តសញ្ញាណប័ណ្ណមិនត្រឹមតែបានបញ្ជាក់ពីក្រុមជាតិពន្ធុតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជាក់អំពីវណ្ណៈសង្គមទៀតផង។ ក្រុមទុតស៊ីប្រកាន់យកគំនិតខុសនៃឧត្តមភាពពូជសាសន៍ ឬក្រុមជាតិពន្ធុ ហើយជនជាតិហ៊ូទូ ត្រូវបានផ្តាច់ចេញ និងទទួលរងការគាបសង្កត់ជាបន្តបន្ទាប់។

ប្រទេសបែលហ្ស៊ិក បានដកខ្លួនចេញពីប្រទេសរវ៉ាន់ដានៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ហើយបានបង្កើតរដ្ឋាភិបាលថ្មីមួយដើម្បីបន្តកាន់កាប់អំណាចនៅចុងទសវត្សរ៍ដដែល។ ភាពតានតឹងស្តីពីក្រុមជាតិពន្ធុ បានកើតឡើងនៅក្នុងអំឡុងពេលនោះ។ ដើម្បីដោះស្រាយភាពតានតឹងនេះ បែលហ្ស៊ិក បានចាប់ផ្តើមផ្តល់អំណាចដល់ក្រុមហ៊ូទូ ដោយតែងតាំងក្រុមនេះឲ្យមានតំណែងក្នុងជួររដ្ឋាភិបាល និងពង្រីកបន្ថែមនូវបុព្វសិទ្ធិក្នុងសង្គម។

នៅក្នុងអំឡុងពេលបោះឆ្នោតដោយសេរីលើកទី១ ដែលត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ១៩៦០ និងឆ្នាំ១៩៦១ ក្រុមហ៊ូទូទទួលបានការគ្រប់គ្រងនយោបាយនៅលើផ្ទៃប្រទេស តាមរយៈការបោះឆ្នោតនៅក្នុងបក្ស ផារមេហ៊ូទូ។ ក្នុងខែកញ្ញា ឆ្នាំ១៩៦១ ប្រជាជនរវ៉ាន់ដាប្រមាណ៨០ភាគរយ បានបោះឆ្នោតដើម្បីបញ្ចប់រាជវង្សអាណានិគម។ ទន្ទឹមនឹងនេះ ដែនដីរវ៉ូនដា-អ៊ូរុនឌី បានត្រូវបំបែកចេញជា២រដ្ឋ គឺ ប៊ូរុនឌី និងរវ៉ាន់ដា។

បក្សផារមេហ៊ូទូ បានបង្កើតគោលនយោបាយដើម្បីកំណត់ក្រុមទុតស៊ី ថាជាសត្រូវនៃបដិវត្តន៍ឯករាជ្យ ព្រមទាំងបង្ហាញហេតុផលសម្រាប់ការវាយប្រហារលើក្រុមទុតស៊ី និងតំបន់កាន់កាប់របស់ក្រុមនេះ។ ជនជាតិទុតស៊ីប្រមាណ១ម៉ឺននាក់បានភៀសខ្លួនទៅកាន់ប្រទេសជិតខាង។ ក្រុមហ៊ូទូ បែរជាបង្កើនទ្រព្យសម្បត្តិនិងអំណាច ព្រមទាំងចាប់ផ្តើមដាក់ចេញគោលនយោបាយដូចគ្នាទៅនឹងអ្វីដែលខ្លួនបានទទួលរងនៅក្រោមការគ្រប់គ្រងរបស់អាណានិគម។ អំពើហិង្សា និងភាពចលាចលបាននាំឲ្យមានការវាយបកវិញពីក្រុមទុតស៊ី។

នៅត្រឹមឆ្នាំ១៩៦៧ ជនជាតិទុតស៊ី ប្រមាណជាង២ម៉ឺននាក់ ត្រូវបានសម្លាប់ និងប្រមាណជាង៣ម៉ឺននាក់ផ្សេងទៀតបានភៀសខ្លួនទៅកាន់ប្រទេសជិតខាង ជាពិសេសទៅកាន់ប្រទេសអ៊ូហ្គង់ដា និងប៊ូរុនឌី ដើម្បីគេចពីការរីករាលដាលនៃអំពើហិង្សា។

ក្នុងឆ្នាំ១៩៧៣ ឧត្តមសេនីយ៍ ជូវ៉េណាល ហាប៊ីយ៉ារីម៉ាណា ដែលជាមេដឹកនាំយោធាជាន់ខ្ពស់នៅភាគខាងជើងបានធ្វើរដ្ឋប្រហារប្រកបដោយជោគជ័យ ព្រមទាំងបានបង្កើតសាធារណរដ្ឋរវ៉ាន់ដាលើកទីពីរ។ ទោះបីជារដ្ឋប្រហារបានប្រព្រឹត្តទៅដោយអហិង្សាក្តី ក៏មេដឹកនាំរបស់បក្សផារមេហ៊ូទូយ៉ាងហោចណាស់៥០នាក់ ត្រូវបានសម្លាប់និងស្លាប់នៅក្នុងគុក។ ហាប៊ីយ៉ារីម៉ាណា



ជំរំជនភៀសខ្លួនសម្រាប់ជនជាតិរវ៉ាន់ដា នៅក្នុងតំបន់គីមប៊ូមបា ភាគខាងកើតប្រទេសហ្សាអៀរ (បច្ចុប្បន្នស្ថិតនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ) បន្ទាប់ពីអំពើប្រល័យពូជសាសន៍លើជនជាតិរវ៉ាន់ដា។ រូបភាពថតដោយ មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (CDC) នៃនាយកដ្ឋានសុខាភិបាលនិងសេវាកម្មបម្រើដល់មនុស្ស របស់សហរដ្ឋអាមេរិក។

បានដាក់ចេញនូវគោលនយោបាយកណ្តាលមួយ ដែលគាំទ្រដល់ឯកភាពជាតិ និងប្រាសចាកពីយុទ្ធសាស្ត្របែងចែងជាតិពន្ធុ ដែលធ្លាប់បានអនុវត្តដោយរដ្ឋអំណាចកាលពីអតីតកាល។ កម្មវិធីនយោបាយជាតិនិយមរបស់លោក ហាប៊ីយ៉ារីម៉ាណា បានធ្វើឲ្យលោកទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់រដ្ឋាភិបាលលោកខាងលិចមួយចំនួន ហើយទន្ទឹមគ្នានោះមុខតំណែងជាមេបញ្ជាការរបស់លោកលើកងកម្លាំងប្រដាប់អាវុធ កាន់តែជួយធានាអំណាចរបស់លោកបានរឹងមាំថែមទៀត។

ហាប៊ីយ៉ារីម៉ាណា បានបង្កើតរដ្ឋឯកបក្សរវ៉ាន់ដាក្នុងឆ្នាំ១៩៧៥ ស្ថិតក្រោមការដឹកនាំរបស់ចលនាបក្សសាធារណរដ្ឋប្រជាជាតិដើម្បីប្រជាធិបតេយ្យ ព្រមទាំងបានប្រកាសខ្លួនជាប្រធានាធិបតី។ នៅក្នុងទសវត្សរ៍ដំបូងនៃការកាន់អំណាចរបស់ ហាប៊ីយ៉ារីម៉ាណា ជនភៀសខ្លួនទុតស៊ីបានកើនឡើងដល់ទៅ៦សែននាក់។ ប្រជាជនទុតស៊ីភាគច្រើនបានភៀសខ្លួនទៅកាន់ប្រទេសអ៊ូហ្គង់ដា និងចូលរួមជាមួយរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា ដែលបង្កើតឡើងក្នុងឆ្នាំ១៩៨៧។ កងជីវពលភាគច្រើនគឺជាជនភៀសខ្លួនទុតស៊ីដែលបានភៀសខ្លួនទៅកាន់ប្រទេសអ៊ូហ្គង់ដា ដោយទទួលបានការគាំទ្រ និងទទួលគ្រឿងសព្វាវុធពីយោធារបស់ប្រទេសអ៊ូហ្គង់ដា។

ខណៈដែលរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា ដែលដឹកនាំដោយទុតស៊ីកាន់តែរីកធំធាត់ទៅៗ ប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា បានស្នើសុំជំនួយពីអន្តរជាតិ។ ថ្វីបើមានភាពស្មាក់ស្មើរក៏ពិតមែន ប្រទេសបារាំងគឺជាអ្នកគាំទ្ររបបហាប៊ីយ៉ារីម៉ាណា ក្នុងការផ្តល់ជំនួយផ្នែកយោធា ថវិកា និងប្រឹក្សាយោបល់។ រដ្ឋាភិបាលបារាំងបានចាត់ទុករវ៉ាន់ដាថាជាផ្នែកសំខាន់នៃទ្វីបអាហ្វ្រិកដែលប្រើប្រាស់ភាសាបារាំង ព្រមទាំងមានការព្រួយបារម្ភចំពោះកំណើនឥទ្ធិពលរបស់រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា។ ការគាំទ្ររបស់បារាំងចំពោះរដ្ឋាភិបាលរវ៉ាន់ដាបានទទួលរងការរិះគន់ពីសំណាក់អង្គការសិទ្ធិមនុស្ស។ នៅខែមករា ឆ្នាំ១៩៩៤ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចេញលិខិតមួយទៅកាន់ប្រធានាធិបតីបារាំង ហ្វ្រង់ស្វ័រ មីតេរ៉ង់ ដោយបានរិះគន់បារាំងចំពោះ "ការផ្តល់ជំនួយសឹកសង្គ្រាមដល់កងយោធារវ៉ាន់ដា ដែលមានពិរុទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងចំពោះការមិនបានដាក់សម្ពាធលើរដ្ឋាភិបាលរវ៉ាន់ដា ដើម្បីទប់ស្កាត់ការរំលោភបំពានសិទ្ធិមនុស្ស"។

រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដាបានព្យាយាមបណ្តេញ ហាប៊ីយ៉ារីម៉ាណា និងចលនាបក្សសាធារណរដ្ឋប្រជាជាតិដើម្បីប្រជាធិបតេយ្យភាពចេញពីអំណាច។ ឧទាហរណ៍ជាក់ស្តែងគឺ រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា បានធ្វើការវាយប្រហារពីប្រទេសអ៊ូហ្គង់ដា។ ទោះបីជាការវាយប្រហារនេះបានប្រព្រឹត្តឡើងយ៉ាងណាក្តី ក៏កងកម្លាំងរប៉េះរប៉ោះរបស់រណសិរ្សនេះមិនអាចយកឈ្នះលើយោធារវ៉ាន់ដាដែលមានចំនួនលើសលុបបានទេ។ ថ្វីត្បិតតែរណសិរ្សស្នេហាជាតិរវ៉ាន់ដាមានចំណុចខ្សោយយ៉ាងណាក៏ដោយ

ក៏ហាប៊ីយ៉ារីម៉ាណាបានប្រើប្រាស់ការវាយប្រហាររបស់រណសិរ្សស្នេហាជាតិរវ៉ាន់ដា ធ្វើជាមធ្យោបាយមួយដើម្បីជាអំណះអំណាងសម្រាប់ធ្វើការវាយប្រហារតាមផ្លូវយោធាសងសឹកទៅលើជនស៊ីវិល ទុតស៊ី។ ដូច្នេះ ការសម្លាប់រង្គាលដោយមានពហុរដ្ឋជាអ្នកបង្ក បានកើតមានឡើងទៅលើជនស៊ីវិលទុតស៊ីរស់នៅក្នុងតំបន់ជុំវិញប្រទេសរវ៉ាន់ដា។

ដោយសារមានការប៉ះទង្គិចជាបន្តបន្ទាប់រវាងរណសិរ្សស្នេហាជាតិរវ៉ាន់ដា និងកងកម្លាំងរដ្ឋាភិបាល សហគមន៍អន្តរជាតិបានដាក់សម្ពាធកាន់តែខ្លាំងទៅលើមេដឹកនាំរណសិរ្សស្នេហាជាតិរវ៉ាន់ដា និងចលនាបក្សសាធារណរដ្ឋប្រជាជាតិដើម្បីប្រជាធិបតេយ្យឲ្យធ្វើការចរចាដើម្បីបញ្ឈប់ការផ្ទុះអាវុធ។ ហាប៊ីយ៉ារីម៉ាណា ត្រូវបានដាក់សម្ពាធឲ្យអនុវត្តប្រព័ន្ធរដ្ឋាភិបាលពហុបក្ស។ ចំណែកយោធាបក្សនយោបាយប្រឆាំងនឹងហ៊ូទូ និងសមាជិកផ្ទៃក្នុងរបស់ ហាប៊ីយ៉ារីម៉ាណា បានប្រឆាំងយ៉ាងខ្លាំងចំពោះការចរចានិងការប៉ុនប៉ងទាំងឡាយណាឈានទៅបង្កើតប្រព័ន្ធពហុបក្សដែលនឹងបង្វែរអំណាចឲ្យក្រុមកណ្តាលនិយម ឬឲ្យទៅក្រុមទុតស៊ី។

ក្នុងឆ្នាំ១៩៩១ ហាប៊ីយ៉ារីម៉ាណា បានចុះចាញ់ចំពោះសម្ពាធអន្តរជាតិ និងបានយល់ស្របឲ្យមានការបង្កើតបក្សនយោបាយប្រឆាំងនឹងរដ្ឋាភិបាល។ នៅខែកក្កដា ឆ្នាំ១៩៩២ ហាប៊ីយ៉ារីម៉ាណា បានយល់ព្រមចរចាលើសន្ធិសញ្ញាសន្តិភាព ដែលជាបណ្តុំឯកសារផ្លូវការហៅថា កិច្ចព្រមព្រៀងអារុស្សា។ ការចរចានេះ មានគោលបំណងបញ្ចប់សង្គ្រាមរវាងរណសិរ្សស្នេហាជាតិរវ៉ាន់ដា និងរដ្ឋាភិបាលរវ៉ាន់ដា ដោយបង្កើតជារដ្ឋាភិបាលពហុបក្ស ដែលបានដាក់បញ្ចូលទាហានរបស់រណសិរ្សស្នេហាជាតិរវ៉ាន់ដាទៅក្នុងកងកម្លាំងប្រដាប់អាវុធរវ៉ាន់ដា និងដើម្បីសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនរវ៉ាន់ដា។ បន្ទាប់ពីការចុះហត្ថលេខាលើកដំបូងលើសន្ធិសញ្ញាសន្តិភាពឆ្នាំ១៩៩២ ហាប៊ីយ៉ារីម៉ាណា បានប្រកាសបដិសេធលើលក្ខខណ្ឌដែលបានចែង។ មួយឆ្នាំក្រោយមក ហាប៊ីយ៉ារីម៉ាណា បានយល់ស្របលើលក្ខខណ្ឌដែលបានចែងនៅក្នុងសន្ធិសញ្ញានោះវិញ។ អង្គការសហប្រជាជាតិបានផ្តល់កងកម្លាំងរក្សាសន្តិភាព (បេសកកម្មអង្គការសហប្រជាជាតិសម្រាប់ជួយប្រទេសរវ៉ាន់ដា) ដើម្បីសម្របសម្រួលស្ថានការណ៍ក្នុងពេលអន្តរកាល។

ការសម្លាប់រង្គាលលើក្រុមទុតស៊ី បានកើតមានឡើងជាច្រើនខែច្រើនឆ្នាំនៅក្នុងផ្នែកផ្សេងៗគ្នាក្នុងប្រទេសរវ៉ាន់ដា ដែលឈានដល់ការកើតមានអំពើប្រល័យពូជសាសន៍។ កងជីវពល និងកងកម្លាំងរបស់រដ្ឋាភិបាល បានចូលរួមនៅក្នុងការសម្លាប់រង្គាលនេះ។ របាយការណ៍របស់អ្នកសង្កេតការបរទេស បានបង្ហាញថារដ្ឋាភិបាលរវ៉ាន់ដាបានរៀបចំគម្រោងការដើម្បីអនុវត្តអំពើប្រល័យពូជសាសន៍ជាប្រព័ន្ធលើជនជាតិទុតស៊ី។

នៅពេលដែល ហាប៊ីយ៉ារីម៉ាណា ត្រឡប់ទៅកាន់ទីក្រុងគីហ្គាលីនាថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ យន្តហោះរបស់លោកត្រូវបានបាញ់ទម្លាក់ ហើយគ្មាននរណាម្នាក់នៅរស់រានមានជីវិតពីឧប្បត្តិហេតុនេះឡើយ។ អត្តសញ្ញាណនិងគោលបំណងពិតប្រាកដរបស់អ្នកវាយប្រហារ គឺនៅតែរកមិនឃើញជារៀងរហូត។ ប៉ុន្តែព័ត៌មាននៃការវាយប្រហារនេះ និងការស្លាប់របស់ប្រធានាធិបតី បានបង្កឲ្យមានយុទ្ធនាការប្រល័យពូជសាសន៍យ៉ាងឆាប់រហ័សបំផុតដែលពុំធ្លាប់មានពីមុនមកនៅលើពិភពលោក។

ក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយមរណភាពរបស់ ហាប៊ីយ៉ារីម៉ាណា កងកម្លាំងប្រដាប់អាវុធ និងកងជីវពល បានចាប់ផ្តើមកំណត់គោលដៅបឋមលើក្រុមហ៊ូទូនិយមកណ្តាល និងសមាជិកដឹកនាំបក្សនយោបាយប្រឆាំង។ នៅថ្ងៃទី៧ ខែមេសា នាយករដ្ឋមន្ត្រីអាហ្កាថា យូវីលីនហ្គីយ៉ាម៉ា ដែលជាអ្នកទទួលបន្ទុកដឹកនាំរដ្ឋាភិបាលរវ៉ាន់ដាបន្ទាប់ពីមានការធ្វើឃាតលើប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា។ ដំបូងឡើយ ការវាយប្រហារនានាត្រូវបានធ្វើឡើងនៅក្នុងទីក្រុងគីហ្គាលី និងក្រោយមកទៀតបានរីករាលដាលយ៉ាងឆាប់រហ័សទៅកាន់ខេត្តដទៃទៀត។ ទោះបីជាមានការដាក់ពង្រាយកងកម្លាំងបេសកកម្មផ្តល់ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសរវ៉ាន់ដា ដើម្បីតាមដានរដ្ឋាភិបាលបណ្តោះអាសន្នប្រកបដោយសន្តិភាពក៏ដោយ ដូចគ្នាទៅនឹងមន្ត្រីសញ្ជាតិបរទេសដែលបម្រើការនៅក្នុងប្រទេសរវ៉ាន់ដាដែរ កងកម្លាំងនិងមន្ត្រីអង្គការសហប្រជាជាតិទាំងនេះមិនបានអើពើចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសនាប៉ុន្មានថ្ងៃក្រោយពីមានការធ្វើឃាតលើរូបលោក ហាប៊ីយ៉ារីម៉ាណា។

ការដកកងកម្លាំងចេញភ្លាមៗរបស់សហគមន៍អន្តរជាតិ បានជំរុញឲ្យយុទ្ធនាការយោធាប្រឆាំងនឹងជនស៊ីវិលទុតស៊ី កើតមានឡើងយ៉ាងឆាប់រហ័ស។ មន្ត្រីហ៊្វូទូនៅក្នុងប្រទេសត្រូវបានបញ្ជាឲ្យបង្កើតប៉ុស្តិ៍យាមនិងបំពាក់អាវុធ និងជ្រើសរើសជនស៊ីវិលហ៊្វូទូឲ្យចូលរួមក្នុងកងជីវពល អ៊ីធីរ៉ាហាមវើ។ មេដឹកនាំយោធាក៏បានបន្តប្រើប្រាស់ស្ថានីយវិទ្យុជាតិ ដើម្បីផ្សព្វផ្សាយពីភាពស្អប់ខ្ពើមចំពោះក្រុមទុតស៊ី និងបំភិតបំភ័យក្រុមហ៊្វូទូ ដែលបានបះបោរប្រឆាំងនឹងការបោសសម្អាតជាតិពន្ធុ។

យោធារ៉ាន់ដា បានបំពាក់ដោយគ្រាប់បែកដៃនិងកាំភ្លើង ខណៈដែលកងជីវពល អ៊ីធីរ៉ាហាមវើ ភាគច្រើនកាន់កាំបិតផ្គាក់។ អាវុធភាគច្រើនដែលប្រើប្រាស់ដោយយោធានិងកងជីវពល គឺត្រូវបានផ្តល់ឲ្យដោយប្រទេសបារាំង នៅមុនពេលកើតមានអំពើប្រល័យពូជសាសន៍។ ទោះបីជាក្រុមទុតស៊ីជាក្រុមគោលដៅក៏ដោយ ក៏នៅមានក្រុមហ៊្វូទូរាប់ពាន់នាក់ត្រូវបានសម្លាប់ដោយសារតែអ្នកទាំងនេះត្រូវបានយល់ច្រឡំថាជាក្រុមទុតស៊ី ឬអ្នកទាំងនេះបានបះបោរប្រឆាំងនឹងចលនានេះ ឬជួយដល់ក្រុមទុតស៊ី។ គោលនយោបាយអនុវត្តដោយរដ្ឋាភិបាលហ៊្វូទូបណ្តោះអាសន្ន មានគោលបំណងលុបបំបាត់នូវរាល់អ្នកប្រឆាំងរដ្ឋាភិបាល និងប្រើប្រាស់អំពើហិង្សាដើម្បីលុបបំបាត់ក្រុមទុតស៊ីទាំងអស់។ ការវាយប្រហារនិងការសម្លាប់រង្គាល បានប្រព្រឹត្តឡើងនៅតាមមន្ទីរពេទ្យនិងវិហារសាសនាគ្រិស្ត។ ស្ត្រី កុមារ និងមនុស្សវ័យចំណាស់ ត្រូវបានកំណត់ថាជាក្រុមគោលដៅសម្លាប់ដូចគ្នាទៅនឹងបុរសជនជាតិទុតស៊ី។ ការរំលោភសេពសន្ថវៈទៅលើស្ត្រីជនជាតិទុតស៊ីនៅមុនពេលសម្លាប់ គឺជាល្បិចកលដ៏អាក្រក់ដែលបានអនុវត្តយ៉ាងសាយភាព ដើម្បីឲ្យស្ត្រីជនជាតិទុតស៊ីបាត់បង់អស់ភាពជាមនុស្ស។ ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ តែងតែត្រូវទទួលរងរបួស និងទារុណកម្មនៅមុនពេលត្រូវសម្លាប់ ខណៈពេលដែលជនរងគ្រោះខ្លះទៀតត្រូវធ្វើជាទាសករក្នុងរយៈពេលវែងជាងជនរងគ្រោះដទៃទៀត នៅមុនពេលត្រូវបានសម្លាប់។ រដ្ឋាភិបាលបណ្តោះអាសន្ន បានកៀរគរជនស៊ីវិលហ៊្វូទូឲ្យមកចូលរួមក្នុងយុទ្ធនាការរបស់ខ្លួន តាមរយៈការលើកទឹកចិត្ត ឬការគំរាមកំហែង។ ផ្ទះសម្បែងនិងទ្រព្យសម្បត្តិរបស់ក្រុមទុតស៊ីត្រូវបានដុតលួចប្លន់ ឬកម្ទេចចោល។

រណសិរ្សអ្នកស្នេហាជាតិរ៉ាន់ដាបានគ្រប់គ្រងលើផ្នែកនានានៃប្រទេស ចាប់ពីខែឧសភាដល់ខែមិថុនា ឆ្នាំ១៩៩៤។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អំពើហិង្សាលើក្រុមជាតិពន្ធុនៅតែបន្តរហូតដល់ដើមខែកក្កដា។ បន្តិចម្តងៗ កងកម្លាំងរណសិរ្សអ្នកស្នេហាជាតិរ៉ាន់ដា បានផ្តួលរំលំកងយោធា និងកងជីវពលរបស់រដ្ឋាភិបាលរ៉ាន់ដា ដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការសម្លាប់។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៤ កងកម្លាំងរណសិរ្សអ្នកស្នេហាជាតិរ៉ាន់ដា បានកាន់កាប់រដ្ឋធានីគីហ្គាលីទាំងស្រុង។ តំបន់តស៊ូសំខាន់ៗដទៃទៀតនៃរដ្ឋាភិបាលបណ្តោះអាសន្នរ៉ាន់ដា ត្រូវបានផ្តួលរំលំនាពេលបន្ទាប់។ ទន្ទឹមនឹងនេះ បទឈប់បាញ់គ្នាជាឯកតោភាគីត្រូវបានប្រកាសនៅថ្ងៃទី១៨ ខែកក្កដា។ មេដឹកនាំរណសិរ្សអ្នកស្នេហាជាតិរ៉ាន់ដា បានបង្កើតរដ្ឋាភិបាលរួបរួមជាតិបណ្តោះអាសន្នមួយ នៅថ្ងៃទី១៩ ខែកក្កដា និងបានពង្រីកការគ្រប់គ្រងរបស់ខ្លួននៅទូទាំងប្រទេស។ ប៉ាស្ទ័រ ប៊ីហ្ស៊ីមុនហ្គូ ជាមេដឹកនាំនិយមកណ្តាលនៃក្រុមហ៊្វូទូ ត្រូវបានតែងតាំងជាប្រធានាធិបតី និងជាមេបញ្ជាការ រណសិរ្សអ្នកស្នេហាជាតិរ៉ាន់ដា ហ៊្វូទូ។ ប៉ូល កាហ្គាមី គឺជាអនុប្រធានាធិបតី។ មេដឹកនាំរដ្ឋាភិបាលបណ្តោះអាសន្នហ៊្វូទូ បានគេចខ្លួនទៅកាន់ប្រទេសជិតខាង ជាពិសេសប្រទេសហ្សាអៀរ និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ ជនជាតិហ៊្វូទូជាច្រើនបានទៅតាមមេដឹកនាំទាំងនេះ ដោយសារតែការភិតភ័យចំពោះផលវិបាកនៃការចូលរួមនៅក្នុងអំពើប្រល័យពូជសាសន៍។ ចំនួនប្រជាជនដែលត្រូវផ្លាស់ទីក្នុងប្រទេសបានឈានដល់ទៅជាង៣លាននាក់។ លើសពីនេះទៀត ជនជាតិហ៊្វូទូជាង២លាននាក់ បានភៀសខ្លួនទៅកាន់ប្រទេសហ្សាអៀរ និងប្រទេសជិតខាង។

ទោះបីជាអង្គការសហប្រជាជាតិ និងមេដឹកនាំអន្តរជាតិនានា បានថ្កោលទោសចំពោះអំពើហិង្សាក៏ដោយ ក៏ស្ថាប័នអន្តរជាតិទាំងនេះមិនបានធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពណាមួយនៅមុនខែកក្កដា។ នៅក្នុងខែមេសា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបោះឆ្នោតដកកងកម្លាំងទ័ពបេសកកម្មអង្គការសហប្រជាជាតិសម្រាប់ជួយប្រទេសរ៉ាន់ដា




សញ្ញាមួយដែលមានន័យថា «ប្រជាជនរវ៉ាន់ដា គឺជាជនរងគ្រោះនៃមនោគមន៍វិជ្ជាប្រល័យពូជសាសន៍ និងឫសគល់ទាំងឡាយនៃអំពើនេះ។» រូបភាពនេះជាកម្មសិទ្ធិរបស់អង្គការ Creative Common License 2.0 គេហទំព័ររបស់អង្គការ https://creativecommons.org/licenses/by/2.0/deed.en.

ចេញពីប្រទេស។ កត្តានេះបានបង្កឲ្យអំពើហិង្សារីករាលដាលនៅពាសពេញផ្ទៃប្រទេស។ ទោះបីជាមានសេចក្ដីរាយការណ៍ និងសម្ពាធពីសំណាក់អង្គការមនុស្សធម៌ អ្នកសារព័ត៌មាន និងប្រជាជាតិដទៃទៀតក៏ដោយ ក៏ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅតែអល់អែកលើសំណួរថា តើគួរចាត់វិធានការបែបណា និងថាតើនៅពេលណា។ ថ្វីបើក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានធ្វើការថ្កោលទោសចំពោះអំពើហិង្សា និងអ្នកដឹកនាំអំពើប្រល័យពូជសាសន៍ក៏ពិតមែន ប៉ុន្តែសេចក្ដីថ្លែងការថ្កោលទោសនោះនៅមានលក្ខណៈទន់ខ្សោយ ហើយមិនទាំងហ៊ានហៅអំពើហិង្សាដែលបានប្រព្រឹត្តឡើងឲ្យចំតាមធាតុពិតរបស់វាថាជាអំពើប្រល័យពូជសាសន៍។ ក្រៅពីនោះ អង្គការសហប្រជាជាតិមិនបានចាត់វិធានការមិនមែនតាមបែបយោធាណាមួយទាល់តែសោះ ដូចជាការបិទស្ថានីយវិទ្យុជាតិរវ៉ាន់ដា ឬធ្វើការថ្កោលទោសជាសាធារណៈលើមេដឹកនាំនៃអំពើប្រល័យពូជសាសន៍។ ប្រសិនបើត្រូវបានដាក់ចេញ វិធានការទាំងអស់នេះ វាអាចនឹងមានប្រសិទ្ធភាពក្នុងការរារាំង ឬពន្យារពេលការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដោយនាំមកនូវហានិភ័យ និងការចំណាយថវិកាតិចតួចបំផុតដល់បណ្ដាសមាជិកអង្គការសហប្រជាជាតិ។ ក៏ប៉ុន្តែទម្រាំតែអង្គការសហប្រជាជាតិ សម្រេចដាក់ពង្រាយកម្លាំងទ័ពរបស់ខ្លួនចំនួន៥ពាន់នាក់ទៅក្នុងប្រទេសរវ៉ាន់ដាសាជាថ្មីវិញ នោះអំពើប្រល័យពូជសាសន៍ត្រូវបានបញ្ចប់ ហើយកន្លងផុតទៅអស់ជាច្រើនខែទៅហើយ។

ទោះបីជារណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដាជាកម្លាំងមូលដ្ឋានតែមួយគត់ ដែលមានបំណងប្រឆាំងនឹងរដ្ឋាភិបាលបណ្ដោះអាសន្នយ៉ាងណាក៏ដោយ ក៏អ្នកទាំងនោះបានចូលរួមនៅក្នុងការវាយប្រហារសងសឹកដែលបំពានលើច្បាប់អន្តរជាតិ និងបំពារបំពានសិទ្ធិមនុស្ស។ ជាញឹកញាប់ ការសម្លាប់ជនស៊ីវិលហ៊ូទូដែលគ្មានអាវុធបានប្រព្រឹត្តឡើងដោយរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា ដែលជំរុញឲ្យមានការសន្មតថា មេបញ្ជាការរណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា ប្រាកដជាបានដឹងអំពីសកម្មភាពនេះ ទោះបីជាពុំបានគ្រប់គ្រងដោយផ្ទាល់លើអំពើទាំងនេះក៏ដោយ។ សាក្សីជាច្រើនបានពិពណ៌នាអំពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដែលបន្តកើតមានឡើងក្រោយពេលរដ្ឋាភិបាលរួបរួមជាតិឡើងកាន់អំណាច។

រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដា បានសម្លាប់ជនដៃដល់មួយចំនួនដែលរស់នៅក្នុងប្រទេសរវ៉ាន់ដា ឬឃុំខ្លួនអ្នកទាំងនោះជារៀងរហូត ដោយពុំបានប្រព្រឹត្តទៅតាមដំណើរការតុលាការ។ រណសិរ្សអ្នកស្នេហាជាតិរវ៉ាន់ដាត្រូវបានចាប់ខ្លួន និងឃុំឃាំងជនសង្ស័យភ្លាមៗ បន្ទាប់ពីបណ្ដេញរដ្ឋាភិបាលហ៊ូទូចេញពីអំណាច។ មន្ទីរឃុំឃាំងក៏ត្រូវបានផ្ទុកអ្នកទោសលើសចំណុះ។ ប្រព័ន្ធតុលាការរបស់ប្រទេសនេះបានធ្លាក់ក្នុងសភាពរខេករខាកដុនដាប ហើយភាគច្រើននៃអ្នកជំនាញរបស់ខ្លួនបានស្លាប់បាត់បង់ជីវិត ឬត្រូវបានសម្លាប់នៅក្នុងអំឡុងអំពើប្រល័យពូជសាសន៍។ អ្នកទោស ត្រូវឃុំខ្លួនដោយគ្មានកាលកំណត់ច្បាស់លាស់ និងពុំបានឆ្លងកាត់ដំណើរការកាត់ក្តីឡើយ។ អ្នកទាំងនេះ បានទទួលរងអំពើអមនុស្សធម៌ដោយសារការផ្ទុកមនុស្សលើសចំណុះ កង្វះអាហារ និងកង្វះការថែទាំសុខភាព។ មកដល់ត្រឹមឆ្នាំ១៩៩៥ មានអ្នកទោសជាង៣ម៉ឺននាក់ នៅតែត្រូវបានបន្តឃុំឃាំងដោយពុំឆ្លងកាត់សវនាការ ឬការកាត់សេចក្ដីអ្វីទាំងអស់។



# តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងយន្តការយុត្តិធម៌ក្រោយជម្លោះ



នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ អង្គការសហប្រជាជាតិបានបង្កើតតុលាការអន្តរជាតិ ក្នុងគោលបំណងកាត់ទោសបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដទៃទៀតដែលបង្កឡើងនៅក្នុងប្រទេសរវ៉ាន់ដា។ ដោយសារតែបញ្ហាអស្ថិរភាពក្នុងប្រទេសរវ៉ាន់ដា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មិនបានចាប់ផ្តើមកាត់ទោស ឬជំនុំជម្រះជនទាំងឡាយណា ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយរហូតដល់ឆ្នាំ១៩៩៥។ តុលាការនេះត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងអារុស្សា ប្រទេសតង់សានី។

តុលាការនេះ គឺជាតុលាការអន្តរជាតិដំបូងបង្អស់ ដែលជំនុំជម្រះលើបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៩៨ ដោយបកស្រាយនិយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍ ដូចដែលបានតាក់តែងឡើងនៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានកំណត់បទឧក្រិដ្ឋកម្មរំលោភបំពានផ្លូវភេទ ជាផ្នែកមួយនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានសម្រេចជោគជ័យគួរឲ្យកត់សម្គាល់។ តុលាការនេះបានព្យាយាមលើកកម្ពស់ការយល់ដឹង និងបទដ្ឋានបទពិសោធភាពទាក់ទងនឹងការរំលោភសពសន្ធរៈ ការរំលោភបំពានផ្លូវភេទ និងឧក្រិដ្ឋកម្មផ្នែកយេនឌ័រដទៃទៀត ហើយបានបង្កើតកម្មវិធីនិងប្រព័ន្ធផ្តល់ការគាំទ្រនិងការការពារជនរងគ្រោះ និងសាក្សីសក្តានុពលនៃអំពើប្រល័យពូជសាសន៍។ ជារួម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានកាត់ទោសបុគ្គលសំខាន់ៗមួយចំនួន ដូចជា អតីតនាយករដ្ឋមន្ត្រី ហ្សង់ កាំបានដា, អតីតនាយសេនាធិការឧត្តមសេនីយ៍ អូហ្គាស្ទីន ប៊ីហ្ស៊ីមុនហ្គូ ព្រមទាំងអតីតនាយសេនាធិការនៃក្រសួងការពារជាតិ វរៈសនីយ៍ ថេអូណេស្ត៍ ហាហ្គោសូរ៉ា។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានជំនុំជម្រះទោសមនុស្សចំនួន៩៣នាក់ ក្នុងនោះមាន៦១នាក់ត្រូវបានដាក់ទោស និង១៤នាក់ទៀតត្រូវបានដោះលែង។

សមិទ្ធផលទាំងអស់របស់តុលាកាឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា គឺដើម្បីប៉ះប៉ូវសងវិញបន្ទាប់ពីការខកខានរបស់អង្គការសហប្រជាជាតិក្នុងការបាត់វិធានការបង្ការ ឬរារាំងអំពើប្រល័យពូជសាសន៍ នៅពេលដែលខ្លួនអាចធ្វើអន្តរាគមន៍បាន ហើយការខកខាននេះបានបង្កផលប៉ះពាល់ដល់កេរដំណែលរបស់អង្គការសហប្រជាជាតិ។ ប៊ូត្រូស ហ្គាលី អគ្គលេខាអង្គការសហប្រជាជាតិនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ បានទទួលស្គាល់ភាពបរាជ័យនេះ ព្រមទាំងភាពអសកម្មរបស់សហគមន៍អន្តរជាតិក្នុងការឆ្លើយតបទៅនឹងអំពើហិង្សា។

តុលាការបានចេញសេចក្តីសម្រេចចុងក្រោយក្នុងខែធ្នូ ឆ្នាំ២០១៤ និងចាប់តាំងពីពេលនោះមក សំណុំរឿងបន្ថែមទៀតត្រូវបានបញ្ជូនទៅកាន់តុលាការជាតិរវ៉ាន់ដា។ បន្ទាប់ពីបញ្ចប់ប្រតិបត្តិការរបស់ខ្លួន កេរដំណែលរបស់តុលាការនេះ ត្រូវបញ្ជូនទៅកាន់ផ្នែកយន្តការអចិន្ត្រៃយ៍អន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌដែលទទួលបន្ទុកអនុវត្តបន្តលើការងារ ដែលសម្រេចបានដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី)។ ការងារនៃផ្នែកយន្តការអចិន្ត្រៃយ៍អន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ គឺផ្តោតលើការពង្រឹងនីតិរដ្ឋនៅក្នុងវិស័យយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ដែលរួមបញ្ចូលទាំងការសម្របសម្រួល ក្នុងការផ្ទេរសំណុំរឿងពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ទៅកាន់តុលាការជាតិ ដោយបន្តតាមដានជនជាប់ចោទដែលនៅសេសសល់គ្រប់គ្រងបណ្ណសារ ឯកសារ និងផ្តល់ជំនួយ ក៏ដូចជាការពារដល់ជនរងគ្រោះនិងសាក្សីរាប់ពាន់នាក់ដែលផ្តល់សក្ខីកម្មនៅក្នុងតុលាការ។

ក្រៅពីយន្តការតុលាការអន្តរជាតិ ប្រទេសរវ៉ាន់ដាបានបង្កើតប្រព័ន្ធតុលាការ “កាឆាឆា” ដើម្បីដោះស្រាយសំណុំរឿងនៅក្នុងប្រព័ន្ធតុលាការសាមញ្ញ។ តុលាការកាឆាឆា គឺជាវេទិកាតាមសហគមន៍គ្រប់គ្រងដោយមន្ត្រីក្នុងសហគមន៍ ដែលជាទូទៅគ្មានការបណ្តុះបណ្តាលផ្លូវច្បាប់។ ប្រព័ន្ធកាឆាឆា មិនត្រឹមតែមានគោលបំណងពន្លឿនរយៈពេលនៃសវនាការនិងដំណើរការយុត្តិធម៌តែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងអនុញ្ញាតឲ្យមានការផ្សះផ្សាក្នុងសហគមន៍ តាមរយៈការលើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតចែករំលែកបទពិសោធន៍របស់ខ្លួន និងឲ្យជនដៃដល់ទទួលបាននូវការអត់ឱនទោសចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

គិតត្រឹមកាលបរិច្ឆេទនៃការបោះផ្សាយសៀវភៅនេះ តួនាទីរបស់ប្រទេសបារាំងនៅក្នុងអំពើប្រល័យពូជសាសន៍ គឺនៅតែជាប្រធានបទដែលត្រូវពិភាក្សាដ៏ចម្រូងចម្រាស់។ នៅក្នុងឆ្នាំ២០១៦ រវ៉ាន់ដា បានបោះពុម្ពបញ្ជីឈ្មោះមន្ត្រីយោធាបារាំងចំនួន២២រូប ដែលត្រូវបានចោទប្រកាន់ពីបទបានផ្តល់ជំនួយ ក្នុងការរៀបចំផែនការ និងគាំទ្រយុទ្ធនាការប្រល័យពូជសាសន៍។ ទន្ទឹមនឹងនេះដែរ នៅក្នុងឆ្នាំ២០១៧ រដ្ឋាភិបាលរវ៉ាន់ដាបានបោះពុម្ពរបាយការណ៍បង្កើតដោយអង្គភាពច្បាប់ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ដែលរបាយការណ៍នោះបានចោទប្រកាន់ប្រទេសបារាំងពីបទគាំទ្រដល់រដ្ឋាភិបាលហ៊ូទូ បង្កឲ្យមានអំពើប្រល័យពូជសាសន៍លើក្រុមទុតស៊ី ក៏ដូចជា ការផ្តល់ទីជម្រកដល់ជនសង្ស័យនៃអំពើប្រល័យពូជសាសន៍ទៀតផង។

## ពិនិត្យមើលសំណួរទាក់ទងនឹងមេរៀន

### សំណួរពិភាក្សា

១) តើប្រទេសមួយមានការទទួលខុសត្រូវក្នុងការការពារប្រជាជននៃប្រទេសដទៃទៀតពីអំពើប្រល័យពូជសាសន៍ឬទេ? តើអ្នកនឹងពិពណ៌នាពីការទទួលខុសត្រូវនេះយ៉ាងដូចម្តេច?

២) តើប្រជាជននៃប្រទេសដទៃគួរតែប្តូរជីវិតរបស់ខ្លួនដើម្បីស្រោចស្រង់ជីវិតមនុស្សពីអំពើប្រល័យពូជសាសន៍ដែរឬទេ?

៣) តើការអន្តរាគមន៍របស់ប្រទេសមួយលើប្រទេសដទៃដើម្បីរារាំង ឬបញ្ឈប់អំពើប្រល័យពូជសាសន៍ជាអំពើខុសច្បាប់ឬទេ?

### សំណួរដែលមានចម្លើយខ្លី

៤) តើមានលក្ខខណ្ឌប្រវត្តិសាស្ត្រអ្វីខ្លះ ដែលជំរុញឲ្យមានអំពើហិង្សារវាងជនជាតិហ៊ូទូ និងទុតស៊ី?

៥) បន្ទាប់ពីប្រធានាធិបតីនៃប្រទេសរវ៉ាន់ដាហាប៊ីយ៉ារីម៉ាណាត្រូវបានធ្វើឃាត តើមានហេតុការណ៍អ្វីខ្លះដែលបានកើតឡើង?

៦) តើអង្គការសហប្រជាជាតិបានធ្វើសកម្មភាពអ្វីខ្លះ ដើម្បីទប់ស្កាត់ការសម្លាប់រង្គាល?

៧) តើមានសកម្មភាពអ្វីខ្លះ ដែលបានបញ្ឈប់អំពើហិង្សានេះ?

៨) បន្ទាប់ពីអំពើហិង្សាទាំងនេះបានបញ្ចប់ អង្គការសហប្រជាជាតិបានបង្កើតតុលាការមួយ គឺតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ជាតុលាការអន្តរជាតិដំបូងបំផុតដែលធ្វើការជំនុំជម្រះលើឧក្រិដ្ឋកម្មអ្វីដែលត្រូវបានកំណត់ឡើងចាប់តាំងពីឆ្នាំ១៩៤៨?


RWANDA
National capital
Prefecture capital
Town, village
Airport, airstrip
International boundary
Prefecture boundary
Road
Track
DEMOCRATIC REPUBLIC OF THE CONGO
BIRUNGA NAT'L PARK
Lake Mutanda
Lac Burera
Lac Ruhondo
Lac Kivu
Lowa
Nyabarongo
Akanyaru
Ile Bugarura
Ile Wahu
Ile Idjwi
Ile Gombo
RUHENGERI
GISENYI
KIBUYE
GITARAMA
GIKONGORO
CYANGUGU
BUTARE
Rutshuru
Kisoro
Cyanika
Kidaho
Butaro
Kirambo
Ruhengeri
Busogo
Kora
Mutura
Kagali
Goma
Gisenyi
Nyundo
Nemba
Rushashi
Kabaya
Ngaru
Ngororero
Kiyumba
Bulinga
Mabanza
Kibuye
Gitarama
Birambo
Bwakira
Gishyita
Rwamatamu
Masango
Ruhango
Gatagara
Kaduha
Nyabisindu
Rusatira
Rwesero
Karaba
Kamembe
Gisakura
Gikongoro
Karama
Bukavu
Cyangugu
Rwumba
Kitabi
Cyimbogo
Karengera
Nyakabuye
Bugumya
Ruramba
Butare
Gisagara
Busoro
Bugarama
Munini
Runyombyi
1° 30'
2° 00'
2° 30'
29° 00'
29° 30'
The boundaries and names shown and the designations used on this map do not imply official endorsement or acceptance by the United Nations.




**ផែនទីប្រទេសរវ៉ាន់ដា**

ព្រំប្រទល់និងឈ្មោះ ដែលបង្ហាញនិងដៅនៅលើផែនទីនេះមិនបញ្ជាក់អំពីការគាំទ្រឬការទទួលស្គាល់របស់អង្គការសហប្រជាជាតិទេ។



# សំណួរ ដែលមានចម្លើយខ្លីសម្រាប់ មេរៀនលម្អិត

ប្រទេសអាល្លឺម៉ង់

ប្រទេសកម្ពុជា

ប្រទេសបូស្នី-ហឺហ្សីហ្គោវីន

ប្រទេសរវ៉ាន់ដា

# ប្រទេសអាល្លឺម៉ង់

**១) នៅឆ្នាំ១៩៣៣ សកម្មភាពចម្បងរបស់រដ្ឋាភិបាលមួយបានកើតមានឡើង ដែលបង្កជាការវាយប្រហារលើជនជាតិជ្វីហ្វ។ តើព្រឹត្តិការណ៍នោះគឺជាព្រឹត្តិការណ៍អ្វី?**

**ចម្លើយ៖** នៅក្នុងឆ្នាំ១៩៣៣ ច្បាប់នូរេមបឺកត្រូវបានអនុម័ត ដែលបង្ខំឲ្យជនជាតិជ្វីហ្វចាកចេញពីការងារស៊ីវិល និងផ្នែកដទៃទៀតនៃសង្គម។ ច្បាប់នេះបានធ្វើឲ្យជនជាតិជ្វីហ្វគឺជាប្រជាជនដែលមានឋានៈទីពីរក្នុងសង្គម។

**២) ចូរពិពណ៌នាអំពីគម្រោងរបស់ណាហ្ស៊ីអាល្លឺម៉ង់ ដែលត្រូវបានស្គាល់ថាជា «ដំណោះស្រាយចុងក្រោយ»។**

**ចម្លើយ៖** គម្រោងផែនការរបស់ណាហ្ស៊ី បង្ហាញពីវិធីសាស្ត្រច្រើនដំណាក់កាល ដែលមានគោលបំណងកម្ចាត់ចោលជនជាតិជ្វីហ្វទាំងអស់ចេញពីទ្វីបអឺរ៉ុប។ ជាផ្នែកមួយនៃគម្រោងនេះ អាដុលហ្វ៍ អាយខ្មាន់ មន្ត្រីជាន់ខ្ពស់នៃកងស្ហ្វិតស្តាហ្វែល អាល្លឺម៉ង់ គឺជាអ្នកទទួលបន្ទុកនិរទេសជនជាតិអាល្លឺម៉ង់-ជ្វីហ្វ នៅក្នុងប្រទេសអាល្លឺម៉ង់ និងជនជាតិអឺរ៉ុប-ជ្វីហ្វ នៅក្នុងឧបទ្វីបអាល្លឺម៉ង់ (រួមមាន ប្រទេសអូទ្រីស ប្រទេសប៉ូឡូញ ប្រទេសឆេកូស្លូវ៉ាគី ប្រទេសបារាំង ប្រទេសហូឡង់ ប្រទេសហុងគ្រីនិងប្រទេសរុស្ស៊ី) ទៅកាន់ ជំរំឃុំឃាំងនិងទីតាំងសម្លាប់។

**៣) តើជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងជំរំឃុំឃាំងមានសភាពយ៉ាងដូចម្តេច?**

**ចម្លើយ៖** ជីវិតប្រចាំថ្ងៃនៅក្នុងជំរំឃុំឃាំង គឺមានសភាពលំបាកលំបិន។ អ្នកទោសរស់នៅក្នុងជំរំទាំងអស់ត្រូវធ្វើការងារធ្ងន់ធ្ងរទាំងខាងក្នុងនិងខាងក្រៅជំរំ។ អ្នកទោសទទួលអាហារ ពេលសម្រាក និងការការពារពីអាកាសធាតុត្រជាក់បានតិចតួចណាស់។ ជំងឺនិងការឆ្លងជំងឺតែងតែកើតមានឡើង។ មនុស្សជាច្រើនបាត់បង់ជីវិតដោយសារការធ្វើការហួសកម្លាំង ភាពអត់ឃ្លាន និងជំងឺ។

**៤) តើក្រុមមនុស្សដែលជាគោលដៅរបស់របបណាហ្ស៊ីមានក្រុមណា ខ្លះ?**

**ចម្លើយ៖** របបណាហ្ស៊ីបានដាក់គោលដៅលើក្រុមមនុស្សទាំងឡាយណា ដែលមិនសមស្របនៅក្នុងផ្នត់គំនិតនៃអម្បូរអារ្យាន ដែលរួមបញ្ចូលទាំង ជនជាតិជ្វីហ្វ ជនជាតិរ៉ូម៉ា ជនជាតិអម្បូរស្លាវ និងជនពិការនៃក្រុមប្រជាជនដទៃទៀត។

**៥) តើប្រទេសអាល្លឺម៉ង់បានចុះចាញ់សង្គ្រាមលោកលើកទី២ នៅពេលណា?**

**ចម្លើយ៖** នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៤៥។

**៦) តើឧក្រិដ្ឋជនណាហ្ស៊ីត្រូវបាននាំយកមកកាត់ទោសយ៉ាងដូចម្តេចខ្លះ?**

**ចម្លើយ៖** រយៈពេលប្រមាណ៦ខែក្រោយពីការប្រព្រឹត្តបទល្មើស តុលាការយោធាអន្តរជាតិនៅក្នុងទីក្រុងនូរេមបឺក បានចាប់ផ្តើមសវនាការរបស់ខ្លួនជាផ្លូវការលើមន្ត្រីរបបណាហ្ស៊ី។ តុលាការនេះបានសម្រេចឲ្យបុគ្គលទាំងនោះជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅប៉ុន្មានឆ្នាំបន្ទាប់មកទៀត មន្ត្រីនៃរបបណាហ្ស៊ី ត្រូវបានកាត់ទោសនៅក្នុងតុលាការនៅជុំវិញពិភពលោក ទោះបីជាយ៉ាងណាក្តី ក៏មន្ត្រីណាហ្ស៊ី ភាគច្រើនពុំដែលត្រូវបានរកឃើញទេ។

# ប្រទេសកម្ពុជា

១) **តើនរណាជាអ្នកដាក់ឈ្មោះ «ខ្មែរក្រហម»?**

**ចម្លើយ៖** ពាក្យថា "ខ្មែរក្រហម" គឺជាឈ្មោះដែលសម្តេចព្រះ នរោត្តម សីហនុ ដាក់ឲ្យគូបដិបក្ខកុម្មុយនីស្តរបស់ព្រះអង្គនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ឈ្មោះផ្លូវការរបស់ក្រុមនេះគឺ បក្សកុម្មុយនីស្តកម្ពុជា។ ដើមកំណើតរបស់ខ្មែរក្រហម គឺផ្តើមចេញពីចលនាតស៊ូទ្រង់ទ្រាយធំប្រឆាំងនឹងអាណានិគមបារាំង។

២) **នៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ ចូលរួមជាមួយខ្មែរក្រហមក្នុងឆ្នាំ១៩៧០ តើសកម្មភាពរបស់ព្រះអង្គមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះកិច្ចប្រឹងប្រែងជ្រើសរើសសមាជិកថ្មីរបស់ខ្មែរក្រហម?**

**ចម្លើយ៖** នៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ ចូលរួមជាមួយខ្មែរក្រហម ព្រះអង្គបានធ្វើឲ្យចលនារបស់ខ្មែរក្រហមវិវត្តទៅជាស្របច្បាប់ និងអនុញ្ញាតឲ្យខ្មែរក្រហមបង្កើនកម្លាំងរបស់ខ្លួនបានយ៉ាងច្រើនសន្ធឹក។

៣) **ចូរពិពណ៌នាអំពីគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា?**

**ចម្លើយ៖** គោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា ឬបក្សរបស់ខ្មែរក្រហម គឺអនុវត្តបដិវត្តន៍សង្គមនិយមមហាលោតផ្លោះមហាអស្ចារ្យនៅក្នុងប្រទេសកម្ពុជា តាម លទ្ធិម៉ៅនិងលទ្ធិម៉ាក្ស-លេនីន។

៤) **ចូររៀបរាប់ក្រុមមនុស្សឲ្យបានយ៉ាងហោច៣ក្រុមដែលជាក្រុមគោលដៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។**

**ចម្លើយ៖** បញ្ញវន្ត, អ្នកមានទ្រព្យសម្បត្តិ, អ្នកប្រណិប័តន៍សាសនា, អ្នកដែលមានទំនាក់ទំនងជាមួយរបបមុនៗ ឬអ្នកដែលស្ថិតក្នុងការសង្ស័យ។ លើសពីនេះទៀត ខ្មែរក្រហមបានកំណត់គោលដៅលើអ្នកដែលមានទំនាក់ទំនងជាមួយជនបរទេស ជាពិសេស ទំនាក់ទំនងជាមួយវៀតណាម។

៥) **មកទល់ត្រឹមឆ្នាំ២០១៨ មេដឹកនាំកំពូលរបស់ខ្មែរក្រហមចំនួន៣រូប ត្រូវបានចោទប្រកាន់ កាត់ទោស និង ផ្តន្ទាទោស ដោយអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។ តើមេដឹកនាំទាំងនោះមានឈ្មោះអ្វីខ្លះ ហើយជាប់ចោទពីទោសឧក្រិដ្ឋអ្វីខ្លះ?**

**ចម្លើយ៖**

(១) នួន ជា - ជាប់ពន្ធនាគារអស់មួយជីវិត

(២) ខៀវ សំផន - ជាប់ពន្ធនាគារអស់មួយជីវិត

(៣) កាំង ហ្គេកអ៊ាវ - ជាប់ពន្ធនាគារអស់មួយជីវិត

# ប្រទេសបូស្នី-ហឺហ្សេហ្គោវីន

១)  **នៅដើមឆ្នាំ១៩៩០ សមាជិកសែ៊បនៃសភាបូស្នី-ហឺហ្ស៊ីហ្គោវីន បានចាកចេញពីសភានេះ និងបានធ្វើអ្វី?**

**ចម្លើយ៖** ក្រុមនេះបានបង្កើតសាធារណរដ្ឋស្រឹបស្កា។

២)  **នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩១ បូស្នី-ហឺហ្ស៊ីហ្គោវីន បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនពីយូហ្គោស្លាវី និងបន្ទាប់ពីនោះមក បានធ្វើប្រជាមតិដើម្បីប្រកាសឯករាជ្យភាព។ តើប្រជាជនភាគច្រើនបានបោះឆ្នោតដើម្បីអ្វី?**

**ចម្លើយ៖** ប្រជាជនភាគច្រើនបានបោះឆ្នោតដើម្បីទាមទារឯករាជ្យភាព។

៣)  **តើយោធាបូស្នី-សែ៊ប មានប្រតិកម្មយ៉ាងដូចម្តេចចំពោះព្រឹត្តិការណ៍នេះ?**

**ចម្លើយ៖** ដោយមានការគាំទ្រពីកងកម្លាំងប្រដាប់អាវុធប្រជាជនយូហ្គោស្លាវី យោធាសែ៊ប យោធាបូស្នី-សែ៊ប បានកាន់កាប់ទឹកដីមួយផ្នែកធំនៃបូស្នី-ហឺហ្ស៊ីហ្គោវីន ក្នុងនាមជាតំបន់ឯករាជ្យសែ៊បនៃបូស្នី-ហឺហ្ស៊ីហ្គោវីន (សាធារណរដ្ឋស្រឹបស្កា) ដែលមានភាពស្មោះត្រង់និងជាផ្នែកមួយនៃប្រទេសសែ៊ប។ អ្នកទាំងនេះក៏បានចាប់ផ្តើមធ្វើការបះបោរប្រដាប់អាវុធ ក្នុងគោលបំណងបែងចែកបូស្នី-ហឺហ្ស៊ីហ្គោវីន តាមក្រុមជាតិពន្ធុ ដោយផ្នែកដែលកាន់កាប់ដោយសែ៊បត្រូវបានកំណត់ថាជា "សែ៊បធំអស្ចារ្យ"។

៤)  **ព្រឹត្តិការណ៍សំខាន់មួយនៃយុទ្ធនាការសែ៊បលើការលុបបំបាត់ក្រុមជាតិពន្ធុ បានកើតមាននៅជុំវិញទីប្រជុំជននៃទីក្រុងស្រ៊ីប្រ៊ីនីសា។ តើជាព្រឹត្តិការណ៍អ្វី?**

**ចម្លើយ៖** យោធាសែ៊បបានរឹបអូសយកទីក្រុងដែលអង្គការសហប្រជាជាតិបានការពារ។ ស្ថិតក្រោមបញ្ជារបស់ រ៉ាត់កូ ម្ល៉ាឌិក ទាហានសែ៊ប បានធ្វើការសម្លាប់ជាប្រព័ន្ធលើបុរសនិងកុមារាចំនួន៧ពាន់នាក់នៅតាមវាលស្រែ សាលារៀន និងឃ្លាំងទំនិញ។

៥)  **ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដើម្បីនាំយកអ្នកទទួលខុសត្រូវលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សជាតិ បង្កឡើងនៅក្នុងដែនដីនៃអតីតយូហ្គោស្លាវីចាប់តាំងពីឆ្នាំ១៩៩១ យកមកកាត់ទោស។ តើឧក្រិដ្ឋកម្មប្រភេទណាខ្លះ ដែលតុលាការនេះ បានកាត់ទោស?**

**ចម្លើយ៖** អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

# ប្រទេសរវ៉ាន់ដា

**១) តើមានលក្ខខណ្ឌប្រវត្តិសាស្ត្រអ្វីខ្លះ ដែលជំរុញឲ្យមានអំពើហិង្សារវាងជនជាតិហ៊ូទូ និងជនជាតិទុតស៊ី?**

**ចម្លើយ៖** ដើម្បីបន្តការដាក់អាណានិគមតទៅទៀត ការគ្រប់គ្រងរបស់ក្រុមអាណានិគម គឺត្រូវតែបង្កឲ្យមានការបែកបែកពូជសាសន៍និងជាតិពន្ធុ។ ការបែងចែកនេះ បានបង្កើតឲ្យមានការបែកថ្នាក់មនុស្ស។ ក្នុងនោះក្រុមទុតស៊ី ត្រូវបានចាត់ទុកថាជាពូជសាសន៍ដែលមានឋានៈខ្ពស់។ ចំណែកឯក្រុមហ៊ូទូដែលមានចំនួនច្រើន បែរជាទទួលឋានៈតូចទាបនិងបុព្វសិទ្ធិតិចតួច។ កាលៈទេសៈនេះបានជំរុញឲ្យមានការយល់ខុសឆ្គងចំពោះឧត្តមភាពពូជសាសន៍ ឬភាពប្រសើរឡើងនៃក្រុមជាតិពន្ធុមួយជាងក្រុមជាតិពន្ធុដទៃទៀត ដោយបង្កើតឲ្យមានការគ្រប់គ្រងនិងការគាបសង្កត់លើក្រុម ហ៊ូទូ ជាបន្តបន្ទាប់រហូតឈានដល់ការកើតមានជម្លោះរវាងជនជាតិហ៊ូទូ និងជនជាតិទុតស៊ី។

**២) បន្ទាប់ពីប្រធានាធិបតីរវ៉ាន់ដា គឺ ហាប៊ីយ៉ារីម៉ាណា ត្រូវបានធ្វើឃាត តើមានព្រឹត្តិការណ៍អ្វីកើតឡើង?**

**ចម្លើយ៖** ព័ត៌មាននៃការវាយប្រហារនេះ រួមជាមួយនឹងការស្លាប់របស់ប្រធានាធិបតី បាននាំឲ្យមានយុទ្ធនាការប្រល័យពូជសាសន៍យ៉ាងគំហុកដែលមិនធ្លាប់មានពីមុនមកនៅលើពិភពលោក។ ដំបូងកងកម្លាំងប្រដាប់អាវុធ និងយុទ្ធជន បានកំណត់គោលដៅលើក្រុមហ៊ូទូ និងសមាជិកដឹកនាំបក្សនយោបាយប្រឆាំង បន្ទាប់ពីរយៈពេល ប៉ុន្មានថ្ងៃក្រោយមរណភាពរបស់ហាប៊ីយ៉ារីម៉ាណា។ ការវាយប្រហារត្រូវបានធ្វើឡើងដំបូង នៅក្នុងទីក្រុងគីហ្គាលី និងបានរីករាលដាលយ៉ាងឆាប់រហ័សទៅកាន់ខេត្តដទៃទៀត។ មានការប៉ាន់ស្មានថា បុរស ស្ត្រីនិងកុមារចំនួនប្រមាណពី៨សែនទៅ១លាននាក់ត្រូវបានសម្លាប់ និងមានករណីរំលោភសេពសន្ថវៈ ទាំងអំពើហិង្សាផ្លូវភេទពី១សែនទៅ២សែនករណីបានកើតឡើង។

**៣) តើអង្គការសហប្រជាជាតិបានធ្វើសកម្មភាពអ្វីខ្លះ ដើម្បីទប់ស្កាត់ការសម្លាប់រង្គាល?**

**ចម្លើយ៖** ទោះបីជាអង្គការសហប្រជាជាតិ និងអ្នកដឹកនាំអន្តរជាតិនានា អាចបញ្ឈប់អំពើហិង្សាបានយ៉ាងណាក៏ដោយ ក៏អង្គភាពអន្តរជាតិទាំងនេះ ពុំបានធ្វើអន្តរាគមន៍តាមវិធីសាស្ត្រដែលមានប្រសិទ្ធភាពនៅមុនខែកក្កដា។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបោះឆ្នោតដកកងកម្លាំងរបស់បេសកកម្មអង្គការសហប្រជាជាតិសម្រាប់ជួយប្រទេសរវ៉ាន់ដាចេញពីប្រទេសនោះនៅក្នុងខែមេសា។ កត្តានេះបានបង្កជាការរាលដាលនៃអំពើហិង្សានៅពាសពេញផ្ទៃប្រទេស។ ទោះបីជាមានសេចក្តីរាយការណ៍ និងសម្ពាធពីសំណាក់អង្គការមនុស្សធម៌ អ្នកសារព័ត៌មាន និងប្រជាជាតិដទៃទៀតក៏ដោយ ក៏ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅតែអល់អែកលើសំណួរថា តើគួរចាត់វិធានការបែបណា និងថាតើនៅពេលណា។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានធ្វើការថ្កោលទោសចំពោះអំពើហិង្សា និងអ្នកដឹកនាំអំពើប្រល័យពូជសាសន៍ក៏ពិតមែន ក៏ប៉ុន្តែសេចក្តីថ្លែងការថ្កោលទោសនោះនៅមានលក្ខណៈទន់ខ្សោយ ហើយមិនទាំងហ៊ានហៅអំពើហិង្សាដែលបានប្រព្រឹត្តឡើងឲ្យចំតាមធាតុពិតរបស់វាថាជាអំពើប្រល័យពូជសាសន៍។ ក្រៅពីនោះ អង្គការសហប្រជាជាតិមិនបានចាត់វិធានការដែលមិនប្រើប្រាស់កងកម្លាំងយោធាណាមួយទាល់តែសោះ ដូចជាការបិទស្ថានីយវិទ្យុជាតិរវ៉ាន់ដា ឬធ្វើការថ្កោលទោសជាសាធារណៈលើមេដឹកនាំនៃអំពើប្រល័យពូជសាសន៍នេះទេ។

៤)  **តើសកម្មភាពអ្វី ដែលអាចបញ្ឈប់អំពើហិង្សានេះ?**

**ចម្លើយ៖** រណសិរ្សស្នេហាជាតិរវ៉ាន់ដាបានគ្រប់គ្រងលើផ្នែកនានានៃប្រទេសចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៩៤។ ទោះបីជាយ៉ាងណាក្តី ក៏អំពើហិង្សាលើក្រុមជាតិពន្ធុនៅតែបន្តរហូតដល់ដើមខែកក្កដា។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៤ កងកម្លាំងរណសិរ្សស្នេហាជាតិរវ៉ាន់ដា បានកាន់កាប់រដ្ឋធានីគីហ្គាលីទាំងស្រុង។ តំបន់តស៊ូសំខាន់ៗដទៃទៀតនៃរដ្ឋាភិបាលស្តីទីរវ៉ាន់ដាក៏ត្រូវបានផ្តួលរំលំនាពេលបន្ទាប់។ ទន្ទឹមនឹងនេះ ការបញ្ឈប់ការផ្ទុះអាវុធជាឯកតោភាគីត្រូវបានប្រកាសនៅថ្ងៃទី១៨ ខែកក្កដា។ មេដឹកនាំរណសិរ្សស្នេហាជាតិរ៉្វាន់ដាបានបង្កើតរដ្ឋាភិបាលរួបរួមជាតិបណ្តោះអាសន្នមួយនៅថ្ងៃទី១៩ ខែកក្កដា និងពង្រីកវិសាលភាពនៃការគ្រប់គ្រងរបស់ខ្លួនទូទាំងប្រទេស។

៥)  **បន្ទាប់ពីអំពើហិង្សាទាំងនេះបានបញ្ចប់ អង្គការសហប្រជាជាតិបានបង្កើតតុលាការមួយ គឺតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ដែលជាតុលាការអន្តរជាតិដំបូងបំផុតដែលធ្វើការជំនុំជម្រះលើឧក្រិដ្ឋកម្មអ្វី ហើយដែលត្រូវបានកំណត់ឡើងចាប់តាំងពីឆ្នាំ១៩៤៨មក?**

**ចម្លើយ៖** តុលាការនេះគឺជាតុលាការអន្តរជាតិដំបូងបង្អស់ដែលកាត់ក្តីលើបទចោទស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៩៨ ដោយអនុលោមតាមការបកស្រាយនិងនិយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍ ដែលបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨។ តុលាការនេះ បានដាក់បញ្ចូលឧក្រិដ្ឋកម្មរំលោភបំពានផ្លូវភេទ ជាផ្នែកមួយនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

# បញ្ជីឯកសារពិគ្រោះ

## ប្រទេសបូស្នី-ហឺហ្សីហ្គោវីន


Aleksa, Djilas, 1995. "Tito's Last Secret: How Did He Keep the Yugoslavs Together," In *Tito and the Rise and Fall of Yugoslavia*, edited by Richard West, 116–124. New York: Caroll & Graf.

Edina, Bećirević, 2014. "The Dissolution of Yugoslav and the Propaganda of Dehumanization," *In Genocide on the Drina River*, edited by Bećirević Edina, 16–49. New Haven, CT: Yale University Press.

Lejla Lasic, Jasmina Hindija Cakar, Gabrijela Radosavljevic, Belma Kalamujic and Naris Pojski, "Historical Overview of the Human Population-Genetic Studies in Bosnia and Herzegovina: Small Country, Great Diversity." *Collegium Antropologicum* 40, no. 2 (June 2016): 145–149.

Marko, Attila Hoare, "Towards an Explanation for the Bosnian Genocide of 1992–1995." *Studies in Ethnicity and Nationalis*m 14 no. 3 (December 2014): 516–532.

Rene, Lemarchand, 2003. "Comparing the Killing Fields: Rwanda, Cambodia and Bosnia," In Genocide: *Cases, Comparisons and Contemporary Debates*, edited by Steven L. B. Jensen and Gwynneth Llewellyn, 141–173. Kobenhavn, Denmark: Danish Center for Holocaust and Genocide Studies.

Stathis, N. Kalyvas and Nicholas, Sambanis, 2005. "Bosnia's Civil War: Origins and Violence Dynamics," In *Understanding Civil War: Evidence and Analysis*, edited by Paul Collier & Nicholas Sambanis, 191–230. World Bank.

Todor, Kuljic, "Was Tito Last Habsburg? Reflections on Tito's Role in the History of the Balkans." *Balkanistica.* 20 (2007): 85–100.

Torsti, Pilvi. 2003. *Divergent Stories, Convergent Attitudes.* Helsinki, Finland: Taifuuni.


## ប្រទេសកម្ពុជា


Becker, Elizabeth. 1998. *When the War Was Over.* New York, NY: Public Affairs.

Chanda, Nayan. 2009. *Brother Enemy: The War after the War.* New York, NY: Harcourt.

Chandler, David. 2008. *A History of Cambodia.* Boulder, CO: Avalon Publishing.

Dearing, Christopher, and Khamboly Dy. 2014. *A History of Anlong Veng Community: Final Stronghold of the Khmer Rouge Movement.* Phnom Penh, Cambodia: Sleuk Rith Institute/ Documentation Center of Cambodia.

Dy, Khamboly. 2007. *The History of Democratic Kampuchea*. Phnom Penh, Cambodia: Documentation Center of Cambodia.

Ea, Meng-Try and Sim, Sorya. 2001. *Victims and Perpetrators: The Testimony of Young Khmer Rouge Cadres at S-21.* Phnom Penh, Cambodia: Documentation Center of Cambodia.

Edwards, Penny. 2007. *Cambodge: The Cultivation of a Nation, 1860–1945.* Chiang Mai, Thailand: Silkworm Books.

Heder, Stephen P. and Tittemore, Brian D. 2004. *Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge.* Phnom Penh, Cambodia: Documentation Center of Cambodia.

Heuveline, Patrick. 2015. The Boundaries of Genocide: Quantifying the Uncertainty of the Death Toll during the Pol Pol Regime in Cambodia 1975–79. Population Studies 2015, Vol. 69 No. 2

Hinton, Alexander. 2004. Why Did They Kill?: *Cambodia in the Shadow of Genocide.* Oakland, CA: University of California Press.

———. *Man or Monster?: The Trial of a Khmer Rouge Torturer.* Durham, NC: Duke University Press.

Kiernan, Ben. 2004. *How Pol Pot Came to Power: Colonialism, Nationalism, and Communism.* New Haven, CT: Yale University Press.

———. *The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge: 1975–1979.* New Haven, CT: Yale University Press.

Mysliwiec, Eva. 1988. *Punishing the Poor: The International Isolation of Kampuchea.* Oxford, UK: Oxfam Professional.

Merle L. Pribbenow, "A Tale of Five Generals: Viet Nam's Invasion of Cambodia," *Journal of Military History* 70, no. 2 (April 2006): 459–486.

Tully, John. 2002. France on the Mekong: *A History of the Protectorate in Cambodia 1863–1953.* Lanham, MD: University Press of America.

## ប្រទេសអាល្លឺម៉ង់

Aly, Götz. 1999. *"Final Solution": Nazi Population Policy and the Murder of the European Jews.* London: Arnold.

Arad, Yitzhak. 1987. *Belzec, Sobibor, Treblinka: The Operation Reinhard Death Camps.* Bloomington: Indiana University Press.

Breitman, Richard. 1991. *The Architect of Genocide: Himmler and the Final Solution.* New York: Knopf.

Browning, Christopher. 2004. *The Origins of the Final Solution: The Evolution of Nazi Jewish Policy, September 1939-March 1942. Lincoln:* University of Nebraska Press.

Hilberg, Raul. 2003. *The Destruction of the European Jews.* New Haven, CT: Yale University Press.

Rudavsky, Joseph. 1997. *To Live With Hope, To Die With Dignity: Spiritual Resistance in the Ghettos and Camps.* Northvale, NJ: Jason Aronson.

Shuter, Jane. 2003. *Life and Death in the Camps. Chicago,* IL: Heinemann.

The United States Holocaust Museum Memorial Museum. n.d. "Timeline of Events." Accessed October 20, 2018. https://www.ushmm.org/.

## ប្រទេសរ៉ាន់ដា

Binaifer, Nowrojee. 1996. *Shattered Lives: Sexual Violence during the Rwandan Genocide and its Aftermath.* New York, NY: Human Rights Watch.

Corrie, Karen. 2013. "Beyond Arusha: The Global Effort to Prosecute Rwanda's Genocide." *Open Society Foundations.* Accessed October 31, 2018. https://www.opensocietyfoundations.org/voices/beyond-arusha-global-effort-prosecute-rwandas-genocide.

Des Forges, Allison. 1995. "Rwanda: The Crisis Continues." 7 no. 1. *Human Rights Watch/Africa.* Accessed October 31, 2018. hrw.org/legacy/reports/1995/Rwanda.htm.

———. 1999. *Leave None to Tell the Story: Genocide in Rwanda.* New York, NY: Human Rights Watch.

Human Rights Watch. 2011. "Justice Compromised: The Legacy of Rwanda's Community-Based *Gacaca Courts.*" Accessed October 31, 2018. https://www.hrw.org/sites/default/files/reports/rwanda0511webwcover_0.pdf.

———. 1995. "Rearming with Impunity: International Support for the Perpetration of the Rwandan Genocide." 7 no. 4. Accessed October 31, 2018. https://www.hrw.org/legacy/reports/1995/Rwanda1.htm.

*UNICTR, United Nations International Criminal Tribunal for Rwanda,* unictr.unmict.org/en/ictr-milestones. Accessed 1 Jul. 2017.

# ប្រវត្តិរូបសង្ខេបរបស់អ្នកកែសម្រួល អ្នកនិពន្ធ និងអ្នកបកប្រែ

**បណ្ឌិត ជា ផល្លា** គឺជាអ្នកគ្រប់គ្រងមួយរូបនៅក្នុងសាលា ឡូវែល នៃ រដ្ឋម៉ាស្សាឈូសេថ សហរដ្ឋអាមេរិក ជាទីកន្លែងដែលលោកស្រីបានបម្រើការងារក្នុងនាមជាអ្នកអប់រំចាប់តាំងពីឆ្នាំ១៩៩៥មកម្ល៉េះ។ បច្ចុប្បន្ន លោកស្រីគឺជាអ្នកសម្របសម្រួលកម្មវិធីអប់រំភាសាអង់គ្លេស។ ការបង្រៀន ការដឹកនាំ ការចូលរួមនៅក្នុងសហគមន៍ និងការគាំទ្ររបស់លោកស្រីចំពោះកម្មវិធីសិក្សាទូទៅពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ទី១២ ជាមួយនឹងសិស្សភាសាអង់គ្លេស គ្រួសារ និងសហគមន៍ គឺជាឆន្ទៈនិងបំណង់បំណូលចិត្តរបស់លោកស្រី។ បន្ថែមលើការងារគ្រប់គ្រងប្រចាំថ្ងៃ លោកស្រីក៏ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ហ្វីដបើកបឹក ស្តេត។ លោកស្រី គឺជាប្រធានសមាគមខ្មែរ និងជាហិរញ្ញិកនៃគណៈកម្មាធិការរៀបចំបុណ្យអុំទូកអាស៊ីអាគ្នេយ៍។ បច្ចុប្បន្ន លោកស្រីមានតួនាទីជាប្រធានគណៈកម្មាធិការនៃសន្និសីទស្តីពីជនភៀសខ្លួននិងជនអន្តោប្រវេសន៍ ព្រមទាំងជាសមាជិកមួយរូបនៃក្រុមប្រឹក្សាភាពជាដៃគូលើបេតិកភណ្ឌឡូវែល ក្នុងទីក្រុងឡូវែល រដ្ឋម៉ាស្សាឈូសេថ។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រនយោបាយ និងសង្គមវិទ្យា ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកកម្មវិធីសិក្សានិងការបង្រៀន និងថ្នាក់បណ្ឌិតស្តីពីភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំពីសាកលវិទ្យាល័យម៉ាស្សាឈូសេថ ក្នុងទីក្រុងឡូវែល។

លោកស្រីបានត្រឡប់មកកាន់ប្រទេសកម្ពុជា ដែលជាប្រទេសកំណើត ជាច្រើនលើកច្រើនសា ដើម្បីធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ក្នុងឆ្នាំ២០០៩ លោកស្រី បានសហការនិពន្ធសៀវភៅណែនាំគ្រូបង្រៀន៖ អំពីវិធីសាស្ត្របង្រៀន “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)”។ ជាផ្នែកមួយនៃគម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍ លោកស្រីបានចូលរួមចំណែកក្នុងការបណ្តុះបណ្តាលអ្នកអប់រំកម្ពុជាចំនួនជាង៥០០នាក់ទាក់ទងនឹងការអនុវត្តតាមសៀវភៅណែនាំគ្រូបង្រៀន និងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម។ ក្នុងខែកក្កដា ឆ្នាំ២០១០ និងក្នុងខែកក្កដា ឆ្នាំ២០១៦ លោកស្រីបានសហការដឹកនាំក្រុមហ្វូលប្រាយហេយស៍ ដែលជាគម្រោងនៃក្រុមអ្នកសិក្សានៅបរទេសមកកាន់ប្រទេសកម្ពុជា រួមមានអ្នកអប់រំមកពីសាលាសាធារណៈឡូវែល និងវិទ្យាល័យសហគមន៍មីដដលសិច។

**មេធាវី គ្រីស្តូហ្វ័រ ឌៀរីង** បំពេញការងារជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា/វិទ្យាស្ថានស្លឹករឹត ក្នុងនាមជាទីប្រឹក្សាឯករាជ្យអន្តរជាតិ, ទីប្រឹក្សាអប់រំ និងអ្នកស្រាវជ្រាវ ចាប់តាំងពីឆ្នាំ២០០៨មក។ លោកមានបទពិសោធន៍ទូលំទូលាយក្នុងការបង្កើតកម្មវិធីសិក្សាទាំងនៅក្នុងសហរដ្ឋអាមេរិក និងប្រទេសកំពុងអភិវឌ្ឍ។ លោកគឺជាសហអ្នកនិពន្ធសៀវភៅវិធីសាស្ត្របង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និង រយៈពេលចុងក្រោយរបស់ខ្មែរក្រហម៖ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។ បន្ថែមពីនេះ លោកក៏បានសហការនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពផ្សាយលើកទី២ (បោះពុម្ពឆាប់ៗ) និងជាអ្នកនិពន្ធសៀវភៅ អំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក៖ ទិដ្ឋភាពទូទៅសម្រាប់ការបង្រៀននៅក្នុងថ្នាក់រៀនរបស់កម្ពុជា។ លោកបានបោះពុម្ពការស្រាវជ្រាវ

លើប្រធានបទប្រវត្តិសាស្ត្រ ច្បាប់ និងការអប់រំជាច្រើន។ នៅក្នុងឆ្នាំ២០១៤ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(តុលាការកូនកាត់វាំងអង្គការសហប្រជាជាតិ-កម្ពុជា) បានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណុំរឿង០០២/០១ ដោយលើកឡើងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងប្រទេសកម្ពុជា និងការសម្លាប់មន្ត្រីនិងទាហានកម្ពុជាប្រព្រឹត្តឡើងដោយខ្មែរក្រហម។ ក្នុងចំណោមគម្រោងសំណងទាំងអស់ តុលាការបានទទួលស្គាល់កិច្ចការរបស់លោក គឺ "ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ" ជាជាគម្រោងសំណងយុត្តាធិការមួយ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០១។ លោកបានចូលរួមចំណែកក្នុងការបោះពុម្ពនេះ ដែលតំណាងឲ្យសមត្ថភាពផ្ទាល់ខ្លួនរបស់លោកក្នុងការប្រឹក្សាយោបល់តាមរយៈគំនិតផ្ទាល់ខ្លួន ដោយមិនតំណាងឲ្យការយល់ឃើញនៃនិយោជិក ឬអ្នកពាក់ព័ន្ធរបស់លោក នាពេលបច្ចុប្បន្ន ឬនាពេលមុននេះទេ។

**បណ្ឌិត លី សុខឃាង** គឺជានាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ លោកគឺជាកូនប្រុសច្បងក្នុងចំណោមបងប្អូន៤នាក់ មានដើមកំណើតក្នុងខេត្តកណ្តាល ជាទីតាំងដែលឪពុកម្តាយរបស់លោកប្រកបរបរកសិកម្ម។ ក្នុងឆ្នាំ២០០២ លោកបណ្ឌិតបានធ្វើការស្ម័គ្រចិត្ត និងក្រោយមកបានក្លាយជាបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ស្របពេលដែលលោកកំពុងសិក្សាថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងនាមជាបុគ្គលិកឆ្នើមមួយរូប លោកទទួលបានអាហារូបករណ៍ដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យខូវេនទ្រី ក្នុងចក្រភពអង់គ្លេសក្នុងឆ្នាំ២០០៥។ បន្ទាប់ពីបញ្ចប់ការសិក្សាក្នុងឆ្នាំ២០០៦ លោកបានត្រឡប់មកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាវិញ ក្នុងតួនាទីជាប្រធានគម្រោងឯកសាររស់ និងសក្ខីកម្មយុត្តិធម៌។ នៅក្នុងឆ្នាំ២០០៨ លោកបណ្ឌិតបានបន្តការសិក្សារបស់ខ្លួនថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យខូវេនទ្រី និងបានចំណាយពេល៦ឆ្នាំបន្តបន្ទាប់ ក្នុងការស្រាវជ្រាវលើប្រធានបទដែលមានចំណងជើងថា "កម្លាំងប្រទាញប្រទង់នៃដំណើរការផ្សះផ្សារបស់ប្រទេសកម្ពុជា ១៩៩៧-២០០៧"។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាជាស្ថាពរនៅក្នុងឆ្នាំ២០១៤។

**ផេង ពង្សរ៉ាស៊ី** គឺជានាយក មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលជាការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានចាប់ផ្តើមធ្វើការស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៧ និងនៅក្នុងឆ្នាំ១៩៩៨ លោកត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវលើគម្រោងស្តីពីការធ្វើផែនទីរណ្តៅសាកសព និងកោសល្យវិច្ច័យឆ្អឹងជនរងគ្រោះក្នុងរបបខ្មែរក្រហម។ ចាប់តាំងពីឆ្នាំ២០០៩ លោកបានកាន់តួនាទីជាប្រធានគម្រោងជាន់ខ្ពស់នៃគម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលមានគោលបំណងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនកម្ពុជាអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល ។

រ៉ាស៊ី បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រមុខវិជ្ជាភាសាអង់គ្លេសពីសាកលវិទ្យាល័យប៉ៀលប្រាយ ក្នុងឆ្នាំ២០០៨។ នៅក្នុងខែកក្កដា ឆ្នាំ២០០៩ រ៉ាស៊ី បានចូលរួមក្នុងកម្មវិធីសិក្សាអំពីសន្តិភាព និងជម្លោះ នៅសាកលវិទ្យាល័យស៊ីដនី ប្រទេសអូស្ត្រាលី ដោយលោកបានចែករំលែកអំពីបទពិសោធន៍របស់លោកលើផ្នែកយុត្តិធមិអន្តរកាល ការកសាងសន្តិភាព និងការផ្សះផ្សាក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំដដែល លោកបានធ្វើដំណើរទៅកាន់ចក្រភពអង់គ្លេសដើម្បីចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពីហ្វូឡូខស និងសិទ្ធិមនុស្ស។ នៅក្នុងឆ្នាំ២០១០ រ៉ាស៊ី បានចូលរួមនៅក្នុងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការងារ សម្រាប់គ្រូបង្រៀនបរទេសនៅសហរដ្ឋអាមេរិក។ លោកបានសិក្សានិងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាដល់សិស្សអាមេរិក នៅឯវិទ្យាល័យរដ្ឋឡូវែល ក្នុងរដ្ឋម៉ាស្សាឈូសេថ សហរដ្ឋអាមេរិក។ នៅខែឧសភា ឆ្នាំ២០១៤ លោកទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់លើមុខជំនាញភាពជាអ្នកដឹកនាំនិងគ្រប់គ្រងក្នុងវិស័យអប់រំ ពីសាកលវិទ្យាល័យដឺឡាសាល ប្រទេសហ្វីលីពីន។

**បេក្ខភាពបណ្ឌិត សូ ហ្វារីណា** គឺជានាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបន្ទុកគ្រប់គ្រងរួម វាយតម្លៃ និងរៃអង្គាសថវិកាសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហ្វារីណា បានចាប់ផ្តើមបំពេញការងារជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០០៣ ដោយចាប់ផ្តើមពីអ្នកស្ម័គ្រចិត្ត និងបន្ទាប់មកជាអ្នកសរសេរទស្សនាវដ្តីស្វែងរកការពិត រហូតក្លាយជាប្រធានគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់សម្រាប់ជនជាតិចាម ដែលកត់ត្រាអំពីបទពិសោធន៍របស់សហគមន៍ចាមមូស្លីម នៅក្នុងរបបខ្មែរក្រហម។ ក្នុងឆ្នាំ២០១១ ហ្វារីណា បានបោះពុម្ពកិច្ចការដំបូងបង្អស់របស់ខ្លួន ដែលមានចំណងជើងថា ហ៊ីចាប់នៃប្រទេសកម្ពុជា៖ ការបងចាំរបស់ស្ត្រីជនជាតិចាមមូស្លីម បន្ទាប់ពីរបបខ្មែរក្រហម ដែលបង្ហាញអំពីបទពិសោធន៍ផ្សេងៗរបស់ស្ត្រីចំពោះការសម្លាប់រង្គាល និងវិធីសាស្ត្រដែលអ្នកទាំងនេះប្រើប្រាស់ដើម្បីតតាំងជាមួយនឹងអតីតកាល។ ដោយមើលឃើញថា ស្ត្រីជាច្រើនដែលមានអាយុស្របាលនឹងខ្លួនបានបោះបង់ការសិក្សាដោយសារតែកត្តាសេដ្ឋកិច្ចនិងវប្បធមិ ហ្វារីណា បានប្តេជ្ញាបន្តការសិក្សារបស់ខ្លួនដើម្បីជួយដល់គ្រួសារនិងដោះស្រាយផលលំបាកដែលស្ត្រីនានាបានជួបប្រទះ។ ទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីម្តាយរបស់ខ្លួន ហ្វារីណា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនិងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់។ ហ្វារីណា បានបេញផ្សាយអត្ថបទនិងជំពូកសៀវភៅជាច្រើនទាក់ទងនឹងសិទ្ធិមនុស្ស យេនឌ័រ និងជនជាតិឥស្លាម។ លោកស្រី ក៏បានធ្វើបទបង្ហាញដល់អ្នកស្តាប់ក្នុងស្រុកនិងអន្តរជាតិអំពីប្រធានបទជាច្រើន រួមមានអំពើប្រល័យពូជសាសន៍និងប្រវត្តិសាស្ត្រផ្ទាល់មាត់ រហូតដល់អំពើហិង្សាផ្លូវភេទ។ ហ្វារីណា បច្ចុប្បន្នគឺជាបេក្ខភាពបណ្ឌិតជំនាញការសិក្សាអំពីសកលលោក នៅសាកលវិទ្យាល័យម៉ាស្សាឈូសេថ ឡូវែល។

**សុភ័ក្រ្ត ភាណា** គឺជាប្រធានគម្រោងស្រាវជ្រាវឯកសារភាសាចិននៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ភាណា បានចាប់ផ្តើមបំពេញការងារជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងនាមជាអ្នកស្ម័គ្រចិត្តក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះ នៅក្នុងឆ្នាំ២០១៤។ នៅក្នុងតួនាទីនេះ ភាណា បានចូលរួមនៅក្នុងការគាំពារដល់ជនរងគ្រោះ តាមរយៈ ការសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចម្លងបទសម្ភាសជាឯកសារសំណៅ បកប្រែភាសាអង់គ្លេស និងកែសម្រួលឯកសារវិភាគនិងអត្ថបទអប់រំ។ នៅខែមករា ឆ្នាំ២០១៥ ភាណា ត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជា។ ក្នុងមុខតំណែងនេះ ភាណា បានជួយដល់ការបង្កើតគោលនយោបាយអភិវឌ្ឍផ្ទៃក្នុងនិងការរៀបចំផែនការយុទ្ធសាស្រ្ត។ ភាណា ក៏បានបំពេញមុខងារជាអ្នកពិនិត្យផ្ទៀងផ្ទាត់នៃទស្សនាវដ្តីស្វែងរកការពិត។ ក្នុងរយៈពេលនៃការបំពេញការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ភាណា ក៏បានចូលរួមនៅក្នុងសកម្មភាពអប់រំនិងផ្សព្វផ្សាយ ទាក់ទងនឹងប្រវត្តិសាស្រ្តនៃអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា។

ភាណា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកអប់រំលើមុខជំនាញភាសាអង់គ្លេស ពីវិទ្យាស្ថានភាសាបរទេស និងថ្នាក់បរិញ្ញាប័ត្រផ្នែកជំនួញលើមុខជំនាញធនាគារ និងហិរញ្ញវត្ថុ ពីវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះដែរ ភាណា ក៏បញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ជំនាញសារព័ត៌មានអន្តរជាតិពីសាកលវិទ្យាល័យ បាផធីស នៃទីក្រុងហុងកុង។ នៅដើមឆ្នាំ២០១៧ ភាណា បានចូលរួមកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ ទៅកាន់សាកលវិទ្យាល័យ ឆៀងម៉ៃ ប្រទេសថៃ ដើម្បីសិក្សាអំពីតំបន់អាស៊ីអាគ្នេយ៍។

# អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅក្នុងខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាជាធរមានដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានការកោតសរសើរ និងពានរង្វាន់ជាច្រើនចំពោះកិច្ចការរបស់ខ្លួន ក្នុងការគាំទ្រឲ្យមានការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងឆ្នាំ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពានរង្វាន់សិទ្ធិមនុស្ស ជូឌិត លី ស្ត្រូណាច់ ពីមជ្ឈមណ្ឌលយុត្តិធម៌និងការទទួលខុសត្រូវ។ នៅក្នុងឆ្នាំដដែល ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ជាការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាម្ចាស់ពានរង្វាន់ រ៉ាម៉ុន ម៉ាកសៃសៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី ក្នុងការថែរក្សាការចងចាំជាប្រវត្តិសាស្ត្រដើម្បីការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។

# សេចក្ដីថ្លែងអំណរគុណ

សៀវភៅនេះពុំអាចចេញជារូបរាងបានឡើយ ប្រសិនបើគ្មានការគាំទ្រជំនួយនិងការលើកទឹកចិត្តដ៏ស្មោះស្ម័គ្រពីសំណាក់បុគ្គល និងស្ថាប័ន ដែលប្ដេជ្ញាចិត្តដើម្បីបុព្វហេតុ នៃការអប់រំពីអំពើប្រល័យពូជសាសន៍។ អ្នកនិពន្ធទាំងអស់ សូមថ្លែងអំណរគុណ ចំពោះការគាំទ្រដ៏សប្បុរសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការគ្រប់គ្រង និងគាំទ្រការសិក្សាស្រាវជ្រាវនេះ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ចំពោះការចូលរួមចំណែកយ៉ាង សប្បុរស និងបានផ្ដល់ជំនួយដ៏ចម្បងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកនិពន្ធ សូមថ្លែងអំណរគុណជាអនេកដល់ បណ្ឌិត អាឡិបសាន់ឌឺ ហ៊ីនតុន, សាស្ត្រាចារ្យ ម៉ាគើស ហ្សីមម៉រ, បណ្ឌិត មីលតុន អូរស្បូន, ព្រះរាជអាជ្ញា នីកូឡាស កូមជាន, អ្នកស្រាវជ្រាវ នីស្សា ផេបេល និងអ្នកគ្រូ ខែលលី វ៉ាត់សុន ដែលបានរួមចំណែកផ្ដល់មតិយោបល់ និងការកែ តម្រូវដ៏មានតម្លៃលើកិច្ចការនេះ។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ប្រវត្តិវិទូ ដេវីដ ឆេនល័រ ដែលបានចំណាយពេលវេលា ពេញមួយជីវិតរបស់លោកក្នុងកិច្ចការស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា និងជំរុញឲ្យមានការអប់រំពី ប្រវត្តិសាស្ត្រនេះដល់មនុស្សជំនាន់ក្រោយ។ សំណៅព្រាងដំបូងនៃសៀវភៅនេះ ត្រូវបានធ្វើបទបង្ហាញនិងពិភាក្សានៅក្នុង វគ្គបណ្ដុះបណ្ដាលសាស្ត្រាចារ្យឧត្តមសិក្សាចំនួន៩០រូប ស្ដីពី “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៩។ ទន្ទឹមនឹងនេះដែរ អ្នកនិពន្ធសូមសម្ដែងអំណរគុណដល់សាស្ត្រាចារ្យដែលបានអញ្ជើញមកពីបណ្ដាសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា ចំពោះមតិយោបល់ដើម្បីស្ថាបនាលើសំណៅព្រាង។ អ្នកនិពន្ធ សូមអរគុណចំពោះលោក ផេង ពង្សរ៉ាស៊ី និង សុភ័ក្ត្រ ភាណា ដែលបានបកប្រែសៀវភៅនេះជាភាសាខ្មែរ។ អ្នកនិពន្ធសូមអរគុណដល់លោកស្រី លី សេនសូនីឡា ដែលជាអ្នករចនា សៀវភៅ ចំពោះភាពអត់ធ្មត់និងជំនួយដ៏ស្វាហាប់របស់លោកស្រីក្នុងការរចនានិងការរៀបចំរូបភាពនិងក្រាហ្វិចសម្រាប់ សៀវភៅនេះ។ ជាចុងក្រោយបង្អស់ យើងខ្ញុំសូមសម្ដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តជំរុញកិច្ចការស្រាវជ្រាវ និងការអប់រំអំពីសោកនាដកម្មដែលបាន កើតមានក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។


បូស្ន៊ី-ហឺហ្សីហ្គោវីន


កម្ពុជា


អាល្លឺម៉ង់


រវ៉ាន់ដា

រូបភាពលើក្របសៀវភៅថតដោយ គ្រីស្តូហ្វ័រ ឌៀរីង៖ រូបបដិមាអ្នកតាព្រះភក្ត្រ៨ នៅលើជម្រាលភ្នំដងរែកពើយតាម៉ុក - មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង